វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
*Working Together for Positive Change*



# ការត្រៀមខ្លួនរបស់គ្រួសារកសិករខ្នាតតូចកម្ពុជា ឆ្ពោះទៅសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន

ស្រាវជ្រាវដោយ៖ លោកសួន សេង ឡារ ដានីញ៉ែលព្រុស៍ ចាយ គាថា និង ឈាង សុខម៉ៅ



ភ្នំពេញ កម្ពុជា
ខែធ្នូ ឆ្នាំ២០១៦

## ការត្រៀមខ្លួនរបស់គ្រួសារកសិករខ្នាតតូចកម្ពុជា ឆ្ពោះទៅសមាហរណកម្ម សហគមន៍សេដ្ឋកិច្ចអាស៊ាន

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែធ្នូ ឆ្នាំ២០១៦
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
កម្មវិធីបរិស្ថាន, គម្រោងតាមដានគោលនយោបាយកសិកម្ម

ស្រាវជ្រាវដោយ៖ លោកសួន សេង ឡារ ដានីញែលព្រុស៍ ចាយ គាថា និង ឈាង សុខម៉ៅ
រចនាអត្ថបទដោយ៖ លោក ភួន យូ អ្នកសម្របសម្រួលប្រព័ន្ធព័ត៌មាន និងទំនាក់ទំនង

### សេចក្តីបញ្ជាក់៖

ទស្សនៈបង្ហាញក្នុងរបាយកាណ៍នេះសុទ្ធតែជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនបង្ហាញពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាទេ។ នៅពេលខ្លឹមសារនៃរបាយការណ៍នេះត្រូវគេដកស្រង់ ឬផលិតសារជាថ្មី ការទទួលស្គាល់ និងការសុំអនុញ្ញាតសិទ្ធិរបស់អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវគេអោយតម្លៃ។

© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា, ខែធ្នូ ឆ្នាំ ២០១៦

## សេចក្តីថ្លែងអំណរគុណ

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ កើតឡើងដោយមានការចូលរួមពីក្រុមការងារអង្គការដៃគូ និងអ្នកពាក់ព័ន្ធដទៃផ្សេងទៀត។ ក្រុមការងាររបស់អង្គការសិនដរ សូមសម្តែងនូវអំណរគុណ និងការកោតសរសើរចំពោះអង្គការអុកស្វាម ដែលបានផ្តល់ថវិកាសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

បន្ថែមលើសនេះ យើងខ្ញុំសូមសម្តែងនូវអំណរគុណ ចំពោះមន្ទីរកសិកម្ម មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរកិច្ចការនារីក្នុងខេត្តទាំង៣ នាយកដ្ឋានឧត្តុនិយម នាយកដ្ឋានស្ថិតិគណនេយ្យ និងហិរញ្ញវត្ថុ ដែលបានផ្តល់នូវឯកសារ ទិន្នន័យពាក់ព័ន្ធទាំងឡាយ រួមនឹងការសហការក្នុងការផ្តល់មន្ត្រីរបស់ខ្លួន ចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។

យើងខ្ញុំ ក៏សូមថ្លែងអំណរគុណដល់អាជ្ញាធរថ្នាក់ភូមិ ឃុំ និងស្រុក ដែលបានចូលរួមសហការយ៉ាងពេញលេញជាមួយក្រុមការងារយើងខ្ញុំ ដោយបានផ្តល់នូវទិន្នន័យពាក់ព័ន្ធទាំងឡាយ និងការគាំទ្រដល់ក្រុមការងារក្នុងការចុះប្រមូលទិន្នន័យ នៅថ្នាក់មូលដ្ឋាន។ លើសពីនេះ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ប្រជាសហគមន៍មូលដ្ឋានដែលបានចំណាយពេលវេលាជាមួយក្រុមការងារយើងខ្ញុំ កំឡុងពេលផ្តល់បទសម្ភាសន៍ជាលក្ខណៈគ្រួសារ និងការធ្វើករណីសិក្សា។ ប្រសិនបើគ្មានការសហការទាំងអស់នេះទេ ការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ ពិតជាមិនអាចបញ្ចប់សព្វគ្រប់បានឡើយ។

តំណាងក្រុមការងារផ្នែកប្រឹក្សាយោបល់<br>
ប្រធានក្រុម

សួន សេង

# មាតិកា


**សង្ខេប** ..... ii
I. **សេចក្តីផ្តើម** ..... **១**
II. **វិធីសាស្រ្ត និងយុទ្ធវិធី** ..... **២**
III. **ក្របខណ្ឌគោលនយោបាយគាំទ្រគ្រួសារកសិករខ្នាតតូច** ..... **៥**
3.1. ក្របខណ្ឌគោលនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ានក្នុងការគាំទ្រគ្រួសារ កសិករខ្នាតតូច ..... ៥
3.2. គោលនយោបាយកម្ពុជាក្នុងការគាំទ្រដល់គ្រួសារកសិករខ្នាតតូច ..... ១២
IV. **ស្ថានភាពកសិកម្មកម្ពុជា** ..... **១៨**
V. **ករណីសិក្សាស្តីពីស្ថានភាពកសិកម្មរបស់គ្រួសារកសិករខ្នាតតូច** ..... **២១**
5.1 ប្រវត្តិរូបសំខាន់ៗនៃគ្រួសារអ្នកផ្តល់ព័ត៌មាន ..... ២១
5.2. សកម្មភាពសេដ្ឋកិច្ចគ្រួសារ និងប្រាក់ចំណូល ..... ២៤
5.3. លទ្ធភាពទទួលបានព័ត៌មានការធ្វើសេចក្តីសម្រេចចិត្តនិងចំណេះដឹងស្តីពី សហគមន៍សេដ្ឋកិច្ចអាស៊ាន ..... ២៦
5.4. លទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ ..... ២៨
VI. **កាលានុវត្តភាព បញ្ហាប្រឈម និងតម្រូវការផ្នែកសមត្ថភាពរបស់គ្រួសារកសិករខ្នាតតូចឆ្ពោះទៅសហគមន៍សេដ្ឋកិច្ចអាស៊ាន** ..... **៣១**
6.1. កាលានុវត្តភាពជាគន្លឹះ ..... ៣១
6.2. បញ្ហាប្រឈម និងឧបសគ្គជាគន្លឹះ ..... ៣៣
6.3. តម្រូវការផ្នែកសមត្ថភាព ..... ៣៦
VII. **បញ្ហាកំពុងវិវឌ្ឍន៍ និងទំនាក់ទំនង ចំពោះគ្រួសារកសិករខ្នាតតូច** ..... **៣៩**
7.1. បណ្តាកម្មសិទ្ធិដីធ្លីនិងសន្តិសុខនៃការកាន់កាប់ដីធ្លី ..... ៣៩
7.2. ប្រព័ន្ធស្រោចស្រពខ្នាតធំនិងមធ្យម និងប្រព័ន្ធស្រោចស្រពខ្នាតតូច ..... ៤១
7.3. ការវិនិយោគផ្ទាល់ពីបរទេស និងការវិនិយោគផ្ទាល់ក្នុងស្រុក ..... ៤៣
7.4. បច្ចេកទេសកសិកម្មនិងទីផ្សារ ..... ៤៥
VIII. **សន្និដ្ឋាន និងការផ្តល់អនុសាសន៍** ..... **៤៩**
**បញ្ជីឯកសារយោង** ..... **៥២**
**ឧបសម្ព័ន្ធទី១៖ បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ** ..... **៥៤**

## សង្ខេប

ការសិក្សាស្តីអំពី "ការត្រៀមខ្លួនរបស់គ្រួសារកសិករខ្នាតតូចកម្ពុជា ឆ្ពោះទៅសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន" ត្រូវបានធ្វើឡើងចាប់ពីខែមករា រហូតដល់ខែមីនា ឆ្នាំ២០១៦។ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា "អាស៊ាន" និងគោលនយោបាយជាតិពាក់ព័ន្ធទៅនឹងការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា ត្រូវបានពិនិត្យឡើងវិញ។ យើងបានសម្ភាសន៍មន្រ្តីសំខាន់ៗនៅថ្នាក់ជាតិ ដែលធ្វើកិច្ចការងារពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍកសិកម្ម និងការគាំទ្រដល់គ្រួសារកសិករខ្នាតតូច។ ការសម្ភាសជាលក្ខណៈគ្រួសារ ត្រូវបានធ្វើឡើងក្នុងស្រុកគោលដៅចំនួន៣ រួមមានៈ ស្រុកឈូកនៃខេត្តកំពតស្រុកសន្ទុកនៃខេត្តកំពង់ធំ និងស្រុកអូរយ៉ាដាវនៃខេត្តរតនគីរី។

## គោលបំណងនៃការសិក្សាស្រាវជ្រាវរួមមានៈ

- កំណត់ពីចំណុចខ្លាំង និងចំណុចខ្សោយស្តីអំពីក្របខណ្ឌគោលនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងការគាំទ្រដល់គ្រួសារកសិករខ្នាតតូច
- កំណត់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃគោលនយោបាយកម្ពុជាក្នុងការគាំទ្រដល់គ្រួសារកសិករខ្នាតតូចនៅកម្ពុជា
- កំណត់ពីតួនាទីរបស់គ្រួសារកសិករខ្នាតតូចក្នុងផលិតកម្មកសិកម្ម ដែលពាក់ព័ន្ធដល់ការចូលរួមរបស់កសិករជាបុរស និងកសិករជាស្រ្តីចំពោះកសិកម្មនៅកម្ពុជា
- កំណត់នូវបញ្ហាប្រឈម និងឱកាសទាំងឡាយ រួមនឹងតម្រូវការលើផ្នែកពង្រឹងសមត្ថភាព ដល់គ្រួសារកសិករខ្នាតតូចក្នុងផលិតកម្មកសិកម្ម ជាពិសេសស្រ្តី ឆ្ពោះទៅសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន
- ទាញចេញនូវអាទិភាពគោលនយោបាយ និងអនុសាសន៍ផ្សេងៗ ដើម្បីគាំទ្រដល់គ្រួសារកសិករខ្នាតតូចទាំងបុរស និងស្ត្រីឆ្ពោះទៅសហគមន៍សេដ្ឋកិច្ចអាស៊ាន។

## របកគំហើញសំខាន់ៗ៖

**ចំណុចខ្លាំង និងចំណុចខ្សោយនៃក្របខណ្ឌគោលនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ានក្នុងការគាំទ្រដល់គ្រួសារកសិករខ្នាតតូច៖**

- សារស្តីអំពីការបង្កើត និងការលើកកម្ពស់បរិស្ថានកសិកម្មប្រកបដោយនិរន្តរភាពមានលក្ខណៈច្បាស់លាស់ នៅក្នុងឯកសារចង្អុលទិសស្តីពីសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ ប៉ុន្តែបានលើកឡើងនូវបញ្ហាប្រឈមមួយចំនួនចំពោះបញ្ហាកម្មសិទ្ធិដីធ្លី ដែលត្រូវគិតគូរពិចារណា។ ទី១) ប្រព័ន្ធនៃការកាន់កាប់ដីធ្លី ត្រូវតែមានតម្លាភាពច្រើនបន្ថែមទៀតក្នុងតំបន់ ដើម្បីជៀសវាងនូវការកើតមានជម្លោះដីធ្លី និងធានាបាននូវសុវត្ថិភាពនៃសិទ្ធិរបស់គ្រួសារកសិករតូចតាចចំពោះធនធានផលិតកម្ម។ ទី២)មេរៀនសំខាន់ៗដែលបានរៀនសូត្រចេញពីវិបត្តិស្បៀងអាហារឆ្នាំ២០០៨ និងឆ្នាំ២០០៩ គឺថា ការរំដោះចេញនូវវិបត្តិសេដ្ឋកិច្ចបានជះឥទ្ធិពលជាអវិជ្ជមាន ចំពោះសន្តិសុខស្បៀងរបស់គ្រួសារកសិករខ្នាតតូច។
- សហគមន៍សេដ្ឋកិច្ចអាស៊ានមានវិស័យពិសេសមួយដែលហៅថា "កិច្ចសហប្រតិបត្តិការអាស៊ានស្តីពីចំណីអាហារ កសិកម្ម និងព្រៃឈើ" ដែលធ្វើកិច្ចការងារជាសំខាន់ ដើម្បីធានានូវសន្តិសុខស្បៀង ការអនុវត្តបច្ចេកវិទ្យាកសិកម្មបៃតង និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ទាំងនេះ រួមមាន៖ ១) ធានានូវសន្តិសុខស្បៀង សុវត្ថិភាពស្បៀង អាហារូបត្ថម្ភប្រសើរជាងមុន និងការចែកចាយប្រកបដោយសមធម៌ និង ២) ជួយគាំទ្រដល់អ្នកផលិតខ្នាតតូចដែលមិនមានធនធានគ្រប់គ្រាន់ និងសហគ្រាសខ្នាតតូចនិងមធ្យម ដើម្បីបង្កើននូវផលិតភាព បច្ចេកវិទ្យា និងគុណភាពផលិតផល ដើម្បីបំពេញបាននូវស្តង់ដារទីផ្សារសាកល និងបង្កើននូវភាពអាចប្រកួតប្រជែងបាន។
- តម្រូវការក្នុងការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និងភាពសក្តិសិទ្ធនៅក្នុងកសិកម្មកម្ពុជាត្រូវបានទទួលស្គាល់។ ជាអាទិ៍ ការចំណាយលើការដឹកជញ្ជូនផលិផលកម្ពុជាក្នុងស្រុកនៅមានតម្លៃខ្ពស់ ដូច្នេះអាចសបញ្ជាក់ឲ្យឃើញថា សេដ្ឋកិច្ចរបស់កម្ពុជានៅមិនទាន់ទទួលបានផលប្រយោជន៍ពេញលេញ ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់នៅឡើយទេ។
- នៅក្នុងឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ បញ្ហាពាក់ព័ន្ធនឹងយេនឌ័រ ត្រូវបានគូសបញ្ជាក់។ វាបានកំណត់ថា សហគ្រិនភាពគួរត្រូវ

បានលើកកម្ពស់ តាមរយៈការបង្កើតប្រព័ន្ធ និងយន្តការដែលនឹងបង្កើនការចូលរួមរបស់ស្ត្រី។ ទោះយ៉ាងណាក្តី នៅពេលនិយាយដល់សមភាពយេនឌ័រចំពោះគ្រួសារកសិករខ្នាតតូច មានកិច្ចការជាច្រើនទៀតដែលមិនទាន់សម្រេចបាននៅឡើយ។ មិនមានក្របខណ្ឌជាក់លាក់ណាមួយ ដែលពិភាក្សាពីរបៀបនៃការលុបបំបាត់ នូវគម្លាតយេនឌ័រដែលកំពុងកើតមាននាពេលបច្ចុប្បន្ននេះនៅឡើយទេ។

- ចំពោះអន្តោប្រវេសការងារអន្តរ តំបន់ក្នុងសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍នាពេលបច្ចុប្បន្ន សហគមន៍សេដ្ឋកិច្ចអាស៊ានបានគូសបញ្ជាក់ និងទទួលស្គាល់តែក្រុមពលកម្មជំនាញកម្រិតខ្ពស់ៗ ដូចជា វេជ្ជបណ្ឌិត វិស្វករ ស្ថាបត្យករ ។ល។ តែប៉ុណ្ណោះ។ ដោយឡែក ក្រុមកម្លាំងពលកម្មដែលមានជំនាញកម្រិតទាប និងមធ្យម ជាអាទិ៍ក្នុងវិស័យកសិកម្ម និងនេសាទ កម្មករក្នុងស្រុក និងកម្មករសំណង់ មិនត្រូវបានដាក់បញ្ចូល ដោយក្របខណ្ឌណាមួយនៃសហគមន៍សេដ្ឋកិច្ចអាស៊ានឡើយ។

**ចំណុចខ្លាំង និងចំណុចខ្សោយនៃគោលនយោបាយកម្ពុជា ក្នុងការគាំទ្រដល់គ្រួសារកសិករខ្នាតតូចៈ**

- កសិកម្មគឺជាវិស័យអាទិភាព ដូចដែលបានបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ វិស័យនេះត្រូវបានទទួលស្គាល់ថា បានដើរតួនាទីសំខាន់ក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច ជាពិសេសការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ប៉ុន្តែក៏ជួយធានាបាននូវសន្តិសុខស្បៀង និងសមធម៌ផងដែរ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ បានបង្កើនការយកចិត្តទុកដាក់ទៅលើការធ្វើទំនើបកម្មកសិកម្ម ពិពិធូបនីកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មផលិតកម្មកសិកម្មផងដែរ។
- ដើម្បីគាំទ្រដល់គ្រួសារកសិករខ្នាតតូច ឯកសារគតិយុត្ត និងគោលនយោបាយមួយចំនួន ត្រូវបានរៀបចំដោយរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសាមី។ ឯកសារទាំងនោះរួមមានៈ គោលនយោបាយពូជស្រូវ និងពូជដំណាំ គោលនយោបាយស្តង់ដារកសិកម្មសរីរាង្គកម្ពុជា គោលនយោបាយនាំចេញអង្ករ និងច្បាប់ស្តីពីសហគមន៍កសិកម្ម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើរតួនាទីជាសំខាន់ ក្នុងការដឹកនាំ គ្រប់គ្រង គាំទ្រ និងធានាថា សេចក្តីថ្លែងគោលនយោបាយ និងការប្តេជ្ញាចិត្តទាំងឡាយលើកិច្ចអភិវឌ្ឍកសិកម្ម អាច

សម្រេចបាន ព្រមទាំងធានាបាននូវសន្តិសុខ និងសុវត្ថិភាពស្បៀងនៅកម្ពុជា។ ទោះយ៉ាងណាក្តី វានៅមិនទាន់ច្បាស់នៅឡើយទេថា ច្បាប់ដីធ្លីដែលត្រូវបាន ដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា បានលើកទឹកចិត្តដល់ការវិនិយោគឯកជន តាមរយៈការផ្តល់ដីរបស់រដ្ឋជាដីសម្បទានក្នុងទ្រង់ទ្រាយធំ ឬ យ៉ាងណានៅឡើយទេ។ អនុក្រិត្យស្តីអំពីសម្បទានដីសេដ្ឋកិច្ច ក៏ត្រូវបានបង្កើតឡើងផងដែរ។

- ក្នុងរយៈពេល ៦ឆ្នាំចុងក្រោយនេះ (២០០៩-២០១៤) រដ្ឋាភិបាលបានបង្កើនថវិកាជាតិចំនួន៧៨% ដល់ក្រសួងកសិកម្ម និង៤៣% ដល់ក្រសួងកិច្ចការនារី។ ទោះយ៉ាងនេះក្តី ការចូលរួមចំណែករបស់វិស័យកសិកម្ម ក្នុងផលិតផលសរុបជាតិ បានថយចុះចំនួន១៤%។ នេះមានន័យថា វិស័យកសិកម្មមានការកើនឡើង ប៉ុន្តែវិស័យឧស្សាហកម្ម និងសេវាកម្ម មានការរីកចម្រើនច្រើនជាង។ ការនេះ ធ្វើឲ្យវិស័យកសិកម្ម មានការចាប់អារម្មណ៍តិចជាងមុនពីវិនិយោគិន។

**ចំពោះតួនាទីរបស់គ្រួសារកសិករខ្នាតតូចក្នុងវិស័យកសិកម្ម យើងបានរកឃើញថា៖**

- គ្រួសារកសិករដែលបានសម្ភាសន៍ស្ទើរតែទាំងអស់ មានប្រភេទដីកសិកម្មជាដីសម្រាប់ធ្វើស្រែ និងដីចម្ការ។ ប្រមាណពាក់កណ្តាលនៃគ្រួសារនៅស្រុកសន្ទុកដែលបានសម្ភាសន៍ ៧០%នៅស្រុកអូរយ៉ាដាវ និង៩៥%នៃគ្រួសារនៅស្រុកជុំគីរី មានដីសម្រាប់ធ្វើស្រែ។ គួរកត់សម្គាល់ផងដែរថា៖ ១)យ៉ាងហោចណាស់ ៧០%នៃគ្រួសារដែលបានសម្ភាសន៍ មានម៉ូតូ ហើយគ្រប់គ្រួសារមានទូរស័ព្ទដៃប្រើប្រាស់ ២)មានការកើនឡើងការប្រើប្រាស់ម៉ាស៊ីនកាត់ស្មៅក្នុងស្រុកអូរយ៉ាដាវ ជាអាទិ៍ ៤០%នៃគ្រួសារដែលបានសម្ភាសន៍នៅក្នុងស្រុកនេះ មានឧបករណ៍កាត់ស្មៅប្រើប្រាស់ ៣) ភាពជាម្ចាស់លើគោយន្ត ឬ គោយន្តសណ្តោងរ៉ឺម៉ក ក៏មានការកើនឡើងផងដែរ។
- ចំណូលសរុបប្រចាំឆ្នាំនៃគ្រួសារដែលបានសម្ភាសន៍ មានភាពខុសប្លែកគ្នាពោលគឺមានចំនួន ២,០៩០ដុល្លារ នៅស្រុកជុំគីរី ២,៣៣០ដុល្លារនៅស្រុកសន្ទុក និងកើនដល់២,៨៧២ដុល្លារនៅស្រុកអូរយ៉ាដាវ។ នៅស្រុកអូរយ៉ាដាវ ចំណូលពីកសិកម្មមានចំនួន៥៧% នៃចំណូលសរុបក្នុងគ្រួសារ ខណៈស្រុកសន្ទុកមាន៥២% និងមានត្រឹមតែ២៥% នៅស្រុកជុំគីរី។បើប្រៀបនឹង៥ឆ្នាំមុន ចំណូលពីកសិកម្មមានប្រមាណ៤៨%នៅស្រុកសន្ទុក ៥៤%នៅស្រុកអូរយ៉ាដាវ និង៤៣% នៅស្រុកជុំគីរី។

- ៥០%នៃគ្រួសារដែលបានសម្ភាសន៍នៅស្រុកសន្ទុក ៦០%នៅស្រុកអូរយ៉ាដាវ និង៩០% នៅស្រុកជុំគីរី បានប្រើប្រាស់ប្រាក់កម្ចី។ ទំហំប្រាក់កម្ចីជាមធ្យម ស្ថិតនៅចន្លោះពី ៧០០ដុល្លារ ដល់ ១,៥០០ដុល្លារ។ នៅស្រុកសន្ទុក និង ស្រុកអូរយ៉ាដាវ ប្រាក់កម្ចីត្រូវបានប្រើប្រាស់សម្រាប់ការដាំដុះដំណាំមិនមែន ស្រូវ ពិសេសដំឡូងមី និងដំណាំស្វាយចន្ទី និងទៅលើស្បៀងអាហារក្នុង កំឡុងពេលខ្វះខាត។ ដោយឡែក នៅស្រុកជុំគីរី កម្ចីត្រូវបានប្រើប្រាស់ សម្រាប់ចំណាយលើការធ្វើចំណាកស្រុក និងធាតុចូលកសិកម្មមួយចំនួន។

**ក្នុងន័យស្តីពីកាលានុវត្តភាព បញ្ហាប្រឈម និងតម្រូវការផ្នែកសមត្ថភាព យើងរកឃើញថា៖**

- **កាលានុវត្តភាពចំពោះគ្រួសារកសិករខ្នាតតូចដែលអាចកំណត់បានរួមមាន៖** ១) វត្តមាននៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជនបទនិងសេវាដឹកជញ្ជូន ២) ប្រព័ន្ធ ទូរគមនាគមន៍ ៣)ប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និង៤)ឱកាសការងារ ក្រៅកសិកម្មជាចំណូលបន្ថែមក្នុងគ្រួសារ។ កាលានុវត្តភាពស្ថិតក្នុងតំបន់ដែល បានធ្វើការសិក្សា ត្រូវបានចាត់ក្នុងលំដាប់ថ្នាក់ពីមធ្យមទៅល្អណាស់។
- **បញ្ហាប្រឈម និងឧបសគ្គចំពោះគ្រួសារកសិករខ្នាតតូច ត្រូវបានកំណត់ រួមមាន៖**១) ការទទួលបាននូវដីកសិកម្ម និងទឹកសម្រាប់ការស្រោចស្រព ២) លទ្ធភាពទទួលបានទីផ្សារសម្រាប់លក់ផលិតផលកសិកម្ម ៣)លទ្ធភាពទទួល បានទុនដើម្បីវិនិយោគក្នុងផលិតកម្មកសិកម្ម និង ៤)លទ្ធភាពទទួលបានធាតុ ចូលកសិកម្មដែលមានគុណភាព (ពូជ ជី និងថ្នាំសម្លាប់សត្វល្អិត) និងបច្ចេក ទេស។ លទ្ធភាពទទួលបានទឹកស្រោចស្រព ត្រូវបានចាត់ចំណាត់ថ្នាក់ក្នុង កម្រិតខ្សត់ខ្សោយទៅមធ្យម ខណៈលទ្ធភាពទទួលបានទីផ្សារសម្រាប់លក់ ផលិតផលកសិកម្មនិងទុនសម្រាប់ការវិនិយោគកសិកម្ម ត្រូវបានចាត់ថ្នាក់ពី មធ្យមទៅល្អ។ ដោយឡែក លទ្ធភាពទទួលបានធាតុចូលកសិកម្មដែលមាន គុណភាព និងបច្ចេកទេសកសិកម្ម ត្រូវបានចាត់ថ្នាក់ក្នុងកម្រិតមធ្យមតែ ប៉ុណ្ណោះ។
- **តម្រូវការសមត្ថភាពដែលចាំបាច់សម្រាប់គ្រួសារកសិករខ្នាតតូចត្រូវបានកំណត់ រួមមាន៖** ១) ការចងក្រងក្រុម និងសហគមន៍កសិកម្ម ២) ចំណេះដឹងបច្ចេក ទេសតាមគោលការណ៍ការអនុវត្តកសិកម្មល្អ ៣)ការបង្កើតនូវប្រព័ន្ធផលិតកម្ម ស្បៀងប្រកបដោយនិរន្តរភាព និងអក្ខរកម្មហិរញ្ញវត្ថុ និងការគ្រប់គ្រងលំហូរ

សាច់ប្រាក់ក្នុងគ្រួសារ។ សមត្ថភាពជាតម្រូវការទាំងអស់នេះ ត្រូវបានចាត់ក្នុងលំដាប់ពីមានតម្រូវការទៅមានតម្រូវការខ្លាំង។

**ដើម្បីបង្កើននូវសន្តិសុខ និងភាពអាចប្រកួតប្រជែងបានសម្រាប់គ្រួសារកសិករខ្នាតតូច យើងខ្ញុំសូមផ្តល់ជាអនុសាសន៍ដូចខាងក្រោម៖**

- រាជរដ្ឋាភិបាលកម្ពុជា គួរធ្វើការវាយតម្លៃលើការអនុវត្តបទបញ្ជា ០១បប និងពង្រីកបន្ថែមនូវមេរៀនទាំងឡាយនេះ សម្រាប់បន្តបេសកកម្មដោះស្រាយដីធ្លីបន្តនៅតំបន់ដទៃផ្សេងទៀតក្នុងប្រទេសកម្ពុជា។ គ្រួសារកសិករជាច្រើននៅតែរង់ចាំការវិលត្រឡប់ជាថ្មី នូវបេសកកម្មរបស់និស្សិត ដើម្បីធ្វើការវាស់វែងដីធ្លីរបស់ពួកគាត់ និងផ្តល់បណ្ណកម្មសិទ្ធិជូនពួកគាត់ពីសំណាក់រាជរដ្ឋាភិបាល។
- រាជរដ្ឋាភិបាលកម្ពុជា គប្បីពិចារណា ដល់ការវិនិយោគប្រព័ន្ធស្រោចស្រពខ្នាតតូចនៅតំបន់ដែលងាយប្រឈមនឹងគ្រោះរាំងស្ងួត។ កិច្ចការនេះ អាចជាការឧបត្ថម្ភធន លើការវិនិយោគជាលក្ខណៈគ្រួសារ ឬសហគមន៍ ឬប្រភេទនៃការស្រោចស្រពសហគមន៍ដែលរួមមានអាងស្តុកទ្រង់ទ្រាយតូច ដូចជាស្រះគ្រួសារ និងស្រះសហគមន៍ជាដើម។
- រាជរដ្ឋាភិបាលកម្ពុជា គប្បីពិចារណាដាក់ការវិនិយោគ ទៅឲ្យសមាគមថ្នាក់ស្រុកទាំងឡាយដែលបានបង្កើតឡើងហើយ ដើម្បីពួកគាត់អាចបង្កើនល្បឿននៃការអភិវឌ្ឍសហគមន៍។ កិច្ចការនេះ នឹងជួយពង្រឹងសមត្ថភាពដើម្បីអាចប្រកួតប្រជែងបានជាមួយកសិករផ្សេងទៀត ក្នុងបណ្តាប្រទេសជាសមាជិកសហគមន៍អាស៊ាន។
- លើសពីនេះ រដ្ឋាភិបាលគប្បីវិនិយោគបន្ថែម ក្នុងវិស័យស្រាវជ្រាវបច្ចេកទេសកសិកម្ម។ ការស្រាវជ្រាវ គប្បីផ្តោតលើការធ្វើឲ្យប្រសើរឡើងនូវផលិតភាពកសិកម្មរបស់គ្រួសារកសិករខ្នាតតូច។

# I. សេចក្តីផ្តើម

សមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលបានបញ្ចប់ទៅនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ត្រូវបានចាត់ទុកដោយរាជរដ្ឋាភិបាលកម្ពុជា ថាជាឱកាសផង និងជាកត្តាប្រឈមផងចំពោះសេដ្ឋកិច្ចកម្ពុជា។ វាត្រូវបានគេរំពឹងទុកថា តម្លៃពលកម្មទាប លទ្ធភាពទទួលបានទីផ្សារល្អប្រសើរ តាមរយៈប្រព័ន្ធទូទៅនៃភាពជឿជាក់ រួមនឹងលទ្ធភាពទទួលបានទីផ្សារ ដែលមានការពេញនិយមក្នុងសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងអាស៊ានបូកនឹងកិច្ចព្រមព្រាងពាណិជ្ជកម្មសេរី នឹងក្លាយជាកម្លាំងចលករ ដើម្បីទាក់ទាញការវិនិយោគសម្រាប់កម្ពុជា។ កិច្ចការនេះនឹងផ្តល់ឲ្យកម្ពុជានូវជំហរល្អមួយ ដើម្បីប្រកួតប្រជែងជាមួយទីផ្សារពិភពលោក ការវិនិយោគផ្ទាល់ពីបរទេស និងការទទួលបានអត្ថប្រយោជន៍ពីទំហំនៃសេដ្ឋកិច្ច។

វិស័យកសិកម្មកម្ពុជា ដែលផ្តល់ការងារដល់ប្រជាពលរដ្ឋប្រមាណ៧0% គ្របដណ្តប់ដោយគ្រួសារកសិករខ្នាតតូច ដែលសមត្ថភាពផ្នែកបច្ចេកទេសកសិកម្ម ប្រព័ន្ធស្រោចស្រព ដើមទុនវិនិយោគ និងការទទួលបានទីផ្សារកសិផលនៅមានកម្រិតនៅឡើយ។ ការសិក្សាដែលត្រូវបានធ្វើឡើងដោយ អង្គការសិនដរនៅឆ្នាំ២០១៥ ក្នុងចំណោមគ្រួសារកសិករខ្នាតតូចចំនួន ៣០៦គ្រួសារ នៅក្នុងខេត្តចំនួន ៣ រួមមាន ខេត្តតាកែវ កំពង់ស្ពឺ និងខេត្តកំពត បានបង្ហាញថា កសិករដែលចាប់យកកសិកម្មជាជម្រើសចិញ្ចឹមជីវិតជាចម្បង ទទួលបានចំណូលទាបជាងគេបំផុត ប្រៀបជាមួយគ្រួសារដែលចាប់យកជម្រើសមុខរបរក្រៅកសិកម្ម (Chay Keartha and Chheang Sokmao, 2015)។

ក្នុងគោលបំណងផ្តល់នូវព័ត៌មានដល់អ្នករៀបចំ និងអ្នកធ្វើសេចក្តីសម្រេចចិត្តលើផ្នែកគោលនយោបាយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា តាមរយៈបណ្តាញការងាររបស់ខ្លួន បានផ្តួចផ្តើមនូវការសិក្សាមួយស្តីអំពី "ការត្រៀមខ្លួនរបស់គ្រួសារកសិករខ្នាតតូច ឆ្ពោះទៅសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន" នេះឡើង។ ការសិក្សាមានគោលបំណងកំណត់នូវតួនាទី បញ្ហាប្រឈម និងកាលានុវត្តភាពសម្រាប់ គ្រួសារកសិករខ្នាតតូចកម្ពុជា ជាពិសេសស្ត្រីក្នុងផលិតកម្មកសិកម្ម ឆ្ពោះទៅសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ដូច្នេះ ការសិក្សានឹងបង្ហាញពីអនុសាសន៍គោលនយោបាយ ដើម្បីគាំទ្រដល់គ្រួសារកសិករខ្នាតតូចទាំងបុរស និងស្ត្រីថា តើគប្បីធ្វើរបៀបណា ដើម្បីឈរលើទីតាំងមួយល្អ ក្នុងការប្រកួតប្រជែង

ជាមួយប្រទេសជាសមាជិកអាស៊ានផ្សេងទៀត ក៏ដូចជាថែរក្សានូវកសិកម្ម កម្ពុជាសម្រាប់សន្តិសុខស្បៀង និងអធិបតេយ្យភាពស្បៀងផងដែរ។ ការសិក្សាបានកំណត់នូវគោលបំណងមួយចំនួន ដូចខាងក្រោម៖

- កំណត់ពីចំណុចខ្លាំង និងចំណុចខ្សោយ ស្តីអំពីក្របខណ្ឌគោលនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងការគាំទ្រដល់គ្រួសារកសិករខ្នាតតូច
- កំណត់ពីចំណុចខ្លាំង និងចំណុចខ្សោយ នៃគោលនយោបាយកម្ពុជា ក្នុងការគាំទ្រដល់គ្រួសារកសិករខ្នាតតូចរបស់កម្ពុជា
- កំណត់ពីតួនាទីរបស់គ្រួសារកសិករខ្នាតតូចក្នុងផលិតកម្មកសិកម្ម ដែលពាក់ព័ន្ធដល់ការចូលរួមរបស់កសិករជាបុរស និងកសិករជាស្ត្រីក្នុងកសិកម្មកម្ពុជា
- កំណត់នូវបញ្ហាប្រឈម និងឱកាសទាំងឡាយរួមនឹងតម្រូវការលើផ្នែកពង្រឹងសមត្ថភាព ដល់គ្រួសារកសិករខ្នាតតូចក្នុងផលិតកម្មកសិកម្ម ជាពិសេស ស្ត្រី ឆ្ពោះទៅសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន
- ទាញចេញនូវអាទិភាពគោលនយោបាយ និងអនុសាសន៍ផ្សេងៗ ដើម្បីគាំទ្រដល់កសិករខ្នាតតូចទាំងបុរស និងស្ត្រីឆ្ពោះទៅសហគមន៍សេដ្ឋកិច្ចអាស៊ាន។

## II. វិធីសាស្ត្រ និងយុទ្ធវិធី

ក្រុមអ្នកប្រឹក្សាយោបល់ត្រូវបានរៀបចំ ដោយមានអ្នកស្រាវជ្រាវចំនួន០៥រូបរួមមាន៖ លោក សួន សេង នាយកប្រតិបត្តិអង្គការសិនដរ ដើរតួជាអ្នកដឹកនាំក្នុងក្រុម នៃគម្រោងប្រឹក្សាយោបល់នេះ។ លោកដើរតួនាទីជាអ្នកទំនាក់ទំនងសំខាន់នៅក្នុងគម្រោង។ លោកសួន សេង ក៏ទទួលខុសត្រូវនៅក្នុងការធ្វើបទសម្ភាសន៍មន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមួយចំនួននៅទីក្រុងភ្នំពេញផងដែរ។ លោក ឡារ ដានីញែលព្រុស៍ ទទួលខុសត្រូវក្នុងការពិនិត្យលើឯកសារក្របខណ្ឌគោលនយោបាយអាស៊ាន ដោយផ្តោតជាសំខាន់លើគោលនយោបាយគាំទ្រកសិករ លោក ឈាង សុខម៉ៅ ដឹកនាំការពិនិត្យមើលលើឯកសារចង្អុលទិសនយោបាយកម្ពុជា ដែលគាំទ្រដល់គ្រួសារកសិករខ្នាតតូច។ ដោយឡែក លោកចាយ គាថា ធ្វើកិច្ចការជាមួយជំនួយការស្រាវជ្រាវ០២នាក់ទៀត ដើម្បីចុះធ្វើករណីសិក្សា។

កិច្ចការងារសំខាន់ចំនួន៥ ត្រូវបានអនុវត្តដោយក្រុមប្រឹក្សាយោបល់។ ការសិក្សានេះ បានចាប់ផ្តើមនៅដើមខែមករា រហូតដល់ខែមេសា ឆ្នាំ២០១៦។ កិច្ចការទាំងនោះរួមមាន៖

**កិច្ចការទី១៖ ការពិនិត្យមើលឯកសារចង្អុលទិសនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ាន និងការសិក្សា៖** តើអ្វីជាចំណុចខ្លាំង និងចំណុចខ្សោយ នៅក្នុងក្របខណ្ឌគតិយុត្ត និងគោលនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងការគាំទ្រដល់គ្រួសារកសិករតូចតាច?
កិច្ចការនេះរួមបញ្ចូល៖ តើអ្វីជាក្តីរំពឹងទុកពីសហគមន៍សេដ្ឋកិច្ចអាស៊ាន សម្រាប់វិស័យកសិកម្មកម្ពុជា និងសេដ្ឋកិច្ចរបស់ខ្លួន? តើអ្វីជាការសង្ឃឹមទុក និងការជំរុញលើកទឹកចិត្តដល់កម្ពុជា ពីការធ្វើសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាននេះ? អ្វីជាការព្រួយបារម្ភចំពោះកសិករទាំងបុរស និងស្ត្រីពីសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន?

**កិច្ចការទី២៖ ការពិនិត្យលើឯកសារចង្អុលទិសនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា៖** តើអ្វីជាចំណុចខ្លាំង និងចំណុចខ្សោយ នៃក្របខណ្ឌគោលនយោបាយកម្ពុជា ក្នុងការគាំទ្រគ្រួសារកសិករខ្នាតតូច?
កិច្ចការទាំងនេះរួមបញ្ចូល៖ តើអ្វីជាគោលនយោបាយដែលមានស្រាប់ ដើម្បីគាំទ្រដល់គ្រួសារកសិករខ្នាតតូច ត្រៀមខ្លួនក្នុងសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន? តើគោលនយោបាយដែលមានស្រាប់នោះ បានពិចារណាលើបញ្ហាយេនឌ័រក្នុងដំណើរសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ានដែរឬទេ? តើអ្វីជាការរំពឹងចង់បានរបស់វិស័យកសិកម្មកម្ពុជា និងសេដ្ឋកិច្ចរបស់ខ្លួន បើយោងលើសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន?

**កិច្ចការទី៣៖ ការពិនិត្យមើលលើអត្ថបទសិក្សាផ្សេងៗ ឯកសាររដ្ឋាភិបាល និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ពីតួនាទីរបស់គ្រួសារកសិករខ្នាតតូច ក្នុងវិស័យកសិកម្មកម្ពុជា៖** តើអ្វីជាការចូលរួមវិភាគទាន របស់គ្រួសារកសិករខ្នាតតូចក្នុងវិស័យកសិកម្ម ដោយផ្តោតជាសំខាន់លើតួនាទីយេនឌ័ររបស់បុរស និងស្ត្រីនៅក្នុងកសិកម្មកម្ពុជា?
កិច្ចការនេះរួមបញ្ចូលនូវ៖ តើមានអ្វីខ្លះជាការផ្លាស់ប្តូរក្នុងតួនាទី របស់គ្រួសារកសិករតូចតាច ប្រៀបធៀបនឹងរយៈពេល៥ឆ្នាំមុន? តើនាពេលបច្ចុប្បន្ន កសិកម្មកម្ពុជាស្ថិតក្នុងស្ថានភាពបែបណា បើសំដៅលើបច្ចេកវិទ្យា ផលិតកម្ម និងទីផ្សារ ដោយរួមបញ្ចូលនូវសហគមន៍កសិកម្ម និងការគាំទ្រផ្នែកគោលនយោបាយ? តើកសិករជាបុរស និងស្ត្រីបានចូលរួមចំណែកអ្វីខ្លះចំពោះកសិកម្មកម្ពុជា?

**កិច្ចការទី៤៖ ការសម្ភាសកសិករគោលដៅ សម្រាប់ករណីសិក្សា លើបញ្ហាប្រឈម ឱកាស និងតម្រូវការផ្នែកសមត្ថភាព៖**

ក) តើអ្វីជាបញ្ហាប្រឈម និងឱកាសសម្រាប់គ្រួសារកសិករខ្នាតតូច ពិសេសកសិករជាស្ត្រី ឆ្ពោះទៅសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន? កិច្ចការទាំងនេះរួមបញ្ចូលនូវៈ តើគ្រួសារកសិករខ្នាតតូចបានយល់ដឹងអ្វីខ្លះ ពីសហគមន៍សេដ្ឋកិច្ចអាស៊ាន? តើគ្រួសារកសិករតូចតាចបានធ្វើអ្វីខ្លះហើយ ហើយគប្បីធ្វើអ្វីខ្លះទៀត ដើម្បីបន្សុាំខ្លួន/ទទួលយកសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន? តើអ្វីជាបញ្ហាប្រឈម និងកាលានុវត្តភាពផ្សេងគ្នា ចំពោះកសិករជាបុរស និងស្ត្រីដែលនឹងផ្តល់ដោយសហគមន៍ សេដ្ឋកិច្ចអាស៊ាន?
ខ) តើសមត្ថភាពអ្វីខ្លះដែលចាំបាច់សម្រាប់គ្រួសារកសិករខ្នាតតូច ដើម្បីត្រៀមខ្លួនសម្រាប់ការប្រកួតប្រជែងទីផ្សារ? កិច្ចការទាំងនេះ រួមបញ្ចូលនូវៈ តើអ្វីជាជំហរនៃវិស័យកសិកម្មនាពេលបច្ចុប្បន្ន ដែលបានចូលរួមចំណែកក្នុងសេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់ និងនិន្នាការនៃវិស័យកសិកម្ម ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ? តើអ្វីជាស្ថានភាពកសិកម្មគ្រួសារ ដោយពិចារណាលើបច្ចេកទេសផលិតកម្ម និងមធ្យោបាយប្រើប្រាស់ផ្សេងៗ ហិរញ្ញប្បទាន ទីផ្សារ ដោយរួមបញ្ចូលទាំងសហគមន៍កសិកម្មផងនោះ? តើអ្វីជាភាពខុសគ្នា លើតម្រូវការផ្នែកសមត្ថភាពរវាងកសិករជាបុរស និងកសិករជាស្ត្រី ដើម្បីទទួលបានអត្ថប្រយោជន៍ពីសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន?

ដើម្បីអនុវត្តកិច្ចការនេះ ការសិក្សាបានជ្រើសយកករណីសិក្សាចំនួន៣ ចេញពីស្រុកចំនួន៣ ក្នុងខេត្តចំនួន៣ រួមមានៈ ខេត្តកំពតដែលតំណាងឲ្យកសិកម្មតំបន់ទំនាប ខេត្តកំពង់ធំដែលតំណាងឲ្យកសិកម្មតំបន់ខ្ពង់រាប និងខេត្តរតនគីរីដែលតំណាងឲ្យកសិកម្មតំបន់ភ្នំ។ គ្រួសារចំនួន៥០ ក្នុងខេត្តគោលដៅនីមួយៗត្រូវបានធ្វើបទសម្ភាសន៍ (ជាសរុប មានគ្រួសារចំនួន១៥០ មកពីខេត្តចំនួន៣)។

**ការងារទី៥ៈ ការប៉ាន់ប្រមាណពីអាទិភាពនយោបាយ និងការផ្តល់អនុសាសន៍ៈ** តើអ្វីជាអាទិភាពគោលនយោបាយ និងអនុសាសន៍ ដើម្បីគាំទ្រគ្រួសារកសិករខ្នាតតូច ឆ្ពោះទៅសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន?
ឆ្លុះបញ្ចាំងទៅនឹងការទទួលយក សហគមន៍សេដ្ឋកិច្ចអាស៊ាន បម្លាស់ប្តូរក្នុងតួនាទីកសិកម្ម បញ្ហាប្រឈម និងកាលានុវត្តភាព តើគោលនយោបាយអ្វីដែលចាំបាច់ដើម្បីគាំទ្រគ្រួសារកសិករខ្នាតតូច? តើគោលនយោបាយអ្វីដែលចាំបាច់ ដើម្បីធ្វើការបែងចែកនូវអត្ថប្រយោជន៍ និងបន្ទុកឲ្យបានស្មើភាពគ្នា សម្រាប់គ្រួសារកសិករជាបុរស និងស្ត្រី ដើម្បីដោះស្រាយទៅនឹងសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន?

**ទំហំ និងដែនកំណត់៖ ការឆ្លុះបញ្ចាំងបែបវិធីសាស្ត្រ**
នេះ គឺជាការសិក្សាពីគោលនយោបាយកសិកម្ម។ ការពិនិត្យមើលឯកសារគោលនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ាន និងគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា គឺជាធាតុសំខាន់នៃការសិក្សានេះ។ ក្នុងការឆ្លុះបញ្ចាំងរវាងគោលនយោបាយ និងភាពជាក់ស្តែងនៅកម្រិតសហគមន៍ ករណីសិក្សាត្រូវបានជ្រើសយក។ ការសិក្សាបានជ្រើសយកករណីសិក្សាចំនួន ៣ ដែលតំណាងឲ្យការធ្វើកសិកម្មក្នុងតំបន់ទាំង ៣ ៖ កសិកម្មតំបន់ទំនាប (ខេត្តកំពត) កសិកម្មតំបន់ខ្ពង់រាប (កំពង់ធំ) និងកសិកម្មតំបន់ភ្នំ (ខេត្តរតនគីរី)។ ទោះយ៉ាងនេះក្តី ករណីសិក្សានៅតំបន់ទាំងបីនេះ មិនអាចគ្របដណ្តប់ប្រភេទនៃប្រព័ន្ធកសិកម្មកម្ពុជាបាននៅឡើយទេ។ បន្ថែមលើសនេះ ករណីសិក្សាទាំងនេះ ក៏នៅមិនទាន់ធ្វើឡើងគ្រប់ជ្រុងជ្រោយជារួម ចំពោះលទ្ធភាពដែលអាចកើតមានទាំងឡាយ នៅកម្រិតសហគមន៍នៅឡើយ។ ក្រុមការងារយើងខ្ញុំ សូមស្វាគមន៍នូវរាល់ការចូលរួមវិភាគទានផ្សេងៗ របស់ដៃគូលើព័ត៌មាន ដើម្បីបំពេញបន្ថែមការវិភាគនូវបញ្ហាដែលកំពុងវិវឌ្ឍន៍ទាំងឡាយ។

## III. ក្របខណ្ឌគោលនយោបាយគាំទ្រគ្រួសារកសិករខ្នាតតូច

### *3.1. ក្របខណ្ឌគោលនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងការគាំទ្រគ្រួសារកសិករខ្នាតតូច*

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា អាស៊ាន) បានផ្តើមបង្កើតទីផ្សាររួមមួយ និងមូលដ្ឋានផលិតកម្មដែលហៅថា"សហគមន៍សេដ្ឋកិច្ចអាស៊ាន" ដែលនឹងអនុញ្ញាតិឲ្យមាននូវលំហូរទំនិញ សេវាកម្ម ការវិនិយោគ ពលកម្មជំនាញ និងចលនាមូលធនដោយសេរី ក្នុងតំបន់ទាំងមូល។ អាស៊ានបានកំណត់ខ្លួនឯងជាមូលដ្ឋាន នៃផលិតកម្មសំខាន់បំផុតរបស់ពិភពលោក និងបានផ្តល់នូវភាពជាសាច់ញាតិថ្នាក់តំបន់ សម្រាប់ទីផ្សារស្បៀងអាហារធំជាងគេបង្អស់របស់ពិភពលោកទាំងពីរ គឺឥណ្ឌា និងចិន ដោយបានគូសបញ្ជាក់ថា ខ្លួននៅមានសក្តានុពលជាច្រើន សម្រាប់ការលូតលាស់នៃវិស័យកសិកម្ម នៅក្នុងអាស៊ាន(Invest in ASEAN, 2016)។ ការលូតលាស់នូវវិស័យកសិកម្ម ត្រូវបានគេមើលឃើញថា បានកើតមានឡើងតាមរយៈការជំរុញឲ្យមាននូវការតភ្ជាប់ និងហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរជាងមុន ដែលជាលទ្ធផលនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន។

ដំណាលគ្នានេះ កសិកម្មលក្ខណៈគ្រួសារ គឺជាទម្រង់មួយសំខាន់របស់កសិកម្មក្នុងតំបន់នេះ។ ហេតុនេះ ក្នុងគោលបំណងឈ្វេងយល់ពីសហគមន៍សេដ្ឋកិច្ចអាស៊ានក្នុងបរិបទកសិកម្មវាមានសារសំខាន់ ដើម្បីគូសបញ្ជាក់ថាតើ ការធ្វើសមាហរណកម្មបែបនេះ មានឥទ្ធិពលអ្វីចំពោះគ្រួសារកសិករខ្នាតតូច។ ដើម្បីកំណត់ និងពិភាក្សាពីចំណុចខ្លាំង និងចំណុចខ្សោយក្នុងក្របខណ្ឌគតិយុត្ត និងគោលនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ាន ដោយផ្សារភ្ជាប់ទៅនឹងគ្រួសារកសិករខ្នាតតូចនៅកម្ពុជា យើងនឹងធ្វើការពិនិត្យលើឯកសារគោលនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ានចំនួន២ គឺឯកសារចង្អុលទិសសហគមន៍ សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥។

## កសិកម្មលក្ខណៈគ្រួសារនៅកម្ពុជា

វិស័យកសិកម្ម នៅតែជាឆ្អឹងខ្នងរបស់សេដ្ឋកិច្ចកម្ពុជា ដែលបានរួមចំណែកប្រមាណ ៣៥.៦% នៃផលទុនសរុបជាតិ (Worldbank, 2015)។ គ្រួសារកសិករមានដីកសិកម្មជាមធ្យមប្រមាណ១.៥ហិកតាក្នុង១គ្រួសារ នៅឆ្នាំ២០១១(USAID,2011) ដែលធ្វើឲ្យកសិកម្មលក្ខណៈគ្រួសារ បានគ្របដណ្តប់ទម្រង់កសិកម្មនៅកម្ពុជា។ ប្រភេទសំខាន់ចំនួន២ នៃប្រព័ន្ធដាំដុះនៅកម្ពុជាគឺ ប្រព័ន្ធដំណាំស្រូវដែលពឹងអាស្រ័យលើទឹកភ្លៀង និងប្រព័ន្ធមិនមែនដំណាំស្រូវ(ចម្ការ) ដែលរួមបញ្ចូលការដាំដុះដំណាំចម្រុះ នៅតាមដងទន្លេ កសិកម្មពនេចរ និងប្រព័ន្ធដាំដុះដំណាំអចិន្ត្រៃយ៍ នៅតំបន់ភ្នំ (Diepart, 2015)។ ក្នុងចំណោមរដ្ឋជាសមាជិកអាស៊ានទាំងអស់ កម្ពុជាស្ថិតក្នុងលំដាប់ថ្នាក់ខ្ពស់ជាងគេបំផុត ដែលមានប្រជាជនប្រមាណ៨0% រស់នៅជនបទ (International Labour Office, and ASIAN Development Bank, 2015)។ អត្រានៃភាពក្រីក្រនៅជនបទបានធ្លាក់មកនៅត្រឹម ២០.៨% នៅឆ្នាំ២០១២ ដែលចំនួននេះ ស្ថិតនៅក្នុងចំនួន ៣ដង ខ្ពស់ជាងអត្រានៃភាពក្រីក្រនៅតំបន់ទីក្រុង។ បើទោះបីភាពក្រីក្រ ត្រូវបានកាត់បន្ថយច្រើនទាំងនៅតំបន់ជនបទ និងទីក្រុងក្នុងទសវត្សចុងក្រោយនេះក៏ដោយ ក៏ប្រជាជនកម្ពុជាភាគច្រើនដែលជាជនក្រីក្របានរស់នៅតំបន់ជនបទ(International Labour Office, and ASIAN Development Bank, 2015)។ ប្រជាជនកម្ពុជាជាច្រើន ដែលតាំងទីលំនៅនៅតំបន់ជនបទ មានប្រវត្តិជាកសិករខ្នាតតូច ដែលដាំដំណាំ និងពឹងអាស្រ័យលើព្រៃឈើក្នុងទ្រង់ទ្រាយតូច។

នៅឆ្នាំ២០១០ ការចូលរួមចំណែកក្នុងការផ្តល់ការងារតាមរយៈ វិស័យកសិកម្មនៅកម្ពុជា ត្រូវបានវាស់វែងក្នុងចំនួន ៥៥%នៃប្រជាជនសរុបរបស់ខ្លួន។ នៅឆ្នាំ ២០២៥ ចំនួននេះ ត្រូវបានគេរំពឹងទុកថា នឹងបន្តធ្លាក់ចុះមកត្រឹម៥០% ហើយនៅពេលដែលគេគិតពីផលប៉ះពាល់ ដោយសហគមន៍សេដ្ឋកិច្ចអាស៊ាន វានឹងបង្កឲ្យមានការធ្លាក់ចុះចំនួន ១.៧% បន្ថែមទៀត (ILO Regional Office for ASIA & the Pacific, and Asian Development Bank, 2014)។ ដំណាលគ្នានេះផងដែរ យើងក៏បានមើលឃើញច្បាស់នូវកំណើន នៃការផ្តល់ការងារក្នុងវិស័យឧស្សាហកម្មផងដែរ។ បើទោះណាការផ្តល់ការងារតាម រយៈវិស័យកសិកម្ម ទំនងជាមានការថមថយក៏ដោយ ក៏នៅមានការមន្ទិលសង្ស័យតិចតួចដែរថា វិស័យកសិកម្មនឹងនៅតែបន្តដើរតួនាទីធំលើសលប់នៅកម្ពុជា នៅប៉ុន្មានឆ្នាំខាងមុខនេះបន្តទៀត (ILO Regional Office for ASIA & the Pacific, and Asian Development Bank, 2014)។

## ដំណើរឆ្ពោះទៅមុខ ជាមួយសហគមន៍សេដ្ឋកិច្ចអាស៊ាន

ដោយបានដាក់ឲ្យប្រើប្រាស់នៅឆ្នាំ២០០៧ ឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ ត្រូវបានរៀបចំឡើង ដោយផ្អែកលើអន្តរសរសរស្តម្ភចំនួន៤។ ទាំងនោះ រួមមាន៖ ទី១) ទីផ្សាររួមមួយ និងមូលដ្ឋានផលិតកម្ម ទី២) តំបន់សេដ្ឋកិច្ចដែលមានការប្រកួតប្រជែង ទី៣) ការអភិវឌ្ឍសេដ្ឋកិច្ចបែបសមធម៌ និងទី៤) ការធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចតំបន់។ ខណៈដែលលទ្ធផលសម្រេចបានជាសារវន្ត រួមមាន ការលុបចោលនូវពន្ធរវាងរដ្ឋជាសមាជិក ការរំដោះបាននូវទីផ្សារ និងតម្លាភាពផ្នែកសេដ្ឋកិច្ច ក៏នៅមានគោលដៅជាច្រើនទៀត នៅមិនទាន់សម្រេចបាននៅឡើយ (ASEAN Secretariat, 2015a, 10-12)។

ឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ាន២០១៥ ត្រូវបានបង្កើតបន្តក្នុងឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០២៥ ដែលត្រូវដាក់ចេញឲ្យប្រើប្រាស់នៅឆ្នាំ២០១៥។ ចំណុចផ្តោតជាសំខាន់ នៃការរៀបចំឯកសារនេះឡើងវិញ គឺដើម្បីធ្វើឲ្យប្រាកដច្បាស់ នូវក្របខណ្ឌដែលបានបង្កើតឡើងពីមុន និងដើម្បីពង្រឹង និងអភិវឌ្ឍន៍នូវអត្តសញ្ញាណរួមនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ជាមួយនឹងគោលបំណងនៅក្នុងការបង្កើត នូវឯកសណ្ឋានសេដ្ឋកិច្ចបែបនិរន្តរភាព និងប្រកបដោយភាពធន់ ឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ ផ្តោតការយកចិត្តទុកដាក់ច្រើនជាងមុន ទៅលើការសម្របសម្រួលអាជីវកម្ម ជាគន្លឹះមួយដើម្បីលើកកម្ពស់ភាព

អាចប្រកួតប្រជែងបាន និងពង្រឹងដល់សមាហរណកម្មសេដ្ឋកិច្ច (ASEAN Secretariat, 2015b, 26)។

## ការភ្ជាប់នូវទស្សនវិស័យសហគមន៍សេដ្ឋកិច្ចអាស៊ាន ជាមួយកសិករខ្នាតតូចកម្ពុជា

ដោយបានបង្ហាញ នូវព័ត៌មានប្រជាសាស្ត្ររបស់ប្រទេសកម្ពុជា ដែលជាងពាក់កណ្តាលនៃប្រជាពលរដ្ឋសរុប ចូលរួមក្នុងការងារកសិកម្មលក្ខណៈទ្រង់ទ្រាយតូច ឥឡូវនេះ យើងសូមបង្វែរនូវសំណួរថាតើ ក្របខណ្ឌគោលនយោបាយសហគមន៍សេដ្ឋកិច្ចអាស៊ាន គាំទ្រដល់គ្រួសារកសិករខ្នាតតូចយ៉ាងដូចម្តេច។

នៅក្នុងផ្នែកស្តីអំពីការអភិវឌ្ឍសេដ្ឋកិច្ចបែបនិរន្តរភាព ក្នុងឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ច អាស៊ានឆ្នាំ២០២៥ មានការផ្តោតចិត្តទុកដាក់យ៉ាងច្បាស់លាស់ស្តីអំពី ការលើកកម្ពស់បរិស្ថានបែបនិរន្តរភាពសម្រាប់កសិកម្ម។ ជាអាទិ៍ ឯកសារចង្អុលទិស បានកត់សម្គាល់នូវតម្រូវការដើម្បី "លើកកម្ពស់ការអនុវត្តកសិកម្មល្អ ដើម្បីកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមាន ទៅលើធនធានធម្មជាតិ ដូចជាដីព្រៃឈើនិងទឹក និងដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់"(ASEAN Secretariat, 2015b,20)។ បន្ថែមលើសនេះ ឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០២៥ បានសង្កត់ធ្ងន់លើការគ្រប់គ្រងព្រៃឈើ ដែលមានទំនាក់ទំនងទៅនឹងសហគមន៍ដែលពឹងអាស្រ័យលើធនធានព្រៃឈើ សម្រាប់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ (ASEAN Secretariat, 2015b, 20)។

បើទោះបីជា ឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ាន បានគូសបញ្ជាក់នូវកិច្ចការសំខាន់ៗ ដែលបានលើកឡើងខាងលើ សម្រាប់កិច្ចអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពយ៉ាងណាក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួន នៅក្នុងក្របខណ្ឌគតិយុត ចំពោះការកាន់កាប់ដីធ្លី ដែលត្រូវតែគូសបញ្ជាក់។ ទី១) វាបានបង្ហាញថា ប្រព័ន្ធកាន់កាប់ដីធ្លី ត្រូវតែមានតម្លាភាពច្រើនជាងមុន នៅក្នុងតំបន់ ដើម្បីជៀសវាង នូវជម្លោះដីធ្លីកើតឡើងញឹកញាប់ និងដើម្បីធានានូវសិទ្ធិរបស់គ្រួសារកសិករខ្នាតតូច ចំពោះធនធានផលិតកម្ម ដូចជា ដីធ្លី ដើម្បីបង្កើតនូវវេទិកា សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព (International Labour Office, and ASIAN Development Bank, 2015)។ ការធ្វើឲ្យប្រសើរឡើងនូវការរៀបចំ ចំពោះការកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព នឹងសម្របសម្រួលឲ្យមាននូវការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច

សម្រាប់គ្រួសារកសិករខ្នាតតូច ដើម្បីវិនិយោគលើដីធ្លីរបស់ពួកគាត់ ដែននឹងរំពឹងថាផ្ដល់នូវផលិតភាពប្រសើរជាងមុន (Bank, 2015, 87) ។ ទី២) មេរៀនសំខាន់ដែលបានរៀនសូត្រពីវិបត្តិស្បៀងអាហារឆ្នាំ២០០៨ និងឆ្នាំ២០០៩ គឺថា ការរំដោះចេញនូវវិបត្តិសេដ្ឋកិច្ចអាចមានឥទ្ធិពលអវិជ្ជមានទៅលើសន្តិសុខស្បៀងរបស់គ្រួសារកសិករខ្នាតតូចជាពិសេស នៅពេលអវត្តមាននូវយន្តការការពារសង្គម។ បញ្ហាចំពោះការរំដោះចេញនូវវិបត្តិសេដ្ឋកិច្ច សម្រាប់ប្រទេសទាំងឡាយ ដែលភាគច្រើន ពឹងអាស្រ័យលើកសិកម្មជាលក្ខណៈគ្រួសារមិនមានសមត្ថភាព ដើម្បីសម្រេចបាននូវទំហំសេដ្ឋកិច្ចកង្វះលទ្ធភាពទទួលបានបច្ចេកវិទ្យាថ្មី និងការការពារនូវហានិភ័យ (Thapa and Gaiha, 2011)។ យោងតាមសន្ទស្សន៍សន្តិសុខស្បៀងសាកលឆ្នាំ២០១៥ កម្ពុជា គឺជាប្រទេសដែលមានសន្តិសុខស្បៀងល្អបំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក(The Economist Intelligence Unit, 2015, 26)។

ចំពោះសន្តិសុខស្បៀង សហគមន៍សេដ្ឋកិច្ចអាស៊ាន មានវិស័យពិសេសមួយដែលហៅថា "កិច្ចសហប្រតិបត្តិការអាស៊ាន ស្តីពីស្បៀងអាហារ កសិកម្ម និងព្រៃឈើ" ដែលស្វែងរកការធានានូវសន្តិសុខស្បៀង ការអនុវត្តបច្ចេកវិទ្យាកសិកម្មបៃតង និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ កិច្ចសហប្រតិបត្តិការអាស៊ាន ស្តីពីស្បៀងអាហារ កសិកម្ម និងព្រៃឈើ ក៏ផ្តោតការយកចិត្តទុកដាក់ទៅលើការជួយគាំទ្រដល់អ្នកផលិតខ្នាតតូចដែលជួបបញ្ហាកង្វះធនធាន និងសហគ្រាសខ្នាតតូច និងមធ្យម ដើម្បីបង្កើននូវផលិតភាព បច្ចេកវិទ្យា និងគុណភាពផលិតផល ដើម្បីបំពេញបានស្តង់ដារទីផ្សារសាកល និងបង្កើននូវភាពអាចប្រកួតប្រជែងបាន (ASEAN Economic Community Department and ASEAN Secretariat , 2015, 56)។ ដូចនេះ នៅលើឯកសារ កិច្ចសហប្រតិបត្តិការអាស៊ាន ស្តីពីស្បៀងអាហារ កសិកម្ម និងព្រៃឈើ បានច្របាច់បញ្ចូលគ្នានូវយុទ្ធសាស្ត្រជាច្រើន ដើម្បីធានាឲ្យបាននូវសន្តិសុខស្បៀង ដើម្បីគាំទ្រដល់កិច្ចអភិវឌ្ឍការអនុវត្តកសិកម្មរបស់គ្រួសារកសិករខ្នាតតូចកម្ពុជា។ ទោះយ៉ាងណាក្តី ការអនុវត្តយុទ្ធសាស្ត្រទាំងនេះ សម្រាប់គ្រួសារកសិករខ្នាតតូចជាច្រើន នៅក្នុងតំបន់ជនបទ ស្ថិតនៅជាបញ្ហាប្រឈមសម្រាប់រដ្ឋាភិបាលកម្ពុជានៅឡើយ ដោយសារតែសមត្ថភាពផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសនៅមានកម្រិត(FAO, 2014, 5)។

សេចក្តីត្រូវការ ដើម្បីធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និងភាពសក្តិសិទ្ធនៅក្នុងវិស័យកសិកម្មកម្ពុជា គឺជាភស្តុតាងស្រាប់។ ផលិតផលកសិកម្មអាចមាន

លក្ខណៈសំពីងសំពោងហើយជារឿយៗ អាចមានការស្អុយរលួយ ដែលទាមទារនូវតម្រូវការឡូជីស្ទីកពិសេសដែលមានតម្លៃខ្ពស់។ ពាណិជ្ជកម្មសេរីជាងមុន អាចចូលរួមចំណែកធ្វើឲ្យតម្លៃស្បៀងអាហារធ្លាក់ចុះ និងបង្កើនលទ្ធភាពទទួលបានស្បៀង នៅទូទាំងតំបន់សហគមន៍សេដ្ឋកិច្ចអាស៊ាន ប៉ុន្តែភាពមិនមានប្រសិទ្ធភាពដែលបង្កឡើងដោយការចំណាយលើការដឹកជញ្ជូនខ្ពស់ ផ្តល់ផលប៉ះពាល់ទៅដល់ដំណើរការនៃការទទួលបានអត្ថប្រយោជន៍ទាំងអស់នេះ ( Caballero - Anthony, 2013, 2 ) ។ អាស្រ័យដោយហេតុផលទាំងនេះ សេដ្ឋកិច្ចកម្ពុជា នៅមិនទាន់ទទួលបានផលប្រយោជន៍ពេញលេញនៅឡើយ ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ (International Labour Office, and ASIAN Development Bank, 2015)។

ឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០២៥ បានទទួលស្គាល់នូវរនាំងទាំងនេះ តាមរយៈការកំណត់នូវតម្រូវការ ដើម្បីធ្វើឲ្យប្រសើរឡើងនូវតំណភ្ជាប់ និងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ផ្លូវដែក សម្រាប់ការដឹកជញ្ជូនទំនិញ។ នេះនឹងជួយដល់កសិករខ្នាតតូច នូវលទ្ធភាពទទួលបានការដឹកជញ្ជូនផលិតផលរបស់ពួកគេបានល្អប្រសើរជាងមុន និងជួយពួកគេក្នុងការបង្កើននូវផលិតកម្មរបស់ពួកគេ ដោយសារតែការចំណាយលើការដឹកជញ្ជូនទាប (ILO Regional Office for ASIA & the Pacific, and Asian Development Bank, 2014)។

ដំណាលគ្នានេះផងដែរ "គ្រួសារកសិករខ្នាតតូច" ស្ថិតនៅក្នុងប្រភេទ និងការចិញ្ចឹមជីវិតផ្សេងៗគ្នា ហើយភាពងាយរងគ្រោះ មានលក្ខណៈខុសប្លែកគ្នាយ៉ាងច្បាស់នៅតាមបន្ទាត់យេនឌ័រ។ ការសិក្សាមួយ ដែលរៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ីនៅឆ្នាំ២០១២ បានបង្ហាញថា គម្លាតយេនឌ័រនៅក្នុងវិស័យកសិកម្មនៅកម្ពុជា ដែលក្នុងនោះស្ត្រីក្នុងវិស័យកសិកម្ម អាចរកចំណូលមធ្យមប្រចាំខែបានតិចជាងបុរស (ADB, 2015, 19-21)។ នេះអាចផ្សារភ្ជាប់ទៅនឹងភាពជាក់ស្តែងដែលថា ស្ត្រីត្រូវបានគេកត់សម្គាល់ថា បានចំណាយពេលប្រចាំថ្ងៃចំនួន៣ម៉ោងកន្លះបន្ថែម ទៅលើការងារដែលមិនមានប្រាក់កម្រៃក្នុងគ្រួសារ ពោលគឺច្រើនជាងដៃគូជាបុរសរបស់ពួកគាត់។ បន្ថែមលើសនេះ ចំពោះបញ្ហានៃលទ្ធភាពទទួលបានដីធ្លី បច្ចេកវិទ្យា និងសេវាហិរញ្ញវត្ថុ ច្បាស់ណាស់ថា បុរសមានភាពរីករាយ ក្នុងលក្ខខណ្ឌមួយដែលទទួលបានអត្ថប្រយោជន៍ច្រើនជាងស្ត្រី នៅកម្ពុជា (ADB, 2015, 19-21)។

នៅក្នុងឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥ បញ្ហាវិសមភាពយេនឌ័រមិនបានលើកយកមកនិយាយទេ។ ដំណាលគ្នានេះ ក្នុងឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ បញ្ហាពាក់ព័ន្ធយេនឌ័រមួយចំនួនត្រូវបានលើកឡើង ប៉ុន្តែស្ថិតក្នុងកម្រិតកំណត់មួយនៅឡើយ។ នៅក្នុងផ្នែកស្តីពី "វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា" វាបានបង្ហាញថា ភាពជាសហគ្រិនគួរត្រូវបានជំរុញ តាមរយៈការបង្កើតឡើងនូវ " ប្រព័ន្ធ និងយន្តការដែលនឹងជួយបង្កើនការចូលរួមពាក់ព័ន្ធរបស់ស្ត្រី...... " (ASEAN Secretariat, 2015b, 20)។ ទោះយ៉ាងណាក្តី វាមិនបានបង្ហាញនូវការរំពឹងទុកវិស័យយេនឌ័រដែលមានការអភិវឌ្ឍ ជាសំខាន់នៅក្នុងក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន សម្រាប់ កសិកម្មលក្ខណៈគ្រួសារឡើយ។ វិធានការដាក់លាក់បន្ថែមទៀតមានភាពចាំបាច់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាសំខាន់នេះ។

ភាពផ្សេងគ្នាលើផ្នែកសេដ្ឋកិច្ច ក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន មានលក្ខណៈខុសគ្នា។ ប្រាក់ខែជាមធ្យមនៅប្រទេសថៃមានចំនួន៣ដង ច្រើនជាងកម្ពុជា។ ជាលទ្ធផល កសិករក្នុងចំនួនដ៏ច្រើនពីប្រទេសកម្ពុជា បានធ្វើចំណាកស្រុកទៅកាន់ប្រទេសថៃ ដើម្បីធ្វើការងារកសិកម្ម។ ធនាគារពិភពលោក បានប៉ាន់ប្រមាណថាបច្ចុប្បន្ន មានប្រជាជនកម្ពុជាប្រមាណ៧៥០.០០០នាក់ បានកំពុងរស់នៅក្នុងប្រទេសថៃ (International Labour Office, and ASIAN Development Bank, 2015) ។

ការដោះដូរផ្នែកសេដ្ឋកិច្ចដែលកំពុងកើនឡើង ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានបាននឹងកំពុងអមដំណើរដោយចំរឹងស្រួច ក្នុងលំហូរអន្តោប្រវេសន៍អន្តរតំបន់ ក្នុងតំបន់អាស៊ាន (ILO Regional Office for ASIA & the Pacific, and Asian Development Bank, 2014)។ លំហូរអន្តោប្រវេសន៍នេះ ទំនងជានឹងបន្តកើនឡើង ដោយសារកត្តាជំរុញទីផ្សារជាចម្បង និងឆ្លុះបញ្ចាំងពីភាពខុសគ្នានៃប្រាក់ចំណូលក្នុងចំណោមប្រទេសនៅក្នុងតំបន់ (Asian Development Bank, 2015b, 8)។

នាពេលបច្ចុប្បន្ន ក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន គិតគូរតែអំពីអន្តោប្រវេសន៍នៃក្រុមពលកម្មជំនាញខ្ពស់ ដូចជា វេជ្ជបណ្ឌិត វិស្វករ និងស្ថាបត្យករ ។ល។ ប៉ុណ្ណោះ។ ដោយឡែក កម្មករពាក់កណ្តាលជំនាញ និងកម្មករដែលមានជំនាញទាបជាអាទិ៍អ្នកដែលធ្វើការងារក្នុងវិស័យកសិកម្ម នេសាទ កម្មករក្នុងស្រុក និងកម្មករសំណង់ មិនត្រូវបានរាប់បញ្ចូលនៅក្នុងក្របខណ្ឌសហគមន៍ សេដ្ឋកិច្ចអាស៊ានទេ។

ទោះយ៉ាងណាក្តី លំហូរអន្តោប្រវេសន៍ការងារនាពេលបច្ចុប្បន្ន នៅក្នុងប្រទេសជាសមាជិកអាស៊ានទាំងអស់ គឺសំបូរទៅដោយក្រុមពលកម្មដែលមានជំនាញ ទាបទាំងនេះច្រើនណាស់ បូករួមទាំងគ្រួសារកសិករខ្នាតតូចក្នុងចំណោកមួយធំផងដែរ (Asian Development Bank, 2015b, 8) ។ ដូច្នេះ ក្រុមងាយរងគ្រោះទាំងនេះ ខ្វះនូវលទ្ធភាពទទួលបានទម្រង់ នៃកិច្ចការពារសង្គមណាមួយរបស់រដ្ឋាភិបាល និងក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន (ILO Regional Office for ASIA & the Pacific, and Asian Development Bank, 2014)។

ភាពមិនស្របគ្នា ដោយអន្លើរវាងកង្វះក្របខណ្ឌសហគមន៍ សេដ្ឋកិច្ចអាស៊ានសម្រាប់កម្មករចំណាកស្រុកដែលមានជំនាញទាប និងភាពពិតជាក់ស្តែងក្នុងកម្រិតខ្ពស់នៃអន្តោប្រវេសន៍កម្លាំងពលកម្ម ដែលមានជំនាញទាបនៅក្នុងតំបន់ បានគូសបញ្ជាក់នូវ គម្លាតជាសំខាន់ក្នុងក្របខណ្ឌគោលនយោបាយ សហគមន៍សេដ្ឋកិច្ចអាស៊ាន។ ដើម្បីធានាបាននូវស្តង់ដារពលកម្មសមស្រប ដែលផ្តល់នូវកិច្ចការពារ និងឱកាសដល់កម្មករចំណាកស្រុក កិច្ចអន្តរាគមន៍ផ្នែកគោលនយោបាយពីសហគមន៍សេដ្ឋកិច្ចអាស៊ាន មានភាពចាំបាច់បំផុត (ILO Regional Office for ASIA & the Pacific, and Asian Development Bank, 2014)។

## *3.2. គោលនយោបាយកម្ពុជាក្នុងការគាំទ្រដល់គ្រួសារកសិករខ្នាតតូច*

ដោយផ្អែកលើបញ្ហា ដែលបានលើកឡើងដោយគ្រួសារកសិករខ្នាតតូច នៅក្នុងវេទិកាកសិករថ្នាក់ជាតិ ឆ្នាំ២០១៥ និងឆ្នាំ២០១៦ បញ្ហាអាទិភាពសម្រាប់គ្រួសារកសិករខ្នាតតូចរួមមាន៖ បច្ចេកទេសកសិកម្ម ប្រព័ន្ធស្រោចស្រព ទុនសម្រាប់ការវិនិយោគ និងការរកទីផ្សារសម្រាប់ផលិតផលរបស់ពួកគាត់។ លើសពីនេះ សន្តិសុខដីធ្លី គឺជាឧបសគ្គចម្បង ដែលលើកឡើងដោយកសិករកម្ពុជា។ ដូច្នេះ ការពិនិត្យមើលឡើងវិញ ផ្នែកគោលនយោបាយ ផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចសំខាន់ទាំង៥ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់គ្រួសារកសិករខ្នាតតូច។

វិស័យកសិកម្ម តំណាងឲ្យសរសរស្តម្ភមួយ ក្នុងចំណោមសរសរស្តម្ភទាំងបួននៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា(ដំណាក់កាលទី៣)។ វិស័យនេះត្រូវបានគេទទួលស្គាល់ថាបានដើរតួនាទីសំខាន់ ក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ចជាពិសេសដល់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ប៉ុន្តែក៏ក្នុងន័យសមធម៌ និងសន្តិសុខ

ស្បៀងផងដែរ (RGC MoP, 2014)។ នេះដើរស្របគ្នាបំផុត ជាមួយនឹងឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥។ ការលើកកម្ពស់វិស័យកសិកម្មក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ្តោតការយកចិត្តទុកដាក់លើការធ្វើទំនើបកម្ម ពិពិធូបនីយកម្ម និងពាណិជ្ជូបនីយកម្ម (RGC MoP, 2014) ។

**ទំនើបភាវូបនីយកម្ម** ត្រូវបានចាត់ទុកជាមធ្យោបាយមួយ ដើម្បីបង្កើនផលិតភាព តាមរយៈការបង្កើនយន្តការ និងការស្រោចស្រព នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ច្បាប់ និងបទប្បញ្ញត្តិមួយចំនួន ត្រូវបានរំពឹងថា នឹងចូលរួមចំណែកដល់ការធ្វើទំនើបកម្ម ជាពិសេស ច្បាប់ ឬបទប្បញ្ញត្តិស្តីពីផលិតកម្មពូជ ការនាំចូលធាតុចូលកសិកម្ម ការធ្វើកសិកម្មតាមកិច្ចសន្យា ការប្រើប្រាស់ដីកសិកម្ម កិច្ចការពារដំណាំ សមាគមអ្នកប្រើប្រាស់ទឹក និងការអភិវឌ្ឍធនធានមនុស្ស ដែលត្រូវបានបង្ហាញថា បានផ្តល់នូវក្របខណ្ឌគាំទ្រសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម (ASSDP, NSDP)។

នៅឆ្នាំ២០១៤ នាយកដ្ឋានកសិកម្ម បានធ្វើពង្រាងគោលនយោបាយពូជស្រូវ និងពូជដំណាំ។ គោលបំណងនៃគោលនយោបាយនេះ គឺដើម្បីធានាថា កសិករអាចមានលទ្ធភាពទទួលបានពូជដំណាំនិងប្រភេទពូជដំណាំផ្សេងៗ ដែលមានគុណភាពល្អយកមកប្រើប្រាស់។ ទំហំនៃគោលនយោបាយពង្រាងនេះ គ្របដណ្តប់នូវរាល់ប្រភេទពូជដំណាំ និងឧបករណ៍កសិកម្ម ហើយវាក៏បានទទួលស្គាល់នូវពូជថ្មីៗ រួមនឹងប្រភេទទាំងឡាយនៃមុខដំណាំ ដោយការចាប់ផ្តើមការបង្កាត់ពូជថ្មី រហូតដល់ការចែកចាយទៅដល់កសិករ។ គោលនយោបាយនេះ មានទិសដៅស្របគ្នាទៅនឹងច្បាប់ស្តីអំពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិរបស់អ្នកផលិតពូជក្នុងឆ្នាំ២០០៨ និងអនុក្រិត្យ ស្តីអំពីការធ្វើកសិកម្មតាមកិច្ចសន្យារួម នឹងគោលនយោបាយនាំអង្ករចេញផងដែរ (RGC, 2011) (RGC, Law on Seed Management and Plant Breeders' Rights, 2008)។ គោលនយោបាយនេះ នឹងផ្តល់ឱកាសដល់កសិករខ្នាតតូច និងអ្នកបង្កាត់ពូជអាចធ្វើការចុះឈ្មោះនូវប្រភេទពូជដំណាំថ្មី ដែលពួកគេបានបង្កើតឡើង។ ក្នុងពេលជាមួយគ្នានេះផងដែរ នាយកដ្ឋានកសិកម្ម បានធ្វើពង្រាងគោលនយោបាយមួយ ថ្មីបន្ថែមទៀត ស្តីពីស្តង់ដារកសិកម្មសរីរាង្គកម្ពុជា។ គោលនយោបាយនេះ កំពុងស្ថិតក្នុងដំណាក់កាលនៃការប្រឹក្សាយោបល់ ក្នុងចំណោមក្រុមការងារបច្ចេកទេស នៃនាយកដ្ឋានពាក់ព័ន្ធនៅក្នុងអគ្គនាយកដ្ឋាន។ គោលនយោបាយនេះ ផ្តោតការយកចិត្តទុកដាក់ទៅលើគ្រប់ប្រភេទផលិតផលសត្វ និងប្រភេទដំណាំទាំងអស់នៅកម្ពុជា។ វាក៏

ដើរស្របគ្នាទៅនឹងការលើកកម្ពស់ ការអនុវត្តកសិកម្មល្អនៅក្នុងឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ានផងដែរ។

**ពាណិជ្ជូបនីយកម្ម និងពិពិធូបនីយកម្មៈ** គឺជាគោលនយោបាយអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ គោលបំណងនៃពាណិជ្ជូបនីយកម្ម សំខាន់ជួយលើកកម្ពស់ពាណិជ្ជកម្ម និងការនាំចេញផលិតផលកសិកម្ម។ សហគមន៍អភិវឌ្ឍន៍កសិកម្មមានតួនាទីសំខាន់នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ដែលជួយដល់ការបង្កើតបណ្ដាញកសិពាណិជ្ជកម្ម។ ពាណិជ្ជូបនីយកម្មកើនឡើងនេះ ពឹងអាស្រ័យលើការធានាបាននូវសមត្ថភាពកែច្នៃ ប្រព័ន្ធឡូជីស្ទីករឹងមាំ លទ្ធភាពចូលទៅកាន់ទីផ្សារ និងការសម្របសម្រួលដែលល្អប្រសើរជាងមុន និងសាមញ្ញកម្មពាណិជ្ជកម្ម។ លើសពីនេះ ផលវិបាកនៃការយកចិត្តទុកដាក់លើការនាំចេញ គុណភាពនៃផលិតផលគួរឈានដល់ស្តង់ដារអន្តរជាតិ។ ក្រៅពីការតភ្ជាប់រវាងអ្នកផលិត និងអ្នកជំនួញប្រសើរជាងមុន ការធ្វើឲ្យប្រសើរឡើងនូវភាពជាដៃគូរ រវាងកសិឧស្សាហកម្មខ្នាតធំ និងកសិកម្មលក្ខណៈគ្រួសារត្រូវបានចាត់ទុកថា ជាការចូលរួមចំណែកដល់ពាណិជ្ជូបនីយកម្មកសិកម្ម។ វាត្រូវបានគេមើលឃើញថាមានលក្ខណៈស៊ីសង្វាក់គ្នា និងឆ្លុះបញ្ចាំងទៅនឹងទស្សនវិស័យ និងទិសដៅសហគមន៍សេដ្ឋកិច្ចអាស៊ាន ស្តីពីការបង្កើតអង្គភាពសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ដែលកាត់បន្ថយភាពក្រីក្រ និងពង្រឹងការលូតលាស់សេដ្ឋកិច្ចរបស់តំបន់ និងនៅលំដាប់សាកលផងដែរ (ASEAN Secretariat, 2015b, 20)។

ដើម្បីលើកកម្ពស់គ្រួសារកសិករខ្នាតតូច ក្នុងកិច្ចអភិវឌ្ឍកសិកម្ម និងសហគមន៍កសិករ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានបង្កើតច្បាប់មួយស្តីពីសហគមន៍កសិកម្មនៅឆ្នាំ២០១៣ ដើម្បីគាំទ្រ និងគ្រប់គ្រងសហគមន៍កសិកម្មក្នុងប្រទេស (RGC MAFF,2013)។ ច្បាប់នេះ រៀបរាប់យ៉ាងលម្អិតពីភារកិច្ច រចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សហគមន៍កសិកម្មនីមួយៗ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងភ្នាក់ងាររបស់ខ្លួន ដើម្បីគាំទ្រកសិករ។ ក្រោយពីច្បាប់នេះត្រូវបានអនុម័តដោយសភាជាតិ នាយកដ្ឋានសហគមន៍កសិកម្ម ត្រូវបានបង្កើតឡើង នៅក្រោមអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ច្បាប់ស្តីពីសហគមន៍កសិកម្ម មាត្រា១៣៖ ក្រសួងស្ថាប័នរដ្ឋដែលពាក់ព័ន្ធ មានភារកិច្ចជួយគាំទ្រក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ចំពោះរាល់សកម្មភាព និងប្រតិបត្តិការរបស់សហគមន៍កសិកម្មតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

**ពិពិធូបនីយកម្ម** សំដៅឆ្ពោះផលិតផលដែលមានតម្លៃទីផ្សារខ្ពស់ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើដំណាំទីផ្សារ និងប្រភេទដំណាំនាំចេញជាសក្តានុពល (ឧទាហរណ៍៖ កៅស៊ូ ដំឡូងមី ស្ករស គ្រាប់ស្វាយចន្ទី ។ល។) ត្រឹមឆ្នាំ២០១៨ ដែលជាគោលដៅចុងក្រោយ គំនិតផ្តួចផ្តើមនេះត្រូវបានរំពឹងថា កើនឡើងតម្លៃបន្ថែមក្នុង១ហិកតាសម្រាប់គ្រប់ដំណាំទាំងអស់ចំនួន ៥០% ប្រៀបធៀបនឹងឆ្នាំ២០០៧ ដែលជារយៈពេលនៃការកំណត់ទិន្នន័យដើមគ្រា (RGC MoP, 2014)។ ការស្រាវជ្រាវ និងការអភិវឌ្ឍកសិកម្មដើរតួនាទីស្នូល ដើម្បីផ្តល់មិនត្រឹមតែគំនិតផ្តួចផ្តើមនៃបច្ចេកវិទ្យាប៉ុណ្ណោះទេ តែថែមទាំងផ្តល់នូវការឆ្លុះបញ្ចាំង ពីការបន្សាំខ្លួននៃបច្ចេកទេសផ្សេងគ្នា ចំពោះបរិបទក្នុងស្រុក និងម៉ូឌែល ដែលត្រូវបានលើកកម្ពស់ (ASSDP, MAFF)។ ចេញពីការបង្ហាញសំខាន់ៗទាំងនេះ ជាសម្មតិកម្មវានឹងអាចផ្តល់នូវតំណភ្ជាប់ រវាងផលិតផលតម្លៃបន្ថែម ការកើនឡើងនូវប្រាក់ចំណូល និងការកាត់បន្ថយភាពក្រីក្រ។ ទោះយ៉ាងណាក៏ដោយលក្ខខណ្ឌ(ដំបូង) នៃដំណើរជោគជ័យនេះ ពិតជាមិនត្រូវបានពិភាក្សា ឬលើកយកមកពន្យល់ទេ។ ស្របទៅនឹងអាណត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានបង្កើតនូវគោលនយោបាយ និងយុទ្ធសាស្ត្រផ្ទាល់ខ្លួន ដើម្បីគាំទ្រសេចក្តីថ្លែងការ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងរបៀបវារៈតួយ៉ាង គោលនយោបាយនាំចេញអង្ករ សន្តិសុខស្បៀង និងសុវត្ថិភាពស្បៀង និងការកាត់បន្ថយភាពក្រីក្រ (RGC MAFF, 2015)។ ដោយពិចារណាថា កសិកម្មកម្ពុជាគ្របដណ្តប់ ដោយកសិកម្មស្ថិតលើមូលដ្ឋានដំណាំស្រូវ គោលនយោបាយទាំងនេះ នឹងផ្តល់នូវផលប៉ះពាល់ជាវិជ្ជមាន ទៅលើការធ្វើឲ្យប្រសើរឡើងនូវការប្រកបរបរចិញ្ចឹមជីវិតរបស់កសិករដំណាំស្រូវ។

### *គោលនយោបាយស្រពិចស្រពិលនិងផលវិបាក៖គ្រួសារកសិករខ្នាតតូចនិងក្រុមហ៊ុនសម្បទាន*

រាជរដ្ឋាភិបាលកម្ពុជា បានជំរុញការវិនិយោគទ្រង់ទ្រាយធំ លើប្រភេទដំណាំកសិកម្ម និងកសិឧស្សាហកម្មនៅកម្ពុជា តាមរយៈការផ្តល់ដីសម្បទានសេដ្ឋកិច្ច ជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់ខ្លួន ដែលផ្តោតការយកចិត្តទុកដាក់ លើកំណើនសេដ្ឋកិច្ច

ក្នុងវិស័យកសិកម្ម។ នៅឆ្នាំ២០០១ ច្បាប់ភូមិបាលត្រូវបានដាក់ឲ្យប្រើប្រាស់ ហើយលទ្ធភាពក្នុងការជួលដីឯកជនរបស់រដ្ឋ សម្រាប់ការ វិនិយោគទ្រង់ទ្រាយធំ រហូតដល់ទៅ៩៩ឆ្នាំ ត្រូវបានគូសបញ្ជាក់។ ក្រុមហ៊ុនឯកជនមួយ អាចទទួលបានដីជួលរហូតដល់ទៅ១០.០០០ហិកតា ដែលត្រូវបានផ្តល់ជាដីសម្បទាន។ ជាមួយនឹងច្បាប់ភូមិបាល ដីត្រូវបានផ្តល់ឲ្យក្រុមហ៊ុនវិនិយោគក្នុងស្រុក និងក្រុមហ៊ុនបរទេស ក្នុងរយៈពេលមួយយ៉ាងយូរ ជាពិសេសក្នុងកំឡុងឆ្នាំ២០១០និង២០១១ (Messerli et al.,, 2015)(Sperfeldt et al.,, 2012)។ ទំនាស់ដីធ្លីបានកើតមានជាច្រើននៅឆ្នាំ២០១២។ អាស្រ័យហេតុនេះ នាយករដ្ឋមន្ត្រីកម្ពុជា បានចេញបទបញ្ជា០១បប ដើម្បីដោះស្រាយទំនាស់ដីធ្លីទាំងឡាយនោះ។ នៅខែមិថុនា ឆ្នាំ២០១២ យុទ្ធនាការថ្នាក់ជាតិ ត្រូវបានប្រកាសដំណើរការក្នុងបំណងអនុវត្តនូវបទបញ្ជា០១នេះ ដោយធ្វើឲ្យស្របច្បាប់នូវការកាន់កាប់ដីដែលមិនច្បាស់លាស់ នៅជុំវិញក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងការចេញបណ្ណកម្មសិទ្ធិទៅឲ្យប្រជាជនដែលជាអ្នកកាន់កាប់ដីពីមុន ដែលកំពុងប្រើប្រាស់ និងដាំដុះដំណាំលើដីនោះ។ ដីដែលជាគោលដៅ អាចត្រូវបានបែងចែកជាបីប្រភេទរួមមាន៖ ដីសម្បទានសេដ្ឋកិច្ច សម្បទានព្រៃឈើ ឬដីដែលត្រូវបានដកហូតក្នុងតំបន់គម្របព្រៃ(Im Chhun Lim, 2012)។ វាបានគាំទ្រ និងពង្រឹងនូវគោលនយោបាយស្បែកខ្លារបស់រដ្ឋាភិបាលក្នុងគោលបំណងកាត់ចេញនូវតំបន់ តាំងទីលំនៅចេញពីដីសម្បទាននិងកាត់បន្ថយការទន្ទ្រានយកដីរបស់កសិករ និងសហគមន៍។

ក្នុងន័យផលវិបាកលើការប្រកបរបរចិញ្ចឹមជីវិត របស់គ្រួសារកសិករខ្នាតតូច ស្ថានភាព និងផលប៉ះពាល់ជាច្រើន មានលក្ខណៈខុសៗគ្នា អាស្រ័យទៅតាមតំបន់ និងក្រុមប្រជាពលរដ្ឋ ប៉ុន្តែធាតុដែលកើតឡើងជារឿយៗ មួយចំនួនអាចត្រូវបានគូសបញ្ជាក់។ ការទន្ទ្រានលើដីស្រែចម្ការ និងការបាត់បង់ទ្រព្យសម្បត្តិយ៉ាងក្រាស់ក្រែលត្រូវបានជួបប្រទះដោយកសិករ រួមនឹងការបាត់បង់លទ្ធភាពចំពោះធនធានធម្មជាតិដែលមានការថយចុះ និងផលិតផលព្រៃឈើមួយចំនួន ដែលនាំទៅដល់ការប្រែប្រួលជាគំហុកផ្នែកបរិស្ថាន និងការបាត់បង់ការប្រកបរបរចិញ្ចឹមជីវិតជាលក្ខណៈប្រពៃណីរបស់ពួកគាត់។ វាត្រូវបានប៉ាន់ប្រមាណថា ប្រជាជនប្រមាណ ៤២០.០០០នាក់ បានទទួលផលប៉ះពាល់ពីការផ្តល់សម្បទានដី និងការរឹបអូសដីផ្សេងទៀត ចាប់ពីឆ្នាំ២០០៣មក (LICADHO, 2014)។

ការបាត់បង់ទ្រព្យសម្បត្តិ មានចាប់ពី ១) ធ្ងន់ធ្ងរ៖ ការបាត់បង់ដីទាំងអស់ និងរាប់បញ្ចូលសំណង់មួយចំនួន ឬ/និងផ្លាស់ប្តូរទីតាំង ការតាំងទីលំនៅថ្មីរបស់ប្រជាជន ២)ធ្ងន់៖ មិនមានការបណ្តេញចេញ ប៉ុន្តែមិនមានដីគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការ និង ៣) កម្រិតមធ្យម៖ មានដីគ្រប់គ្រាន់ដើម្បីរក្សាសកម្មភាពកសិកម្ម ដើម្បីបំពេញសេចក្តីត្រូវការ។ កម្រិតនៃផលប៉ះពាល់ ក៏អាស្រ័យលើទំហំដីជាតម្រូវការ ភាពអាចរកបាននៃដីជាទូទៅ ក្នុងចំណោមតំបន់ប៉ះពាល់ ភាពកៀកបង្កើយនៃសម្បទានដីទៅនឹងតំបន់ដែលត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋ និងចុងបញ្ចប់ គឺជំហាននៃការអនុវត្តការផ្តល់ដីសម្បទានសេដ្ឋកិច្ច (Gironde et al.,, 2014)។ សម្រាប់ប្រជាជនដែលជួបការបណ្តេញចេញ ការផ្លាស់ប្តូរទីតាំង និងការតាំងទីលំនៅថ្មី ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ នឹងនៅតែពឹងអាស្រ័យជាចម្បង ទៅលើឱកាសដែលផ្តល់ឲ្យនៅទីតាំងថ្មី។ ប្រជាជននៅក្នុងចំណាត់ថ្នាក់ផ្សេង ដែលត្រូវបានរៀបរាប់មកហើយនោះច្បាស់ណាស់នឹងប្រឈមការបាត់បង់ដីធ្លី ឬខ្វះដី និងប្រឈមនឹងបញ្ហាលំបាកជាខ្លាំងនៅក្នុងការរក្សានូវការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់។

ក្រៅពីផលប៉ះពាល់ភ្លាមៗ ពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច ផលវិបាកនៃការប្រកបរបរចិញ្ចឹមជីវិត គួរត្រូវបានប៉ាន់ប្រមាណ នៅដំណាក់កាលអន្តរកាលផងដែរ។ គ្រួសារកសិករដែលមានដីធ្លីខ្នាតតូច ជាពិសេសក្រុមជនជាតិដើមភាគតិច ដែលអាចប្រឈមនឹងការបាត់បង់ទ្រព្យសម្បត្តិ នៅពេលនោះនឹងត្រូវប្រឈមនឹងអន្តរកាលដីធ្លី។ អន្តរកាលដីធ្លី អាចត្រូវបានយល់ថា ជាការផ្លាស់ប្តូរជាសំខាន់នៃកសិកម្ម តួនាទីរបស់វាក្នុងសង្គម ការផ្លាស់ប្តូរទំនាក់ទំនងរបស់ប្រជាពលរដ្ឋ ជាមួយនឹងបរិស្ថាន (Castella, 2007)។ ដំណើរការនេះ បាននឹងកំពុងកើតឡើង និងផ្តួចផ្តើមដោយគោលនយោបាយសាធារណៈ មុនពេលផ្ទុះឡើងនូវការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដូចជាការផ្សព្វផ្សាយបច្ចេកទេសទំនើប និងការអភិវឌ្ឍមូលដ្ឋានទីផ្សារ នៃដំណាំទីផ្សារជាដើម។ ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ពិសេសក្រោយឆ្នាំ២០០៥ បានបង្កើននូវជំហានមួយយ៉ាងធំ នៃការផ្លាស់ប្តូរការប្រកបរបរចិញ្ចឹមជីវិតជនបទ និងផ្លាស់ប្តូរនូវបរិស្ថានសេដ្ឋកិច្ចសង្គម ដែលត្រូវបានកំណត់លក្ខណៈ ដោយតម្រូវការកើនឡើងនៃសាច់ប្រាក់ (Gironde et al.,, 2014)។ នាពេលបច្ចុប្បន្ន កសិករបានជួបនូវការផ្លាស់ប្តូរមិនស្មើគ្នាលើប្រព័ន្ធចិញ្ចឹមជីវិតជនបទរបស់ពួកគេ និងដំណើរការមួយ នៃភាពផ្សេងគ្នាផ្នែកសេដ្ឋកិច្ច និងសង្គម ជាការគម្រាមកំហែង និងឱកាសដែលកើតចេញពីបរិស្ថានសេដ្ឋកិច្ចសង្គមថ្មី ដែលមិនប៉ះពាល់ដល់ប្រជាពលរដ្ឋ តាមរបៀបតែមួយ (Gironde et al.,, 2014)។

## IV. ស្ថានភាពកសិកម្មកម្ពុជា

ក្នុងន័យផលិតកម្មស្រូវ កម្ពុជាបានបង្កើនផលិតកម្មរបស់ខ្លួនគួរឲ្យកត់សម្គាល់ ដើម្បីឈានដល់កម្រិតមួយដែលគ្រប់គ្រាន់សម្រាប់ខ្លួន និងបរិមាណលើសសម្រាប់ការនាំចេញ។ ចាប់ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៤ ផលិតកម្មស្រូវបានកើនឡើងប្រហែល ២៣%។ ការកើនឡើងនេះ មួយផ្នែក ចូលរួមមកពីការបង្កើនផ្ទៃដីដាំដុះ (១២%) និងពីការបង្កើនទិន្នផលស្រូវ (៨%)។ ការកើនឡើងនូវទិន្នផលស្រូវ អាស្រ័យដោយការណែនាំ និងការទទួលយកពូជស្រូវកែលម្អ ដែលត្រូវបានណែនាំដោយវិទ្យាស្ថានស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កសិកម្ម និងដំណាំស្រូវនៅកម្ពុជា (CARDI) និងការប្រើប្រាស់ធាតុចូលកសិកម្មដែលមានការកើនឡើង ជាពិសេសជីគីមី។ ការទទួលយកពូជដែលបានកែលម្អ មានការកើនឡើងជារៀងរាល់ឆ្នាំ។ ដំណាលគ្នានេះ ការបាត់បង់ផ្ទៃដីប្រមូលផលក៏ត្រូវបានកាត់បន្ថយប្រមាណ៤០% ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤។

**តារាងទី១៖ ស្ថានភាពផលិតកម្មស្រូវពីឆ្នាំ២០០៩ ដល់២០១៤**

| ឆ្នាំ | ផ្ទៃដីដាំដុះសរុប (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ផលិតកម្មសរុប (ត.) | ទិន្នផលស្រូវ (ត./ហ.ត) | ផ្ទៃដីខូចខាត (ហ.ត) |
|---|---|---|---|---|---|
| ២០០៩ | ២,៧១៩,០៨០ | ២,៦៧៤,៦០៣ | ៧,៥៨៥,៨៧០ | ២.៨៤ | ៤៤,៤៧៧ |
| ២០១០ | ២,៧៩៥,៨៩២ | ២,៧៧៧,៣២៣ | ៨,២៤៩,៤៥២ | ២.៩៧ | ១៨,៥៦៩ |
| ២០១១ | ២,៩៦៨,៥២៩ | ២,៧៦៦,៦១៧ | ៨,៧៧៩,៣៦៥ | ៣.១៧ | ២០១,៩១២ |
| ២០១២ | ៣,០០៧,៥៤៥ | ២,៩៨០,២៩៧ | ៩,២៩០,៩៤០ | ៣.១២ | ២៧,២៤៨ |
| ២០១៣ | ៣,០៥២,៤២០ | ២,៩៦៨,៩៦៧ | ៩,៣៨៩,៩៦១ | ៣.១៦ | ៨៣,៤៥៣ |
| ២០១៤ | ៣,០៥៥,៥០៧ | ៣,០២៨,៨៣៦ | ៩,៣២៤,៤១៦ | ៣.០៨ | ២៦,៦៧១ |
| មធ្យមភាគ | ២,៩៣៣,១៦២ | ២,៨៦៦,១០៧ | ៨,៧៧០,០០១ | ៣.០៦ | ៦៧,០៥៥ |
| អត្រាកំណើន (២០០៩-២០១៤) | ១២% | ១៣% | ២៣% | ៨% | -៤០% |

ប្រភព៖ ស្ថិតិកសិកម្មប្រចាំឆ្នាំ នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ២០០៩-២០១៤

ក្រៅពីផលិតកម្មស្រូវ ដំណាំមិនមែនស្រូវក៏មានការកើនឡើងផងដែរ ពិសេសកៅស៊ូ និងដំឡូងមី។ ផលិតកម្មកៅស៊ូបានកើនឡើងប្រមាណ១៨០% ខណៈដែលផលិតកម្មដំឡូងមី បានកើនឡើងប្រមាណ២៩២%។ ផ្ទុយទៅវិញ ផលិតកម្មសណ្តែកសៀង បានធ្លាក់ចុះប្រមាណ២៤% និងពោតប្រមាណ៤០%។ តាមរយៈការអង្កេតនៅមូលដ្ឋាន មានការកើនឡើងនូវប្រភេទដំណាំស្វាយចន្ទី និងដំណាំម្រេច។ ទោះយ៉ាងណាក្តី ពុំមានទិន្នន័យអាចរកបានសម្រាប់ផលិតកម្មទាំងពីរនេះទេ។

**តារាងទី២៖ ស្ថានភាពដំណាំមិនមែនស្រូវសំខាន់ៗ ពីឆ្នាំ២០០៩ ដល់២០១៤ (ពាន់តោន)**

| ឆ្នាំ | កៅស៊ូ (១.០០០ត) | កៅស៊ូ (ហ.ត) | ដំឡូងមី | សណ្តែកសៀង | ពោត | បន្លែ |
|---|---|---|---|---|---|---|
| ២០០៩ | ៣៧ | ១២៧៨២៣ | ៣៤៩៧ | ១៣៧ | ៩២៤ | ៣២៣ |
| ២០១០ | ៤២ | ១៨១៤៣៣ | ៤២៤៩ | ១៥២ | ៧៧៣ | ៣៧៧ |
| ២០១១ | ៥១ | ២១៣១០៤ | ៨០៣៤ | ១១៥ | ៦៤៦ | ៤០០ |
| ២០១២ | ៦៥ | ២៨០៣៥៤ | ៧៦១៤ | ១២០ | ៨២០ | ៤១១ |
| ២០១៣ | ៨៥ | ៣២៨៧៧១ | ៧៩៣៣ | ១៣១ | ៩២៧ | ៤៥៣ |
| ២០១៤ | ៩៧ | ៣៥៧៨០០ | ១១៩៤៣ | ១០៤ | ៥៥០ | ៤១៥ |
| មធ្យមភាគ | ៦៣ | ២៤៨២១៤ | ៧០៤៧ | ១២៧ | ៧៧៣ | ៣៩៧ |
| អត្រាកំណើន(២០០៩-២០១៤) | ១៦២% | ១៨០% | ២៤២% | -២៤% | -៤០% | ២៨% |

ប្រភព៖ ស្ថិតិកសិកម្មប្រចាំឆ្នាំ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០០៩-២០១៤

ក្រៅពីផលិតកម្មដំណាំ ផលិតកម្មបក្សីនិងជ្រូកមានការកើនឡើង ប៉ុន្តែផលិតកម្មគោក្របីមានការថយចុះ។ ការថយចុះផលិតកម្មគោក្របី ដោយសារការថយចុះនៃតម្រូវការកម្លាំងពលកម្មសម្រាប់គោក្របី នៅក្នុងសកម្មភាពដាំដុះ។ កម្លាំងអូសទាញត្រូវបានជំនួសដោយគ្រឿងម៉ាស៊ីន ដូចជា ត្រាក់ទ័រ និងគោយន្ត។

**តារាងទី៣៖ ស្ថានភាពនៃការចិញ្ចឹមសត្វពីឆ្នាំ ២០០៩-២០១៤**

| ឆ្នាំ | បក្សី | ជ្រូក | គោ និងក្របី |
|---|---|---|---|
| ២០០៩ | ២០,១៩២,៨១១ | ២,១២៦,៣០៤ | ៤,៣១៩,៥២៨ |
| ២០១០ | ២០,៨៣៤,២៩៥ | ២,០៥៧,៤៣១ | ៤,១៨៦,៦៧៥ |
| ២០១១ | ២២,០៣៦,៧៥៥ | ២,០៩៩,៣៣២ | ៤,០៩៥,៨០១ |
| ២០១២ | ២២,០៩៨,៨០៩ | ២,២០៨,៦១១ | ៤,០៣៣,៧៨០ |
| ២០១៣ | ២៧,៣១៦,៤១៥ | ២,៤៣៦,៦៩៩ | ៤,០៥០,០០៩ |
| ២០១៤ | ៣១,៥៨៣,៦៥៧ | ២,៧៣៥,៧១៧ | ៣,៦០១,៧៨៦ |
| មធ្យមភាគ | ២៤,០១០,៤៥៧ | ២,២៧៧,៣៤៩ | ៤,០៤៧,៩៣០ |
| អត្រាកំណើន (២០០៩-២០១៤) | ៥៦% | ២៩% | -១៧% |

ប្រភព៖ ស្ថិតិកសិកម្មប្រចាំឆ្នាំ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០០៩-២០១៤

គួរកត់សម្គាល់ថា ថវិកាសម្រាប់កសិកម្មជាតិ បានកើនឡើងប្រមាណ៧៨% ពីឆ្នាំ២០០៩ ដល់២០១៤ ប៉ុន្តែការចូលរួមក្នុងផលិតផលសរុបជាតិ បានថយចុះចំនួន ១៤%។ យើងអាចនិយាយបានថា វិស័យកសិកម្ម មិនមានដំណើរការល្អទេក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ហើយវិស័យឧស្សាហកម្ម និងសេវាកម្ម មានសកម្មភាពខ្លាំងក្លាជាង។ ជាការគួរឲ្យចាប់អារម្មណ៍ថវិកាជាតិ សម្រាប់ក្រសួងកិច្ចការនារីបានកើនឡើងប្រមាណ ៤៣% ក្នុងកំឡុង៥ឆ្នាំដូចគ្នា។ នេះបានបង្ហាញនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្សារភ្ជាប់វិសមភាពយេនឌ័រនៅកម្ពុជា ពិសេសក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម។

តារាងទី៤៖ ស្ថានភាពដីកសិកម្ម និងការចូលរួមក្នុងផលទុនសរុបជាតិពីឆ្នាំ២០០៩-២០១៤

| ឆ្នាំ | ចំណែក (%) ក្នុងផលទុនសរុបជាតិ (តម្លៃ២,០០០ថេរ) | ថវិកាជាតិសរុប (ពាន់ដុល្លារ) | ចំណាយសម្រាប់កសិកម្ម (ពាន់ដុល្លារ) | ចំណាយសម្រាប់កិច្ចការនាទី (ពាន់ដុល្លារ) |
|---|---|---|---|---|
| ២០០៩ | ៣៣.៥ | ១,៧៧០,៦២៦ | ១៩,៧៧៧ | ៦,២៤៣ |
| ២០១០ | ៣៣.៩ | ២,០២៤,៣៣៥ | ២១,៣៣៨ | ៦,៨០៧ |
| ២០១១ | ៣៤.៦ | ២,៤០២,៣៥៤ | ២៤,០៩៥ | ៦,៨៩៥ |
| ២០១២ | ៣៣.៥ | ២,៦២៦,៣៣៧ | ៣០,៤០៤ | ៧,២២១ |
| ២០១៣ | ៣១.៦ | ២,៩៥០,០១៨ | ៣៤,៤៣៧ | ៧,៥២៥ |
| ២០១៤ | ២៨.៧ | ២,០៤៩,៣៦០ | ៣៥,១៤៣ | ៨,៩៤៦ |
| មធ្យមភាគ | ៣២.៦ | ២,៣០៣,៨៣៨ | ២៣,៥២១ | ៧,២៧២ |
| អត្រាកំណើន (២០០៩-២០១៤) | -១៤% | ១៦% | ៧៨% | ៤៣% |

## V. ករណីសិក្សាស្តីពីស្ថានភាពកសិកម្ម របស់គ្រួសារកសិករខ្នាតតូច

### *5.1. ប្រូហ្វីលសំខាន់ៗនៃគ្រួសារអ្នកផ្តល់ព័ត៌មាន*

ក្នុងចំណោមគ្រួសារដែលត្រូវបានសម្ភាសន៍គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានចំនួនចន្លោះពី ៥% ទៅ ១០%។ នៅស្រុកសន្ទុក និងស្រុកជុំគីរី មេគ្រួសារដែលបានបញ្ចប់កម្រិតអនុវិទ្យាល័យ មានប្រមាណ១៥% ខណៈដែលនៅស្រុកអូរយ៉ាដាវ មិនមានមេគ្រួសារណាមួយ បានបញ្ចប់កម្រិតអនុវិទ្យាល័យឡើយ។ មូលហេតុដែលមិនមានមេគ្រួសារណាមួយអាចបញ្ចប់កម្រិតអនុវិទ្យាល័យ ដោយសារថា ការតាំងទីលំនៅរបស់ពួកគាត់ ស្ថិតនៅឆ្ងាយពីសាលារៀន នៅពេលដែលពួកគាត់នៅក្មេង ឬមិនមានសាលារៀនតែម្តង។ ដូច្នេះ ពួកគាត់មិនមានឱកាសទទួលបានការអប់រំឡើយ។

តារាងទី៥៖ ប្រូហ្វីលសំខាន់ៗនៃគ្រួសារដែលជាអ្នកផ្តល់ព័ត៌មាន ក្នុងឆ្នាំ ២០១៦

| ល.រ | បរិយាយ | សន្ទុក | អូរយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|
| ១ | គ្រួសារដែលមានបុរសជាមេគ្រួសារ | ៩០% | ៩៥% | ៩០% |
| ២ | គ្រួសារដែលមានស្ត្រីជាមេគ្រួសារ | ១០% | ៥% | ១០% |

| | | | | | |
|---|---|---|---|---|---|
| ៣ | ការអប់រំរបស់គ្រួសារយ៉ាងហោចណាស់កម្រិតអនុវិទ្យាល័យ | សម្រាប់គ្រួសារដែលមានបុរសជាមេគ្រួសារ | ១៥% | ០% | ១៥% |
| | | សម្រាប់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ | ០% | ០% | ០% |
| ៤ | ប្រវត្តិនៃការតាំងទីលំនៅក្នុងស្រុកបច្ចុប្បន្ន | ពី១-៥ឆ្នាំ | ២៥% | ៥% | ១០% |
| | | ពី៥-១០ឆ្នាំ | ២០% | ៥% | ១០% |
| | | ច្រើនជាង១០ឆ្នាំ | ៥៥% | ៩០% | ៨០% |

ចំនួនច្រើនជាង៩៥% នៃគ្រួសារដែលបានសម្ភាសន៍ មានដីលំនៅឋានខណៈដែលតិចជាង ៥% មិនមានដីលំនៅឋាន។ ពួកគាត់ជាគ្រួសារដែលទើបតែរៀបការថ្មីៗ ដែលបានតាំងទីលំនៅលើដីលំនៅស្ថានរបស់ឪពុកម្តាយរបស់ពួកគាត់ ឬជាគ្រួសារក្រីក្រ ដែលជួបបញ្ហាលំបាកហើយលក់ដីធ្លីអស់។ ជាការពិត ដីលំនៅស្ថានគឺជាធនធានចុងក្រោយ ដែលពួកគាត់អាចរក្សាទុក ប្រសិនពួកគាត់អាចនៅស្វែងរកដំណោះស្រាយផ្សេងទៀត ដើម្បីដោះស្រាយបញ្ហា ឬភាពងាយរងគ្រោះរបស់ពួកគេ។

គ្រួសារដែលបានសម្ភាសន៍ស្ទើរតែទាំងអស់មានដីកសិកម្មតាមប្រភេទផ្សេងៗទាំងដីស្រែ និងដីចម្ការ។ គ្រួសារដែលបានសម្ភាសន៍ ប្រមាណពាក់កណ្តាលនៅស្រុកសន្ទុក ៧០% នៅស្រុកអូរយ៉ាដាវ និង៩៥% នៅស្រុកជុំគីរី មានដីសម្រាប់ធ្វើស្រែ។ គ្រួសារជនជាតិដើមភាគតិចនៅស្រុកអូរយ៉ាដាវដែលបានរស់នៅដោយមានដីធំទូលំទូលាយ និងធ្លាប់ពឹងអាស្រ័យលើការធ្វើស្រូវចម្ការសម្រាប់ហូបបានផ្លាស់ប្តូរមកដាំដំណាំទីផ្សារ និងពឹងអាស្រ័យលើការទិញស្រូវពីទីផ្សារមកហូបវិញ។ ការនេះបានធ្វើឲ្យមានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់នូវទំនៀមទម្លាប់ និងប្រពៃណីនៃការហូបចុករបស់ពួកគាត់។ សម្រាប់ហេតុផលមួយចំនួន ១) ដីមានលក្ខខណ្ឌសមស្របសម្រាប់ការដាំដុះ បន្ទាប់ពីដាំដុះបាន២ទៅ៣រដូវកាល ២) មិនមានដីដែលអាចធ្វើការផ្លាស់បង្វិលក្នុងការអនុវត្តដំណាំស្រូវចម្ការទៀតទេ និង៣) មានទីផ្សារល្អ សម្រាប់

ដំឡូងមី និងដំណាំស្វាយចន្ទី។ ដូច្នេះ ពួកគាត់បានទទួលយកការអនុវត្តកសិកម្មបែបថ្មី ដើម្បីឆ្លើយតបទៅនឹងបម្រែបម្រួលប្រព័ន្ធដីធ្លីថ្មីនេះ។

**តារាងទី៦៖ ប្រូហ្វីលស្តីអំពីដី និងភាពជាកម្មសិទ្ធិនៃគ្រួសារដែលបានសម្ភាសន៍ក្នុងឆ្នាំ២០១៦**

| ល.រ | បរិយាយ | | សន្ទុក | អូរយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|---|
| 1 | គ្រួសារមានដីលំនៅស្ថានជាកម្មសិទ្ធិ | %គ្រួសារ | ៩៥% | ១០០% | ៩៨% |
| | | មធ្យម(ម²/គ្រួសារ) | ១,៨០០ | ១,៩៥០ | ១,០០០ |
| 2 | គ្រួសារមានដីកសិកម្ម | %គ្រួសារ | ស្រូវ=៥០%<br>ចម្ការ=៨០% | ស្រូវ=៧០%<br>ចម្ការ=៩៥% | ស្រូវ=៩៣%<br>ចម្ការ=២៧% |
| | | មធ្យម(ម²/គ្រួសារ) | ស្រូវ=១០,០០០<br>ចម្ការ=២០,០០០ | ស្រូវ=១៥,០០០<br>ចម្ការ=៣០,០០០ | ស្រូវ=១៥,០០០<br>ចម្ការ=១០,០០០ |
| 3 | គ្រួសារមានដីផ្សេងទៀត | %គ្រួសារ | ១៣% | ២២% | ១៨% |
| | | មធ្យម(ម²/គ្រួសារ) | ២៣,០០០ | ២២,៣០០ | ៥,០០០ |

ធនធានរូបវន្តសំខាន់ៗដែលបានសង្កេតឃើញរួមមាន៖ ត្រាក់ទ័រ ឬគោយន្ត គោ ឬក្របី ម៉ាស៊ីនបូមទឹក អណ្តូងលូ និងអណ្តូងស្នប់ ម៉ាស៊ីនកាត់ស្មៅ និងទូរស័ព្ទដៃ។ គួរកត់សម្គាល់ថា៖

- ម៉ូតូ និងទូរស័ព្ទដៃគឺជាទ្រព្យសម្បត្តិ ដែលគ្រួសារភាគច្រើនមានប្រើប្រាស់។ យ៉ាងហោចណាស់ ៧០%នៃគ្រួសារដែលបានសម្ភាសន៍ មានម៉ូតូជារបស់ផ្ទាល់ខ្លួន និងគ្រួសារទាំងអស់ មានទូរស័ព្ទដៃ។

- ម៉ាស៊ីនកាត់ស្មៅ ត្រូវបានទទួលយកមកប្រើប្រាស់គួរឲ្យកត់សម្គាល់ នៅស្រុកអូរយ៉ាដាវ ដែលចំនួន៤០% មានឧបករណ៍នេះប្រើប្រាស់ជារបស់ផ្ទាល់ខ្លួន។
- គោយន្ត ឬគោយន្តសណ្តោងរ៉ឺម៉ក ក៏មានការកើនឡើងគួរឲ្យកត់សម្គាល់ផងដែរ។ នាពេលបច្ចុប្បន្ន ២៥%នៃគ្រួសារដែលបានសម្ភាសន៍នៅស្រុកអូរយ៉ាដាវ ៤០%នៅស្រុកសន្ទុក និង៤៥%នៅស្រុកជុំគីរី មានឧបករណ៍នេះប្រើប្រាស់ជារបស់ផ្ទាល់ខ្លួន។

**តារាងទី៧៖ ទ្រព្យសម្បត្តិសំខាន់ៗនៃគ្រួសារដែលបានសម្ភាសន៍ក្នុងឆ្នាំ២០១៦**

| ល.រ | ធនធានរូបវន្តសំខាន់ៗ | សន្ទុក | អូរយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|
| ១ | គោយន្ត ឬ គោយន្តសណ្តោងរ៉ឺម៉ក | ៤០% | ២៥% | ៤៥% |
| ២ | គោ ឬ ក្របី | ៥% | ៨% | ៣០% |
| ៣ | ម៉ាស៊ីនបូមទឹក | ៣% | ៥% | ៧% |
| ៤ | អណ្តូងលូ ឬ អណ្តូងស្នប់ | ៦៥% | ៤៥% | ០% |
| ៥ | ម៉ូតូ | ៨០% | ៩០% | ៧០% |
| ៦ | ម៉ាស៊ីនកាត់ស្មៅ | ៣% | ៤០% | ០% |
| ៧ | ទូរស័ព្ទដៃ | ១០០% | ១០០% | ១០០% |

## *5.2. សកម្មភាពសេដ្ឋកិច្ចគ្រួសារនិងប្រាក់ចំណូល*

ចំណូលសរុបប្រចាំឆ្នាំនៃគ្រួសារដែលបានសម្ភាសន៍ស្ថិតនៅចន្លោះពី ២,០៩០ ដុល្លារនៅស្រុកជុំគីរី ២,៣៣០ដុល្លារនៅស្រុកសន្ទុក និង២,៨៧២ដុល្លារនៅស្រុកអូរយ៉ាដាវ។ នៅស្រុកអូរយ៉ាដាវ ចំណូលដែលបានមកពីរបរកសិកម្ម មានចំនួន៥៧% ខណៈដែលស្រុកសន្ទុកមានចំនួន៥២% និង២៥%នៅស្រុកជុំគីរី។ បើប្រៀបធៀបនឹងរយៈពេល៥ឆ្នាំមុន ចំណូលពីកសិកម្ម មានប្រមាណ៤៨% នៅស្រុកសន្ទុក៥៤% នៅស្រុកអូរយ៉ាដាវ និង៤៣%នៅស្រុកជុំគីរី។ ជាការគួរឲ្យកត់សម្គាល់ ចំណូលពីកសិកម្មនៅស្រុកសន្ទុក បានមកពីដំឡូងមីជាសំខាន់ ស្រុកអូរយ៉ាដាវបានមកពីដំឡូងមី ស្វាយចន្ទី និងក្របី ខណៈដែលចំណូលកសិកម្មនៅស្រុកជុំគីរី បានមកពីផលិតកម្មសត្វជាសំខាន់។

**តារាងទី៨៖ សមាសភាគចំណូលគ្រួសារ និងការចូលរួមចំណែក ក្នុងឆ្នាំ២០១៦**

| ល.រ | ប្រភពចំណូល | | សន្ទុក | អូរយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|---|
| ១ | ចំណូលពីកសិកម្ម | បច្ចុប្បន្ន | ១,២២០ | ១,៦៤២ | ៥៣០ |
| | | ៥ឆ្នាំមុន | ១,១៦០ | ១,៧៣៥ | ៥៩០ |
| ២ | ចំណូលក្រៅកសិកម្ម | បច្ចុប្បន្ន | ១,១១០ | ១,២៣០ | ១,៥៦០ |
| | | ៥ឆ្នាំមុន | ១,២៧០ | ១,៤៨០ | ៧៧៩ |
| ៣ | ប្រាក់ចំណូលសរុបក្នុងគ្រួសារ | បច្ចុប្បន្ន | ២,៣៣០ | ២,៨៧២ | ២,០៩០ |
| | | ៥ឆ្នាំមុន | ២,៤៣០ | ៣,២១៥ | ១,៣៦០ |

**តារាងទី៩៖ សមាសភាគចំណូលកសិកម្ម និងការចូលរួមរបស់វានៅឆ្នាំ២០១៦**

| ល.រ | ប្រភពចំណូល | | សន្ទុក | អូរយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|---|
| ១ | ផលិតកម្មដំណាំ | %គ្រួសារ | ស្រូវ=២០%<br>ស្វាយចន្ទី=៩%<br>ដំឡូងមី=៦៤% | ស្រូវ=៥៥%<br>ស្វាយចន្ទី=៤៥%<br>ដំឡូងមី=៧៥%<br>កៅស៊ូ=៥% | ស្រូវ=១០០%<br>ដំណាំផ្សេងៗ=១៥%<br>បន្លែ=២% |
| | | មធ្យម | ៧០០ដុល្លារ | ១,៥០០ដុល្លារ | ៣០០ដុល្លារ |
| ២ | ផលិតកម្មសត្វ | %គ្រួសារ | មាន់=៥% | ក្របី=១៥% | មាន់=១៥%<br>ជ្រូក=១៥%<br>គោក្របី=១៥% |
| | | មធ្យម | ២០ដុល្លារ | ៤៦៥ដុល្លារ | ៥០០ដុល្លារ |

**ចំពោះការចូលរួមពលកម្ម វាត្រូវបានរកឃើញថា៖**

- នៅក្នុងសកម្មភាពកសិកម្ម ស្ត្រីបានចូលរួមចំណែកច្រើនជាងបុរសនៅស្រុកអូរយ៉ាដាវ ខណៈបុរសបានចូលរួមច្រើនជាងស្ត្រីនៅស្រុកជុំគីរី។

- នៅក្នុងសកម្មភាពមិនមែនកសិកម្ម បុរសចូលរួមចំណែកច្រើនជាងស្ត្រីនៅស្រុកសន្ទុក និងជុំគីរី ខណៈស្ត្រីចូលរួមចំណែកច្រើនជាងបុរសនៅស្រុកអូរយ៉ាដាវ។
- នៅក្នុងការងារមិនផ្តល់ប្រាក់កម្រៃស្ត្រីរមែងចូលរួមច្រើនលើសលប់ជាងបុរស។

**តារាងទី១០៖ ការចូលរួមកម្លាំងពលកម្មពីបុរស និងស្ត្រី ក្នុងសហគ្រាសកសិកម្មគ្រួសារឆ្នាំ២០១៦**

| ល.រ | ប្រភពចំណូល | | សន្ទុក | អូរយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|---|
| ១ | ការងារកសិកម្ម | បុរស | ៥០% | ៤៧% | ៦០% |
| | | ស្ត្រី | ៥០% | ៥៣% | ៤០% |
| ២ | ការងារក្រៅកសិកម្ម | បុរស | ៧៥% | ៤៨% | ៧៥% |
| | | ស្ត្រី | ២៥% | ៥២% | ២៥% |
| ៣ | ការងារមិនផ្តល់ប្រាក់កម្រៃ | បុរស | ២០% | ១០% | ៣០% |
| | | ស្ត្រី | ៨០% | ៩០% | ៧០% |

### *5.3. លទ្ធភាពទទួលបានព័ត៌មាន ការធ្វើសេចក្តីសម្រេចចិត្ត និងចំណេះដឹងស្តីពីសហគមន៍សេដ្ឋកិច្ចអាស៊ាន*

ចំពោះលទ្ធភាពទទួលបានព័ត៌មានស្តីពីធាតុចូលកសិកម្ម ចំណេះដឹងបច្ចេកទេស និងទីផ្សារ បុរសមានលទ្ធភាពទទួលបានច្រើនជាងស្ត្រី។ ភាពខុសប្លែកគ្នានេះបង្ហាញដោយភស្តុតាងជាពិសេស ក្នុងស្រុកសន្ទុក និងស្រុកអូរយ៉ាដាវ ដោយឡែកស្រុកជុំគីរី ភាពខុសប្លែកគ្នានេះមានលក្ខណៈតិចតួចប៉ុណ្ណោះ។ ការធ្វើសេចក្តីសម្រេចចិត្ត ពីការទទួលយកប្រភេទដំណាំផ្សេងគ្នា ឬសកម្មភាពកសិកម្មណាមួយភាគច្រើនធ្វើឡើងដោយភាគីបុរស។

លើសពីនេះ ប្រមាណ៣០%នៃអ្នកផ្តល់សម្ភាសន៍នៅស្រុកអូរយ៉ាដាវ ៣៥%នៅស្រុកសន្ទុក និងពាក់កណ្តាលនៅស្រុកជុំគីរី ធ្លាប់បានឮពីសហគមន៍សេដ្ឋកិច្ចអាស៊ានពិសេសតាមរយៈបណ្តាញសង្គម ដែលរួមមានទូរទស្សន៍ និងវិទ្យុ។

**តារាងទី១១៖ លទ្ធភាពទទួលបានព័ត៌មាន ការធ្វើសេចក្តីសម្រេចចិត្តក្នុងការងារកសិកម្ម និងចំណេះដឹងពីសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងឆ្នាំ២០១៦**

| ល.រ | ប្រភេទព័ត៌មាន | | សន្ទុក | អូរយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|---|
| 1 | ធាតុចូលកសិកម្ម | ស្ត្រីចូលរួមច្រើនជាងបុរស | ១៥% | ៥% | ៤៥% |
| | | បុរសចូលរួមច្រើនជាងស្ត្រី | ៨៥% | ៩៥% | ៥៥% |
| 2 | បច្ចេកទេសប្រើប្រាស់ធាតុចូល | ស្ត្រីចូលរួមច្រើនជាងបុរស | ១៥% | ១០% | ៤០% |
| | | បុរសចូលរួមច្រើនជាងស្ត្រី | ៨៥% | ៩០% | ៦០% |
| 3 | ព័ត៌មានទីផ្សារ | ស្ត្រីចូលរួមច្រើនជាងបុរស | ២៥% | ១០% | ៤៥% |
| | | បុរសចូលរួមច្រើនជាងស្ត្រី | ៨៥% | ៩០% | ៥៥% |
| 4 | ការទទួលយកប្រភេទដំណាំណាមួយ | ស្ត្រីចូលរួមច្រើនជាងបុរស | ២០% | ១៥% | ៣៥% |
| | | បុរសចូលរួមច្រើនជាងស្ត្រី | ៨០% | ៨៥% | ៦៥% |
| 5 | ធ្លាប់ឮពីសហគមន៍សេដ្ឋកិច្ចអាស៊ាន | | ៣៥% | ៣០% | ៥០% |
| | • បណ្តាញសង្គម | | ១០០% | ៨០% | ៦៥% |
| | • អង្គការមិនមែនរដ្ឋាភិបាលនិងគម្រោងអភិវឌ្ឍន៍ | | ០% | ០% | ០% |
| | • អាជ្ញាធរមូលដ្ឋាន(កម្រិតភូមិ និងឃុំ) | | ១៥% | ០% | ២០% |
| | • អ្នកជិតខាង/សាច់ញាតិ | | ១០% | ២០% | ៣៥% |
| | • មន្ត្រីរដ្ឋាភិបាល (ពីថ្នាក់ស្រុកដល់ថ្នាក់ជាតិ) | | ០% | ០% | ៥% |

អ្នកផ្តល់ព័ត៌មានក្នុងតំបន់គោលដៅ នៃការសិក្សានៅស្រុកជុំគីរីបានលើកឡើងថា អត្ថប្រយោជន៍ចេញពីសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន គឺជួយកាត់បន្ថយការចំណាយលើការអនុញ្ញាតិ ចំពោះចលនាផ្លាស់ប្តូរនៅតាមព្រំដែនសម្រាប់ឱកាសការងារ។ ម៉្យាងទៀត ការវិនិយោគបរទេស នឹងបង្កើតឱកាសការងារបន្ថែម

ហើយអនុញ្ញាតិឲ្យកូនៗរបស់ពួកគាត់ អាចស្វែងរកការងារធ្វើបាន នៅក្នុងប្រទេស។ ផ្ទុយទៅវិញ កសិករនៅស្រុកសន្ទុក និងស្រុកអូរយ៉ាដាវ មិនអាចរៀបរាប់បានពីអត្ថប្រយោជន៍ចេញពីសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ានបានទេ។

## *5.4. លទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ*

ចំពោះលទ្ធភាពទទួលបានកម្ចី ពីស្ថាប័នហិរញ្ញវត្ថុផ្លូវការ ពាក់កណ្តាលនៃគ្រួសារដែលបានសម្ភាសន៍នៅស្រុកសន្ទុក ៦០%នៅស្រុកអូរយ៉ាដាវ និង៩០%នៅស្រុកជុំគីរីបានប្រើប្រាស់ប្រាក់កម្ចី។ ទំហំប្រាក់កម្ចីជាមធ្យម ស្ថិតនៅចន្លោះពី ៧០០ ដុល្លាររហូតដល់១.៥០០ដុល្លារ។ នៅស្រុកសន្ទុក និងស្រុកអូរយ៉ាដាវ កម្ចីត្រូវបានប្រើប្រាស់ជាសំខាន់សម្រាប់ដំណាំមិនមែនស្រូវ ជាពិសេសដំណាំដំឡូងមី និងស្វាយចន្ទី និងសម្រាប់ម្ហូបអាហារកំឡុងពេលខ្វះស្បៀង ជាពិសេសពីខែសីហារហូតដល់ខែវិច្ឆិកា មុនការប្រមូលផលស្រូវ និងដំឡូងមី។ ដោយឡែក នៅស្រុកជុំគីរី កម្ចីត្រូវបានប្រើប្រាស់សម្រាប់ការធ្វើចំណាកស្រុក និងធាតុចូលកសិកម្ម។

មានគ្រួសារតិចតួចប៉ុណ្ណោះនៅស្រុកសន្ទុក ដែលបានខ្ចីប្រាក់ពីសាច់ញាតិ ឬកម្ចីឯកជន។ នៅស្រុកជុំគីរី គ្រួសារដែលត្រូវបានសម្ភាសប្រមាណ៧០% ទិញធាតុចូលកសិកម្ម ជាពិសេសជីគីមីដោយការបណ្តាក់ ខណៈនៅស្រុកអូរយ៉ាដាវ គ្រួសារដែលបានសម្ភាសន៍ប្រមាណ២០% បានប្រើប្រាស់ប្រាក់កម្ចីសម្រាប់ការដាំដុះ និងស្បៀងអាហារកំឡុងពេលខ្វះស្បៀង។ ការទទួលបានប្រាក់កម្ចីពីអ្នកផ្តល់កម្ចីឯកជននៅតែត្រូវបានអនុវត្តជាទូទៅនៅឡើយ នៅស្រុកអូរយ៉ាដាវ អាស្រ័យភាពបត់បែននៃការសងកម្ចីត្រឡប់មកវិញ។ គួរកត់សម្គាល់ថា ក្នុងសហគមន៍ខ្មែរ ស្ត្រីបានដើរតួនាទីសំខាន់ នៅក្នុងការស្វែងរកប្រាក់កម្ចី ទទួលប្រាក់កម្ចី និងយកលុយទៅសងវិញ ខណៈដែលសហគមន៍ជនជាតិដើមភាគតិច បុរសគឺជាតួអង្គសំខាន់ក្នុងការធ្វើសកម្មភាពទាំងនេះ។

## តារាងទី១២៖ លទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ ចំពោះគ្រួសារដែលបានសម្ភាសន៍ក្នុងឆ្នាំ២០១៦

| ល.រ | ប្រភពហិរញ្ញវត្ថុ | | សន្ទុក | អូរយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|---|
| ក | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/ធនាគារ | | | | |
| ១ | គ្រួសារដែលប្រើប្រាស់ប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬ ធនាគារ | | ៥០% | ៦០% | ៩០% |
| ២ | ទំហំប្រាក់កម្ចីក្នុង១គ្រួសារ (ដុល្លារ) | | ៧០០ | ១.០០០ | ១.៥០០ |
| ៣ | បុគ្គលសំខាន់ដែលស្វែងរកកម្ចី? | បុរស | ៤០% | ៧០% | ៣៥% |
| | | ស្ត្រី | ៦០% | ៣០% | ៦៥% |
| ៤ | អ្នកដែលធ្វើសេចក្តីសម្រេចចិត្តទទួលប្រាក់កម្ចី? | បុរស | ៤៨% | ៨០% | ៤៨% |
| | | ស្ត្រី | ៥២% | ២០% | ៥២% |
| ៥ | បុគ្គលដែលទទួលខុសត្រូវសំខាន់ក្នុងការស្វែងរកចំណូលសងប្រាក់កម្ចី? | បុរស | ៥៥% | ៨០% | ៦៥% |
| | | ស្ត្រី | ៤៥% | ២០% | ៣៥% |
| ៦ | អ្នកដែលទទួលលុយពីស្ថាប័ន/អ្នកផ្តល់កម្ចី | បុរស | ៥៥% | ៨៥% | ១០% |
| | | ស្ត្រី | ៤៥% | ១៥% | ៩០% |
| ៧ | កាន់លុយយកទៅសង | បុរស | ៥៥% | ៨៥% | ១៥% |
| | | ស្ត្រី | ៤៥% | ១៥% | ៨៥% |
| ខ | សាច់ញាតិ (មិនមានការប្រាក់) | | | | |
| ១ | គ្រួសារដែលទទួលប្រាក់កម្ចីពីសាច់ញាតិ | | ១៥% | ៥% | ៥% |
| ២ | ចំនួនប្រាក់កម្ចីក្នុង១គ្រួសារ (ដុល្លារ) | | ១០០ | ៥០ | ៥០ |
| ៣ | បុគ្គលសំខាន់ដែលស្វែងរកកម្ចី? | បុរស | ៣០% | ៥០% | ០% |
| | | ស្ត្រី | ៧០% | ៥០% | ១០០% |
| ៤ | អ្នកដែលធ្វើសេចក្តីសម្រេចចិត្តទទួលប្រាក់កម្ចី? | បុរស | ៤០% | ១០០% | ០% |
| | | ស្ត្រី | ៦០% | ០% | ១០០% |

| | | | | | |
|---|---|---|---|---|---|
| ៥ | បុគ្គលដែលទទួលខុសត្រូវសំខាន់ក្នុងការស្វែងរកចំណូលសងប្រាក់កម្ចី? | បុរស | ៤០% | ១០០% | ៥០% |
| | | ស្ត្រី | ៦០% | ០% | ៥០% |
| ៦ | អ្នកដែលទទួលលុយពីស្ថាប័ន/អ្នកផ្តល់កម្ចី | បុរស | ៤០% | ១០០% | ០% |
| | | ស្ត្រី | ៦០% | ០% | ១០០% |
| ៧ | កាន់លុយយកទៅសង | បុរស | ៤០% | ១០០% | ០% |
| | | ស្ត្រី | ៦០% | ០% | ១០០% |
| គ | អ្នកផ្តល់ប្រាក់កម្ចីឯកជន | | | | |
| ១ | គ្រួសារទទួលប្រាក់កម្ចីពីអ្នកផ្តល់ប្រាក់កម្ចីឯកជន | | ៧% | ២០% | ៧៥% |
| ២ | ចំនួនប្រាក់កម្ចីក្នុង១គ្រួសារ (ដុល្លារ) | | ៥០០ | ១.០០០ | ៥០០ |
| ៣ | បុគ្គលសំខាន់ដែលស្វែងរកកម្ចី? | បុរស | ០% | ១០០% | ០% |
| | | ស្ត្រី | ១០០% | ០% | ១០០% |
| ៤ | អ្នកដែលធ្វើសេចក្តីសម្រេចចិត្តទទួលប្រាក់កម្ចី? | បុរស | ២៥% | ១០០% | ០% |
| | | ស្ត្រី | ៧៥% | ០% | ១០០% |
| ៥ | បុគ្គលដែលទទួលខុសត្រូវសំខាន់ក្នុងការស្វែងរកចំណូលសងប្រាក់កម្ចី? | បុរស | ១០០% | ៥០% | ១០០% |
| | | ស្ត្រី | ០% | ៥០% | ០% |
| ៦ | អ្នកដែលទទួលលុយពីស្ថាប័ន/អ្នកផ្តល់កម្ចី | បុរស | ០% | ១០០% | ០% |
| | | ស្ត្រី | ១០០% | ០% | ១០០% |
| ៧ | កាន់លុយយកទៅសង | បុរស | ០% | ១០០% | ០% |
| | | ស្ត្រី | ១០០% | ០% | ១០០% |

# VI. កាលានុវត្តភាព បញ្ហាប្រឈម និងតម្រូវការផ្ទែកសមត្ថភាព របស់គ្រួសារកសិករខ្នាតតូចឆ្ពោះទៅសហគមន៍សេដ្ឋកិច្ចអាស៊ាន

## *6.1. កាលានុវត្តភាពជាគន្លឹះ*

**ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសេវាដឹកជញ្ជូន៖** ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាចាប់ពីអណត្តិទី១ រហូតដល់អណត្តិទី៤[1] ផ្លូវជាតិ និងផ្លូវខេត្តត្រូវបានកសាង និងកែលម្អ។ គិតត្រឹមឆ្នាំ២០១៣ ផ្លូវជាតិដែលត្រូវបានកសាងមានប្រវែងសរុប ១១.២៩២ គីឡូម៉ែត្រ និងផ្លូវខេត្តប្រវែង ១០,៨១៩.៦៩ គីឡូម៉ែត្រ។ លើសពីនេះ ផ្លូវដែកកម្ពុជា២ខ្សែ ដែលមានប្រវែង៦៥០គីឡូម៉ែត្រ ក៏ត្រូវបានកសាងឡើងវិញ (វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០១៥)។

នៅស្រុកអូរយ៉ាដាវ និងស្រុកជុំគីរី ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ត្រូវបានចាត់ក្នុងចំណាត់ថ្នាក់ល្អ។ នៅស្រុកសន្ទុក ផ្លូវនៅក្នុងភូមិ ត្រូវបានចាត់ចំណាត់ថ្នាក់ក្នុងកម្រិតមធ្យម។ នៅភូមិមួយចំនួន ការធ្វើដំណើរដោយម៉ូតូ និងរថយន្តនៅរដូវវស្សាមានការលំបាក។

**បណ្តាញទូរគមនាគមន៍៖** ស្ថិតក្រោមកិច្ចការរបស់ក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ ក្រុមហ៊ុនទូរគមនាគមន៍ជាតិ និងអន្តរជាតិជាច្រើន មានវត្តមាននៅប្រទេសកម្ពុជា ក្រោមការបណ្តាក់ទុនរួមគ្នា និងមានតម្លៃសេវាប្រកួតប្រជែងគ្នាទាបផងដែរ។ ព័ត៌មានពីបណ្តាញសង្គមផ្សេងៗគ្នា ដូចជា វិទ្យុ ទូរទស្សន៍ក៏ទទួលបានផងដែរ។ ទូរស័ព្ទដៃ ដែលមានតម្លៃថោកសមរម្យ បង្កលក្ខណៈងាយស្រួលដល់កសិករអាចធ្វើទំនាក់ទំនងរវាងគ្នានឹងគ្នាបានកាន់តែប្រសើរ។ គិតត្រឹមឆ្នាំ២០១១ ទូរស័ព្ទចល័ត មានប្រមាណ ១៦.២លានគ្រឿង។ ចំនួននេះ បានកើនឡើងទ្វេរដង បើប្រៀបធៀបជាមួយស្ថិតិឆ្នាំ២០១០(NIS, 2015)។ ការអភិវឌ្ឍប្រព័ន្ធទូរគមនាគមន៍ បានជួយដល់កសិករ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរជាងមុន។ មុនពេលលក់ផលិតផលរបស់ខ្លួន កសិកររមែងទូរស័ព្ទសាកសួរតម្លៃលក់នៅទីតាំងទិញកសិផលផ្សេងៗមួយចំនួន។

---

[1] អាណត្តិទី១៖ ១៩៩៣-១៩៩៨ អាណត្តិទី២៖ ១៩៩៨-២០០៣ អាណត្តិទី៣៖ ២០០៣-២០០៨ អាណត្តិទី៤៖ ២០០៨-២០១៣

**ប្រព័ន្ធទីផ្សារនិងហេដ្ឋារចនាសម្ព័ន្ធទីផ្សារៈ** ក្នុងតំបន់គោលដៅសិក្សា ឈ្មួញក្នុងស្រុក និងពាណិជ្ជករ មានវត្តមាននៅទីតាំងទាំងនោះ។ កសិករជាច្រើន បានសាកសួរតម្លៃជាមួយនឹងឈ្មួញក្នុងស្រុក ឬពាណិជ្ជករ ១នាក់ ឬ២នាក់ មុនពេលសម្រេចចិត្តលក់កសិផលរបស់ខ្លួន។ នៅស្រុកសន្ទុក បែបផែនពាណិជ្ជកម្មផលិតផលដំឡូងមីបានផ្លាស់ប្តូរពីការលក់នៅក្នុងភូមិ ឬលក់នៅនឹងចម្ការ ទៅលក់នៅទីតាំងប្រមូលទិញដែលអាចស្រូបយកផលិតផលច្រើនចេញពីភូមិរណបផ្សេងៗ។ តាមរយៈការប្រើប្រាស់នូវការរៀបចំទីផ្សារដែលមានស្រាប់នេះ ទីតាំងប្រមូលទិញនីមួយៗ អាចទិញបានដំឡូងស្រស់ និងដំឡូងស្ងួតរាប់រយតោនសម្រាប់ការនាំចេញ។ ចំពោះគ្រាប់ស្វាយចន្ទីមានឈ្មួញជាច្រើនចូលទិញដល់ភូមិ មុនពេលផលិតផលនេះត្រូវបានដឹកជញ្ជូនទៅឲ្យឈ្មួញធំ ឬទៅកាន់ព្រំដែនកម្ពុជាវៀតណាម។ រូបភាពស្រដៀងគ្នានេះ ក៏ត្រូវបានប្រទះឃើញនៅតំបន់សិក្សានៃស្រុកជុំគីរី និងស្រុកអូរយ៉ាដាវផងដែរ។

**ឱកាសការងារក្រៅកសិកម្ម សម្រាប់ប្រាក់ចំណូលបន្ថែមក្នុងគ្រួសារៈ** ឱកាសសម្រាប់ការបង្កើតប្រាក់ចំណូលបន្ថែម ពីសកម្មភាពក្រៅកសិកម្មនៅក្នុង និងក្រៅតំបន់សិក្សា បានផ្តល់នូវដង្ហើមសេដ្ឋកិច្ចមួយបន្ថែមទៀត ចំពោះសេដ្ឋកិច្ចក្នុងតំបន់។ នៅស្រុកសន្ទុក ស្ត្រីមានឱកាសស្វែងរកចំណូលបន្ថែមនៅទីក្រុង ខណៈបុរសធ្វើការជាសំខាន់ក្នុងចម្ការក្នុងតំបន់មូលដ្ឋានរបស់ពួកគាត់។ បុរសភាគច្រើន អាចលក់កម្លាំងពលកម្ម នៅក្នុងចម្ការរបស់គ្រួសារដែលមានជីវភាពធូរធារ និងក្នុងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច។ នៅស្រុកជុំគីរី ឱកាសស្វែងរកចំណូលបន្ថែម តាមរយៈការលក់កម្លាំងពលកម្មនៅក្នុងការងារស្រែចម្ការ នៅមានកម្រិតបំផុត។ ទាំងបុរស និងស្ត្រី ធ្វើចំណាកស្រុកឆ្លងដែន ដើម្បីស្វែងរកឱកាសប្រាក់ចំណូល និងសម្រុកមកទីក្រុងដើម្បីការងារប្រាក់ឈ្នួល ក្នុងរោងចក្រកាត់ដេរ និងការងារសំណង់។

ប្រាក់ចំណូលពីការងារក្រៅកសិកម្ម បានចូលរួមចំណែកយ៉ាងធំចំពោះសេដ្ឋកិច្ចគ្រួសារ និងធ្វើឲ្យផលិតកម្មកសិកម្មមាននិរន្តរភាព។ ការធ្វើចំណាកស្រុករបស់សមាជិកគ្រួសារមិនត្រឹមផ្តល់ចំណូល ដើម្បីគ្របដណ្តប់ការចំណាយប្រចាំថ្ងៃ ក្នុងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែក៏បានប្រើប្រាស់សម្រាប់ការវិនិយោគលើធាតុចូលកសិកម្មផងដែរ។

**តារាងទី១៣៖ សង្ខេបការប៉ាន់ប្រមាណពីឱកាសជាគន្លឹះ ចំពោះគ្រួសារកសិករខ្នាតតូច**

| ល.រ | បរិយាយ | សន្ទុក | អូរយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|
| ១ | ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសេវាដឹកជញ្ជូន | មធ្យម | ល្អ | ល្អ |
| ២ | បណ្តាញទូរគមនាគមន៍ | ល្អ | ល្អណាស់ | ល្អណាស់ |
| ៣ | ប្រព័ន្ធទីផ្សារនិងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ | មធ្យម | ល្អ | ល្អ |
| ៤ | ឱកាសការងារក្រៅកសិកម្ម សម្រាប់ប្រាក់ចំណូលបន្ថែមក្នុងគ្រួសារ | ល្អ | ល្អ | ល្អណាស់ |

### *6.2. បញ្ហាប្រឈម និងឧបសគ្គជាគន្លឹះ*

**លទ្ធភាពទទួលបានមិនទាន់គ្រប់គ្រាន់ផ្នែកដីធ្លីកសិកម្ម និងទឹកសម្រាប់ស្រោចស្រព៖** នៅស្រុកជុំគីរី ប្រជាជនភាគច្រើនមានដីធ្លីតូចជាងតំបន់សិក្សាពីរផ្សេងទៀត។ ផលិតកម្មស្រូវ ពឹងផ្អែកជាសំខាន់លើរបបទឹកភ្លៀង។ ដំណាំពោតក្រហម ត្រូវបានអនុវត្តន៍នាពេលថ្មីៗដោយកសិករមួយចំនួនក្នុងតំបន់សិក្សា។ ផលិតកម្មស្រូវនៅឆ្នាំនេះ ផ្តល់ទិន្នផលទាបជាងបណ្តាឆ្នាំមុនៗ ហើយការចំណាយទៅលើផលិតកម្មមានការកើនឡើង អាស្រ័យដោយគ្រោះរាំងស្ងួតអូសបន្លាយ។ បញ្ហាអាកាសធាតុដ៏អាក្រក់នេះបានបង្កឲ្យការចំណាយទៅលើផលិតកម្មស្រូវមានការកើនឡើងខ្ពស់។

នៅស្រុកជុំគីរី ការជួលដីសម្រាប់ធ្វើកសិកម្ម មានការលំបាក អាស្រ័យដោយគ្រួសារនីមួយៗ មានដីតូច។ កសិករមួយចំនួនបានជួលដីនៅតំបន់ផ្សេងទៀត ឬនៅខេត្តផ្សេងសម្រាប់ធ្វើកសិកម្ម។ កសិករអត់ដី ដែលជួលដីក៏ត្រូវបានជួបប្រទះនៅស្រុកសន្ទុក និងអូរយ៉ាដាវផងដែរ។ នៅក្នុងខេត្តទាំងពីរនេះ ការទិញ និងការជួលដីអាចធ្វើទៅបាននៅឡើយ។ ទោះយ៉ាងនេះក្តី ជាការកត់សម្គាល់តម្លៃដី និងតម្លៃជួលដីសម្រាប់ផលិតកម្មមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ តម្លៃជួលដីជាមធ្យមក្នុងមួយហិកតាក្នុង១ឆ្នាំ មានតម្លៃ២០០ដុល្លារនៅស្រុកសន្ទុក និង៣០០ដុល្លារនៅស្រុកអូរយ៉ាដាវ។

**បម្រែបម្រួលតម្លៃទីផ្សារផលិតផលកសិកម្ម៖** ប្រភេទផលិតផលសំខាន់ៗ ដូចជា ស្រូវ មាន់ ជ្រូក ពោតក្រហម នៅស្រុកជុំគីរី ដំឡូងមី និងគ្រាប់ស្វាយចន្ទីនៅស្រុកសន្ទុក និងស្រុកអូរយ៉ាដាវ ត្រូវបានទិញដូរនៅនឹងទីតាំងចម្ការ និងនៅក្នុងភូមិ

ដឹកទៅតំបន់ខាងក្រៅ។ បើទោះណារចនាសម្ព័ន្ធទីផ្សារ មានវត្តមាននៅលើទីផ្សារយ៉ាងណាក៏ដោយ យើងមើលឃើញថា តម្លៃលក់ចេញផលិតផលកសិកម្មរបស់ប្រជាកសិករ មានការប្រែប្រួលជាញឹកញាប់គ្រប់ពេលវេលា ខណៈតម្លៃធាតុចូលកសិកម្មចេះតែបន្តឡើងថ្លៃ។ នៅស្រុកសន្ទុក តម្លៃទីផ្សារទិញចូល នៅនឹងទីតាំងប្រមូលទិញដំឡូងមីរ មានការប្រែប្រួលជាច្រើនដងក្នុងរយៈពេល១ថ្ងៃៗ ដែលបង្កនូវបញ្ហាលំបាកសម្រាប់កសិករ។ នៅស្រុកអូរយ៉ាដាវ មានឈ្មួញ/ពាណិជ្ជករជាច្រើន ក្នុងរដូវប្រមូលផលដំឡូងមី និងគ្រាប់ស្វាយចន្ទី ប៉ុន្តែតម្លៃទិញរបស់ឈ្មួញទាំងនោះ មិនមានភាពខុសប្លែកគ្នាជាការគួរឲ្យកត់សម្គាល់ទេ។

**តម្រូវការមូលធនដើម្បីវិនិយោគក្នុងផលិតកម្មកសិកម្ម៖** បច្ចុប្បន្ននេះ ការទទួលបានប្រាក់កម្ចី សម្រាប់ផលិតកម្មកសិកម្មមិនមានអ្វីជាការលំបាកទៀតទេ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារជាច្រើន មានវត្តមានតាមសេចក្តីត្រូវការ។ ប្លង់ដីត្រូវបានប្រើប្រាស់ជាទូទៅ ជាទ្រព្យបញ្ចាំដើម្បីទទួលបានកម្ចី។ នៅស្រុកសន្ទុក និងស្រុកជុំគីរី ដែលកសិករមួយចំនួនមិនមានប្លង់កម្មសិទ្ធិដីធ្លី កម្ចីជាក្រុមដែលមានសមាជិកពី៣ ទៅ៥នាក់ ត្រូវបានអនុវត្តន៍។ សមាជិកម្នាក់ៗ អាចទទួលបានកម្ចីរហូតដល់៥០០ដុល្លារ។ ចំពោះវដ្តនៃផលិតកម្ម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារបានសម្របសម្រួលកម្មវិធីកម្ចីដែលមានរយៈពេលសមស្រប តម្រូវទៅតាមវដ្តនៃផលិតកម្ម។ កសិករគ្រាន់តែបង់នូវការប្រាក់ប្រចាំខែរៀងរាល់ខែ និងប្រាក់កម្ចីដើម នៅរដូវប្រមូលផល។ អត្រាការប្រាក់ប្រចាំខែ មានតម្លៃចន្លោះពី ១.២ ទៅ៣.៥%ក្នុង១ខែ។

ជារឿយៗ កសិកររមែងបង្ខំចិត្តលក់ផលិតផលរបស់ខ្លួនភ្លាមៗ ក្រោយពីប្រមូលផលរួច ឬលក់នៅមុនពេលប្រមូលផលតែម្តង។ នេះដោយសារភាពជាក់ស្តែងថាកសិករត្រូវសងប្រាក់កម្ចី ក្រោយពីប្រមូលផលរួច។ បរាជ័យនៃការដាំដុះ បង្ខំចិត្តឲ្យកសិករស្វែងរកកម្ចីលើកទី២ ពីប្រភពកម្ចីផ្សេងទៀត ជាពិសេសពីអ្នកផ្តល់កម្ចីឯកជនដើម្បីសងប្រាក់បំណុលពីមុន។

នៅស្រុកជុំគីរី ជីគីមី១បាវមានតម្លៃ១២០.០០០រៀល នៅពេលដែលកសិករទិញដោយឲ្យប្រាក់ដល់ដៃ។ ទោះយ៉ាងណា កសិករភាគច្រើន ទិញបណ្តាក់សម្រាប់១វដ្តនៃផលិតកម្មស្រូវ ក្នុងតម្លៃ១៥០.០០០រៀល បន្ថែមស្រូវ៣០គីឡូក្រាមទៀត។

តម្លៃចំណេញ៣០,០០០រៀល និងស្រូវ៣០គីឡូក្រាម គឺជាការប្រាក់ដែលកំណត់យកដោយអ្នកលក់ជី។

នៅស្រុកសន្ទុក និងស្រុកអូរយ៉ាដាវ កសិករនីមួយៗទទួលប្រាក់កម្ចីជាមធ្យម ១,០០០ដុល្លារពីអ្នកផ្តល់កម្ចីឯកជន។ សំណងការប្រាក់និងប្រាក់ដើមខ្ចី ត្រូវបានធ្វើនៅពេលប្រមូលផលដំឡូងមី។ ក្នុងវដ្តនៃផលិតកម្មនេះ កសិករតម្រូវសងត្រឡប់ទៅវិញ ចំនួន១,៩០០ដុល្លារ។

**ធាតុចូលកសិកម្មដែលមានគុណភាព (គ្រាប់ពូជ ជី និងថ្នាំសម្លាប់សត្វល្អិត)៖** ចំពោះគ្រាប់ពូជ យើងរកឃើញថា កសិករនៅស្រុកជុំគីរី បានទទួលយកពូជស្រូវកែលម្អ ដើម្បីដាំដុះ នៅលើដីមួយចំនួនរបស់ពួកគាត់ ដែលជាពូជណែនាំដោយក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទខណៈដែលពូជពោតក្រហមត្រូវបានណែនាំដោយក្រុមហ៊ុនផ្គត់ផ្គង់ពូជ។ នៅស្រុកសន្ទុក កសិករបានទទួលយកពូជដំឡូងមី និងស្វាយចន្ទីបង្កាត់ ពិសេសពីអ្នកផ្គត់ផ្គង់កូនស្វាយចន្ទី ដែលភាគច្រើនមានដើមកំណើតពីខេត្តកំពង់ចាម។ ដោយឡែក ចំពោះជីគីមី និងថ្នាំបាញ់ ភាគច្រើនទិញមកពីផ្សារក្នុងតំបន់។ នៅស្រុកសន្ទុក ដោយសារកត្តាជំរុញនៃតម្រូវការទីផ្សារ ដំណាំស្វាយចន្ទីពូជទំនើប ត្រូវបានទទួលយក។ គ្រួសារដែលមានជីវភាពធូរធារ អាចមានលទ្ធភាពទទួលបានពូជទំនើប ខណៈគ្រួសារកសិករក្រីក្រមិនមានលទ្ធភាពប្រើប្រាស់ពូជទំនើប ហើយនៅតែដាំដុះប្រភេទពូជក្នុងស្រុក។ នៅស្រុកអូរយ៉ាដាវ ទាំងប្រភេទពូជក្នុងស្រុក និងពូជទំនើបត្រូវបានទទួលយកដាំដុះ។

លទ្ធភាពទទួលបានបច្ចេកទេសកសិកម្ម នៅក្នុងតំបន់គោលដៅសិក្សាទាំងបី មានភាពខុសគ្នាពីតំបន់មួយទៅតំបន់មួយ។ នៅស្រុកជុំគីរី កសិករភាគច្រើន ទទួលបានបច្ចេកទេសកសិកម្មពីមន្ត្រីនៃមន្ទីរកសិកម្មខេត្ត តាមរយៈគម្រោងដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ខណៈកសិករនៅស្រុកសន្ទុកទទួលបានបច្ចេកទេសកសិកម្ម ពីអ្នកចំណូលស្រុកពីខេត្តជិតខាង ពោលគឺខេត្តកំពង់ចាម។ នៅស្រុកអូរយ៉ាដាវ ការទទួលយកប្រភេទដំណាំណាមួយទៅអនុវត្តន៍ ត្រូវបានជំរុញដោយកត្តាតម្រូវការទីផ្សារ ក៏ប៉ុន្តែក៏ទទួលឥទ្ធិពលពីអ្នកចំណូលស្រុកផងដែរ។

នៅស្រុកជុំគីរី កសិករទទួលយកការដាំដុះដំណាំពោតក្រហម តាមរយៈវត្តមាននៃក្រុមហ៊ុនផ្គត់ផ្គង់ធាតុចូល។ ដោយប្រឈមនឹងគ្រោះធម្មជាតិ កាលពីឆ្នាំមុន

កសិករបានផ្លាស់ប្តូរពីការស្ទូងស្រូវ មកធ្វើស្រូវពង្រោះ ក្រោយពីសំណាបលើកទី១ របស់ពួកគាត់ វងការខូចខាតដោយគ្រោះរាំងស្ងួត។ លទ្ធភាពទទួលបានឯកសារណែនាំពីផលិតកម្មនេះ នៅមានកម្រិតនៅឡើយ។ កសិករទទួលដាំដុះដំណាំ ឬប្រើប្រាស់ធាតុចូលដោយពុំបានដឹងពីប្រសិទ្ធភាព និងផលប៉ះពាល់នាពេលអនាគតនៃការអនុវត្តទាំងនោះ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា បច្ចេកទេសកសិកម្ម នៅតែជាបញ្ហាសម្រាប់ពួកគាត់នៅឡើយ។

**តារាងទី១៥៖ សង្ខេបការវាយតម្លៃបញ្ហាប្រឈមនិងឧបសគ្គ ចំពោះគ្រួសារកសិករខ្នាតតូច**

| ល.រ | បរិយាយ | សន្ទុក | អូររយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|
| ១ | លទ្ធភាពទទួលបានដីធ្លីកសិកម្ម និងទឹកសម្រាប់ស្រោចស្រព | អន់ | អន់ | មធ្យម |
| ២ | លទ្ធភាពទទួលបានទីផ្សារសម្រាប់លក់ផលិតផលកសិកម្ម | ល្អ | ល្អ | មធ្យម |
| ៣ | លទ្ធភាពទទួលបានមូលធនដើម្បីវិនិយោគក្នុងផលិតកម្មកសិកម្ម | ល្អ | ល្អ | ល្អ |
| ៤ | លទ្ធភាពទទួលបានធាតុចូលកសិកម្មដែលមានគុណភាព (គ្រាប់ពូជ ជី និងថ្នាំបាញ់) និងបច្ចេកទេស | មធ្យម | មធ្យម | មធ្យម |

## *6.3. តម្រូវការផ្នែកសមត្ថភាព*

ដើម្បីធ្វើឲ្យកសិករ ដែលមានមុខរបរចិញ្ចឹមជីវិតផ្អែកលើការងារកសិកម្ម មានជីវភាពល្អប្រសើរ សមត្ថភាពដូចមានរៀបរាប់ខាងក្រោម គឺជាការចាំបាច់៖

**ការរួមគ្នា និងការរៀបចំជាសហគមន៍កសិកម្ម៖** គោលបំណងនៃការចងក្រងគ្រួសារកសិករខ្នាតតូច នឹងមិនត្រូវបានធ្វើឡើង ដើម្បីលទ្ធភាពទីផ្សារប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ដើម្បីបង្កើនផលិតភាពកសិកម្ម តាមរយៈសកម្មភាពរួមផងដែរ។

នៅស្រុកអូររយ៉ាដាវ ក្រុមសន្សំត្រូវបានណែនាំក្នុងតំបន់គោលដៅសិក្សា។នៅស្រុកជុំគីរី សហគមន៍ ប្រតិបត្តិការក្រោមកម្មវិធីសន្សំ និងឥណទាន ជាពិសេសការ

វិនិយោគក្នុងផលិតកម្មកសិកម្ម។ សហគមន៍ស្ថិតក្រោមជំនួយបច្ចេកទេស និងថវិកាពីគម្រោងអភិវឌ្ឍន៍នៃអង្គការមិនមែនរដ្ឋាភិបាល និងការសហការរវាងអង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរកសិកម្មខេត្ត។

**ចំណេះដឹងបច្ចេកទេសនៃការអនុវត្តកសិកម្មល្អ៖** សមត្ថភាពបច្ចេកទេសស្ដីអំពីការជ្រើសរើសពូជ ការគ្រប់គ្រងជីជាតិដី ការប្រើប្រាស់ធាតុចូលឲ្យបានត្រឹមត្រូវ មិនត្រឹមអាចបង្កើនផលិតភាពរបស់ដីប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ជួយឲ្យផលិតកម្មមាននិរន្តរភាពផងដែរ។ នៅស្រុកជុំគីរី ប្រជាជនបានចាប់អនុវត្តដំណាំពោតក្រហម នៅលើដីដែលទើបរៀបចំនៅក្បែរតំបន់ភ្នំ។ គ្រាប់ពូជត្រូវបានណែនាំ ដោយក្រុមហ៊ុនផ្គត់ផ្គង់គ្រាប់ពូជ ប៉ុន្តែបច្ចេកទេសនៅក្នុងការដាំដុះនិងគ្រប់គ្រងដំណាំ ទទួលបានជាពិសេសពីកសិករដែលធ្លាប់មានបទពិសោធន៍ពីក្រៅខេត្ត បូករួមនឹងបច្ចេកទេសដាំដុះពោតសដែលកសិករនៅតំបន់នេះ ធ្លាប់បានអនុវត្តកន្លងមក។ ការប្រើប្រាស់ធាតុចូលគីមី រួមមាន ជី និងថ្នាំសម្លាប់សត្វល្អិត ត្រូវបានមើលឃើញថា ពុំបានគិតគូរពីផលប៉ះពាល់នាពេលបច្ចុប្បន្ន និងអនាគតទៅលើគុណភាពផលិតផលនិងជីជាតិដីឡើយ។

**ការបង្កើតនូវប្រព័ន្ធផលិតកម្មស្បៀងសម្រាប់ទ្រទ្រង់គ្រួសារបានដោយខ្លួនឯង៖**

ការបង្កើតនូវប្រព័ន្ធផលិតកម្មស្បៀងសម្រាប់ទ្រទ្រង់គ្រួសារបានដោយខ្លួនឯង គឺដើម្បីធានានូវសុវត្ថិភាព និងអធិបតេយ្យភាពស្បៀងរបស់គ្រួសារ តាមរយៈការធ្វើចម្រុះកម្មផលិតកម្ម និងប្រាក់ចំណូល។ ទោះយ៉ាងណាក្ដី ប្រព័ន្ធនេះមិនសូវបានជួបប្រទះទេ នៅក្នុងតំបន់គោលដៅនៃការសិក្សា។ ការផ្លាស់ប្ដូរទៅកាន់ដំណាំឧស្សាហកម្មប្រចាំឆ្នាំ និងដំណាំច្រើនឆ្នាំ ដូចជាដំឡូងមី ឬស្វាយចន្ទី ដែលជាទូទៅត្រូវបានជំរុញដោយតម្រូវការផ្នែកទីផ្សារ បានផ្លាស់ប្ដូរកសិករឲ្យទៅអភិវឌ្ឍន៍ការអនុវត្តកសិកម្មតែមួយមុខ។ កសិករនាពេលថ្មីៗ ដឹកនាំខ្លួនពួកគេទៅរកភាពពឹងអាស្រ័យលើស្បៀងអាហារមកពីខាងក្រៅ។

នៅស្រុកជុំគីរី កសិករបានអនុវត្តន៍កសិកម្មដែលមានលក្ខណៈចម្រុះជាងកសិករនៅតំបន់គោលដៅសិក្សាពីរផ្សេងទៀត។ ផលិតកម្មស្រូវ ពោតស និងពោតក្រហម ការជីកស្រះចិញ្ចឹមត្រី បន្លែ ដូង ការចិញ្ចឹមសត្វ និងការធ្វើចំណាកស្រុកសម្រាប់ប្រាក់ចំណូលបន្ថែម ត្រូវបានអង្កេតឃើញច្រើននៅស្រុកជុំគីរី ជាងនៅតំបន់គោលដៅសិក្សាពីរផ្សេងទៀត។

**អក្ខរភាពហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់គ្រួសារ៖** ការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវប្រាក់ចំណូល ដើម្បីធ្វើហិរញ្ញប្រទានដល់គម្រោងអភិវឌ្ឍន៍គ្រួសារ និងការចំណាយផ្សេងៗក្នុងគ្រួសារ រួមនឹងការបង្កើតនូវប្រាក់ចំណូលជាប្រចាំ គឺជាការសំខាន់។ នៅក្នុងការលេចឡើងនូវកសិកម្មបែបពាណិជ្ជកម្ម កសិករបានបង្កើតនូវការផ្លាស់ប្តូរពីផលិតកម្ម ដើម្បផ្គត់ផ្គង់ក្នុងគ្រួសារ មកដំណាំសម្រាប់ពាណិជ្ជកម្ម ពិសេសដំណាំដែលជំរុញដោយតម្រូវការទីផ្សារ។

នៅស្រុកសន្ទុក និងស្រុកអូរយ៉ាដាវ កសិករមានទំនោរផ្តោតលើផលិតកម្មដំឡូងមីរ។ ប្រសិនកសិករទាំងនោះមានលទ្ធភាព ពួកគេនឹងបន្តទៅមុខ ដោយដាំដុះដំណាំស្វាយចន្ទី។ នៅស្រុកអូរយ៉ាដាវ ផលិតកម្មស្រូវចម្ការស្ទើរបាត់បង់ ហើយត្រូវបានជំនួសដោយដំណាំប្រចាំឆ្នាំ និងដំណាំច្រើនឆ្នាំ ដូចជាដំឡូងមី និងស្វាយចន្ទី។ កសិករទទួលបានចំណូលច្រើន ពីផលិតកម្មរបស់ពួកគាត់ក្នុងពេលតែមួយ ហើយត្រូវចំណាយច្រើនទៅវិញភ្លាមៗ។ ការអនុវត្តរបៀបនេះ ធ្វើឲ្យកសិកររមែងជួបនូវបញ្ហាកង្វះហិរញ្ញវត្ថុ។ នៅពេលនោះ កសិករត្រូវខ្ចីប្រាក់ ដែលនាំឲ្យពួកគាត់ជាប់ក្នុងអន្ទាក់បំណុល។ ហេតុនេះ សមត្ថភាពអក្ខរភាពហិរញ្ញវត្ថុ និងការគ្រប់គ្រងចរន្តសាច់ប្រាក់ គឺជាការចាំបាច់បំផុត។

**តារាងទី១៥៖ សង្ខេបពីការវាយតម្លៃទៅលើសមត្ថភាពជាតម្រូវការសំខាន់សម្រាប់គ្រួសារកសិករខ្នាតតូច**

| ល.រ | បរិយាយ | សន្ទុក | អូរយ៉ាដាវ | ជុំគីរី |
|---|---|---|---|---|
| ១ | ការរួមគ្នា និងការរៀបចំជាសហាគមន៍កសិកម្ម | ត្រូវការបំផុត | ត្រូវការបំផុត | ត្រូវការបំផុត |
| ២ | ចំណេះដឹងបច្ចេកទេសនៃការអនុវត្តកសិកម្មល្អ | ត្រូវការ | ត្រូវការ | ត្រូវការ |
| ៣ | ការបង្កើតនូវប្រព័ន្ធផលិតកម្មស្បៀងសម្រាប់ទ្រទ្រង់គ្រួសារបានដោយខ្លួនឯង | ត្រូវការបំផុត | ត្រូវការបំផុត | ត្រូវការបំផុត |
| ៤ | អក្ខរភាពហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់គ្រួសារ | ត្រូវការ | ត្រូវការ | ត្រូវការ |

## VII. បញ្ហាកំពុងវិវឌ្ឍន៍ និងទំនាក់ទំនង ចំពោះគ្រួសារកសិករខ្នាតតូច

ក្រៅពីគោលនយោបាយ និងក្របខណ្ឌគាំទ្រនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន និងរាជរដ្ឋាភិបាល ចំពោះគ្រួសារកសិករខ្នាតតូច វាមានសារសំខាន់នៅក្នុងការលើកយកបញ្ហាដែលកំពុងវិវឌ្ឍន៍ និងទំនាក់ទំនងរបស់វា ចំពោះគ្រួសារកសិករខ្នាតតូច។ អត្ថបទសិក្សា អត្ថបទស្រាវជ្រាវ និងគំនិតនៃអ្នកផ្ដល់ព័ត៌មានសំខាន់ៗ ត្រូវបានច្របាច់បញ្ចូលនៅក្នុងផ្នែកនេះ។ ជាពិសេស វាបានកសាងនូវការជជែកវែកញែកស្ដីពីភាពត្រឹមត្រូវ និងភាពសមស្របសម្រាប់គ្រួសារកសិករខ្នាតតូច និងអ្នកដែលមានដីធ្លីធំ។

### *7.1. បណ្ណកម្មសិទ្ធិដីធ្លី និងសន្តិសុខនៃការកាន់កាប់ដីធ្លី*

នៅតំបន់ទំនាប ការធ្វើកសិកម្មជាលក្ខណៈសមូហភាព ត្រូវបានអនុវត្តន៍នៅក្នុងកំឡុងឆ្នាំ១៩៨០ ក្រោយពីរបបខ្មែរក្រហម ហើយបន្ទាប់មកទ្រព្យសម្បត្តិជាលក្ខណៈឯកជន ត្រូវបានអនុវត្តនៅចុងឆ្នាំ១៩៨០។ បណ្ណសម្គាល់ការបែងចែកដីធ្លី ត្រូវបានផ្ដល់ឲ្យដោយអាជ្ញាធរមូលដ្ឋាន ជាញឹកញាប់ដោយអាជ្ញាធរកម្រិតឃុំ ដែលផ្ដល់សិទ្ធិដល់អ្នកកាន់កាប់ដី។ រដ្ឋបាលដីធ្លី នៅតំបន់ខ្ពង់រាប និងតំបន់ព្រៃ មិនត្រូវបានគ្រប់គ្រងបានត្រឹមត្រូវឡើយ ជាពិសេសរវាងដីកសិកម្ម និងដីព្រៃ ដែលប្រជាជនធ្វើកសិកម្មពនេចរ។ ការបែងចែកដីនៅតំបន់ភ្នំ និងតំបន់ព្រៃ មិនដែលធ្លាប់បានអនុវត្តរហូតឆ្នាំ២០១២ នៅពេលបទបញ្ជា០១បប ដើម្បីដោះស្រាយទំនាស់ដីធ្លីត្រូវបានចេញ។

នៅតំបន់ភ្នំ និងតំបន់ព្រៃ ការប្រើប្រាស់ដីក្នុងសហគមន៍ជនជាតិដើមភាគតិច ត្រូវបានអនុវត្ត ដោយផ្អែកលើការកាន់កាប់ដីជាលក្ខណៈប្រពៃណី ដែលបានធ្វើការបែងចែកជាដីកសិកម្ម ដីកប់សព ដីអភិរក្សទឹក ដីបម្រុងទុក និងដីទំនេរ។ល។ គួរកត់សម្គាល់ថា ការកាន់កាប់ដីជាលក្ខណៈប្រពៃណី ត្រូវបានទទួលស្គាល់ពេញលេញនៅក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១។ ប៉ុន្តែនៅក្នុងការអនុវត្ត សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ដើម្បីទាមទារនូវការកាន់កាប់ជាលក្ខណៈប្រពៃណី សម្រេចបានតិចតួចបំផុត អាស្រ័យដោយក្រមច្បាប់លក្ខន្តិកៈនៃព្រះរាជាណាចក្រកម្ពុជា។ ផ្ទុយទៅវិញ អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច ត្រូវបានចេញនៅឆ្នាំ២០០៥ ហើយត្រូវបានអនុវត្តយ៉ាងសកម្ម ក្នុងកំឡុងឆ្នាំ២០០០ដល់២០១០។ នេះបានបង្កើតឲ្យមាននូវបញ្ហាដ៏ច្រើនលើសលប់នៃជម្លោះដីធ្លី នៅក្នុងប្រទេស ជាពិសេស វាបានរំលោភសិទ្ធិជាលក្ខណៈប្រពៃណីរបស់របស់ជនជាតិដើមភាគតិចយ៉ាងច្បាស់ ដូចដែលបានបញ្ជាក់នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១។

លើសពីនេះ ប្រសិនណាអ្នកកាន់កាប់ដីអាចអះអាងថា ពួកគេបានកាន់កាប់ដី និងប្រើប្រាស់ដីតាំងពីមុនឆ្នាំ២០០១នោះ ពួកគាត់មានសិទ្ធិទាមទារនូវភាពជាកម្មសិទ្ធិនៃដីនោះ។ ឯកសារដែលប្រើប្រាស់កាលបរិច្ឆេទតាំងពីមុនៗ នៃការផ្ទេរដីធ្លី ត្រូវបានអនុវត្តន៍ដើម្បីផ្តល់ភាពស្របច្បាប់នៃភាពជាម្ចាស់នៃដីធ្លី តាមរយៈច្បាប់ភូមិបាលឆ្នាំ២០០១។ ការកាន់កាប់ដីជាលក្ខណៈប្រពៃណី ដែលត្រូវបានអនុវត្តន៍ដោយប្រជាជនជនជាតិដើមភាគតិច ប្រឈមនឹងការបាត់បង់ដីធ្លីដោយសារថា ពួកគាត់មិនមានឯកសារស្របច្បាប់ណាមួយ ដើម្បីអះអាងនូវភាពជាកម្មសិទ្ធិរបស់ពួកគាត់ទេ។ ក្នុងការដោះស្រាយជម្លោះដីធ្លី អ្នកខាងក្រៅដែលអាចផ្តល់នូវភស្តុតាង នៃការកាន់កាប់ដីតាមរយៈឯកសារទិញលក់ ឬឯកសារចលនាដីធ្លីផ្សេងៗទៀត រមែងទទួលជោគជ័យក្នុងករណីជម្លោះ ទាំងតាមរយៈដំណោះស្រាយជម្លោះផ្សេងៗ ឬដំណោះស្រាយតាមប្រព័ន្ធតុលាការ។ ទំនាស់ដីធ្លីនៅដើមឆ្នាំ២០១០ នៅសហគមន៍តំបន់ភ្នំ សិទ្ធិកាន់កាប់ដីធ្លីជាលក្ខណៈប្រពៃណី មិនត្រូវបានយកមកពិភាក្សា ឬលើកឡើងកំឡុងដំណោះស្រាយទំនាស់ឡើយ។ ជាលទ្ធផល សហគមន៍ជនជាតិដើមភាគតិច អាចទទួលបានដីតែនៅទីតាំងដែលពួកគាត់កំពុងប្រើប្រាស់ប៉ុណ្ណោះ កំឡុងបេសកកម្មនិស្សិត សម្រាប់ការដោះស្រាយទំនាស់ដីធ្លី (បទបញ្ជា០១បប) ប៉ុន្តែដីដែលពួកគាត់បម្រុងទុក មិនទទួលបានឡើយ។

ចាប់តាំងពីថ្ងៃបរិច្ឆេទចេញច្បាប់ភូមិបាលឆ្នាំ២០០២ ដល់ឆ្នាំ២០១២ នយោបាយស្តីអំពីការកាន់កាប់ដីធ្លី និងការរឹបអូសដី បានកើតឡើង ដែលជាប់ពាក់ព័ន្ធតួអង្គជាច្រើនផ្សេងៗគ្នា ពីកម្រិតផ្សេងៗគ្នា៖ អ្នកនៅថ្នាក់កណ្តាល និងថ្នាក់ជាតិ និងអន្តរជាតិផងដែរ។ ជាលទ្ធផល ប្រជាជនដែលរស់នៅតំបន់ភ្នំ និងតំបន់ព្រៃ ដែលមានដីច្រើនហូរហៀរនៅពេលមុន បានផ្លាស់ប្តូរទៅរកភាពខ្សត់ដីនាពេលបច្ចុប្បន្ន តែក្នុងរយៈពេល ១០ឆ្នាំប៉ុណ្ណោះ។ កិច្ចខិតខំប្រឹងប្រែង ចំពោះការកាន់កាប់ដីជាលក្ខណៈប្រពៃណីនៅកម្ពុជា ស្ទើរតែបញ្ចប់ទៅទាំងស្រុង បន្ទាប់ពីការអនុវត្តបទបញ្ជា០១បប។ បទបញ្ជា០១បប អនុញ្ញាតិឲ្យអ្នកកាន់កាប់ដី ឬអ្នកប្រើប្រាស់ដី ដើម្បីប្រកាសទាមទារនូវបណ្ណកម្មសិទ្ធិជាលក្ខណៈបុគ្គល។ ម៉្យាងបទបញ្ជា០១បប បានលើកទឹកចិត្តដល់ប្រជាសហគមន៍ជនជាតិដើមភាគតិច ក្នុងរូបភាពមិនផ្ទាល់ ឲ្យទទួលយកភាពជាម្ចាស់លក្ខណៈបុគ្គល ឯម៉្យាងទៀត វាបានបំបាក់ទឹកចិត្តប្រជាសហគមន៍ជនជាតិដើមភាគតិច មិនឲ្យទទួលយកប្លង់ដីឃុំឡើយ។ ការនេះបានបង្កើតនូវការផ្លាស់ប្តូរ ការអនុវត្តការអភិបាលកិច្ចដីធ្លីនៅក្នុងសហគមន៍ជនជាតិដើមភាគតិច។

ហេតុដូច្នេះ ការស្វែងចេញនូវបញ្ហាសន្តិសុខដីធ្លី នៅមានសភាពធ្ងន់ធ្ងរ សម្រាប់កិច្ចអភិវឌ្ឍកសិកម្មនៅឡើយ ពិសេសគ្រួសារកសិករខ្នាតតូច គឺជាក្រុមដែលទទួលរងដោយផ្ទាល់ ដោយសារថា ពួកគាត់នៅមិនទាន់មានសន្តិសុខផ្នែកដីធ្លីនៅឡើយ។ ករណីសិក្សាពីស្រុកសន្ទុក ខេត្តកំពង់ធំ គឺជាការផ្តល់ដំណឹងមួយយ៉ាងល្អ ស្តីអំពីអសន្តិសុខផ្នែកដីធ្លី សម្រាប់ប្រជាសហគមន៍ ដែលបានកាន់កាប់ដី ដោយពុំមានការទទួលស្គាល់ត្រឹមត្រូវ។ នេះនឹងបន្ថយល្បឿននៃការអភិវឌ្ឍកសិកម្មគ្រួសារ។ ករណីសិក្សានៅស្រុកអូរយ៉ាដាវ ខេត្តរតនគីរី ផ្តល់ព័ត៌មានស្តីអំពីការផ្លាស់ប្តូរបរិបទពីភាពសំបូរហូរហៀរផ្នែកដីធ្លី ទៅកាន់ភាពក្រខ្សត់នៃដីធ្លីសម្រាប់ជនជាតិដើមភាគតិច។

## *7.2. ប្រព័ន្ធស្រោចស្រពខ្នាតធំ និងមធ្យម និងប្រព័ន្ធស្រោចស្រពខ្នាតតូច*

ដោយសារថា ការធ្វើស្រែនៅកម្ពុជាជាទំនៀមទម្លាប់ ពឹងផ្អែកលើរបបទឹកភ្លៀងជាជាងប្រព័ន្ធស្រោចស្រព ការបែងចែករបបទឹកភ្លៀងជាកត្តាកំណត់នូវភាពជោគជ័យ និងទំហំនៃការប្រមូលផល (Wokker et al., 2011)។ ដោយមានជំនឿថា សេណារីយ៉ូផលិតកម្មនេះ មានសក្តានុពលជាសំខាន់ សម្រាប់ការទទួលបាននូវទិន្នផលតាមរយៈការផ្តល់នូវទឹកស្រោចស្រព រដ្ឋាភិបាលបានវិនិយោគយ៉ាងច្រើនក្នុងកិច្ចអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ក្នុងពីរទសវត្សរ៍កន្លងទៅនេះ។ ស្ថិតិពីក្រសួងធនធានទឹក និងឧតុនិយមបានបង្ហាញថា នៅត្រឹមឆ្នាំ២០១០ ផ្ទៃដីទំហំ១,១២០,២៤៦ហិកតា(ស្រូវប្រាំងចំនួន ៣៤៧,០៥៨ហិកតា និងស្រូវវស្សាចំនួន ៧៧៣,១៨៨ហិកតា) ត្រូវបានស្រោចស្រព ដែលទិន្នន័យនេះ មានចំនួនប្រមាណ៤៣% នៃផ្ទៃដីដាំដុះស្រូវសរុប (CDRI 2010)។ចំនួននេះ ជាប់ទាក់ទិនទៅនឹងការស្តារឡើងវិញ នូវទម្រង់ស្រោចស្រពដែលមានស្រាប់ជាច្រើន ជាមួយនឹងការគាំទ្រផ្នែកថវិកាពីម្ចាស់ជំនួយបរទេស និងភ្នាក់ងារផ្តល់ជំនួយផ្សេងៗ (Thuon et al., 2007)។

យុទ្ធសាស្ត្រកសិកម្ម និងទឹក មានទិសដៅកាត់បន្ថយនូវភាពក្រីក្រ បង្កើននូវសន្តិសុខស្បៀង និងការលូតលាស់ផ្នែកសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ រហូតមកដល់ពេលបច្ចុប្បន្ន យុទ្ធសាស្ត្របានផ្តោតសំខាន់លើទម្រង់ស្រោចស្រពខ្នាតធំ និងមធ្យម ដែលមានទិសដៅសំខាន់សម្រាប់ផលិតកម្មស្រូវ ដើម្បីបំពេញទិសដៅនាំអង្ករចេញ។ រដ្ឋាភិបាលកម្ពុជាបានកំណត់ថា កសិកម្មនិងការអភិវឌ្ឍជនបទ ជាបញ្ហាអាទិភាពក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ និងការលូតលាស់ផ្នែកសេដ្ឋកិច្ច។ ចំណុចពាក់ព័ន្ធនៃកសិកម្ម ចំពោះអាទិភាពនេះ គឺថា

ប្រជាពលរដ្ឋកម្ពុជាជាង ៨០% រស់នៅតំបន់ជនបទ ហើយការប្រកបរបរចិញ្ចឹមជីវិតមានមូលដ្ឋានគ្រឹះលើការងារកសិកម្ម។

- ប្រព័ន្ធស្រោចស្រពខ្នាតតូច (ផ្ទៃដីស្រោចស្រព < ២០០ហិកតា)៖ ប្រព័ន្ធនេះ គ្រប់គ្រងដោយការិយាល័យធនធានទឹកនិងឧត្តុនិយមថ្នាក់ស្រុក ឬថ្នាក់ខេត្ត ប្រសិនបើប្រព័ន្ធនេះ ស្ថិតនៅច្រើនជាងមួយស្រុក វាមានដំណើរការ និង ត្រូវបាន ថែទាំដោយអ្នកទទួលផលក្រោមការត្រួតពិនិត្យរបស់ការិយាល័យធនធានទឹក និងឧត្តុនិយមថ្នាក់ស្រុក)។
- ប្រព័ន្ធស្រោចស្រពខ្នាតមធ្យម (ផ្ទៃដីស្រោចស្រពចន្លោះពី ២០០ ទៅ ៥០០ ហិកតា)៖ ប្រព័ន្ធនេះ គ្រប់គ្រងដោយមន្ទីរធនធានទឹកនិងឧត្តុនិយមខេត្ត ឬ ដោយក្រសួងធនធានទឹកនិងឧត្តុនិយម ប្រសិនប្រព័ន្ធនេះ ស្ថិតនៅច្រើនជាងមួយខេត្ត។ វាស្ថិតក្រោមការថែទាំរបស់មន្ទីរធនធានទឹក និង ឧត្តុនិយមខេត្ត សហការជាមួយ អ្នកប្រើប្រាស់ និងជួសជុលដោយក្រសួងធនធានទឹក និងឧត្តុនិយម។
- ប្រព័ន្ធស្រោចស្រពខ្នាតធំ ( > ៥,០០០ហិកតា)៖ ប្រព័ន្ធនេះត្រូវបានគ្រប់គ្រង និង ថែទាំដោយក្រសួងធនធានទឹកនិងឧត្តុនិយម។

*ប្រភព៖ CDRI ២០០៨*

មកដល់ពេលបច្ចុប្បន្ន ការវិនិយោគលើប្រព័ន្ធស្រោចស្រពខ្នាតធំ និងខ្នាតមធ្យម ត្រូវបានទទួលស្គាល់ថាជាការល្អ តែនៅមិនទាន់គ្រប់គ្រាន់ទេ។ យោងតាមឯកសារចង្អុលទិសសហគមន៍សេដ្ឋកិច្ចអាស៊ាន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ពាណិជ្ជូបនីយកម្ម និងពិពិធូបនីយកម្មកសិកម្ម បានផ្លាស់ប្តូរទម្រង់នៃកសិកម្មកម្ពុជាពីកសិកម្ម ដែលមានមូលដ្ឋានលើដំណាំស្រូវមកជាកសិកម្មដែលមានមូលដ្ឋានមិនមែនស្រូវ ដើម្បីទាក់ទាញបាននូវតម្លៃទីផ្សារដែលប្រសើរជាងមុន និងធ្វើឲ្យការប្រកបរបរចិញ្ចឹមជីវិតបានប្រសើរឡើង។ ការដាំបន្លែនៅតំបន់ទំនាប ជាពិសេសនៅរដូវប្រាំងត្រូវជួបនឹងកង្វះទឹក និងកង្វះលទ្ធភាពទទួលបានទឹកពីទម្រង់ស្រោចស្រព។ គោលនយោបាយ និងការលើកកម្ពស់ប្រព័ន្ធស្រោចស្រពខ្នាតតូចពីស្រះបុគ្គល ឬស្រះសហគមន៍នៅមិនទាន់មាននៅឡើយ។ វេទិកាកសិករថ្នាក់ជាតិឆ្នាំ២០១៦ បានលើកឡើងពីសារសំខាន់នៃប្រព័ន្ធស្រោចស្រពខ្នាតតូចដែលកសិករអាចទទួលបាន ដើម្បីធ្វើឲ្យប្រសើរឡើងនូវផលិតកម្មក្នុងគ្រួសារ ឆ្ពោះ

ទៅដល់សន្តិសុខស្បៀងក្នុងគ្រួសារ និងប្រាក់ចំណូលសម្រាប់បង្កើនជីវភាពរស់នៅផងដែរ។

ផលិតកម្មដំណាំទីផ្សារមិនមែនស្រូវកំពុងជួបប្រទះនូវកង្វះទឹក ឬទម្រង់នៃការស្រោចស្រព។ កសិករដែលមានជីវភាពធូរធារ បានវិនិយោគលើការជីកប្រព័ន្ធស្រោចស្រពជា លក្ខណៈបុគ្គល ដោយការផ្លាស់ប្តូរទីជំរាល ឬជ្រលងភ្នំ(ច្រប់) មកជាអាងស្តុកឯកជន។ មួយផ្នែកការនេះអាចនាំឲ្យមានការប្រែប្រួលនូវមីក្រូបរិស្ថាន និងបង្កនូវភាពខ្សត់ទឹក ប៉ុន្តែក៏បង្កើតនូវផលប៉ះពាល់អវិជ្ជមានដល់គ្រួសារក្រីក្រ ដែលពឹងអាស្រ័យលើទឹកដើម្បីប្រើប្រាស់ប្រចាំថ្ងៃ និងការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារផងដែរ។ មួយផ្នែកទៀត វាបានបង្កើតនូវភាពអយុត្តិធម៌សង្គម ដែលធនធានទឹកសាធារណៈ ត្រូវបានប្រែក្លាយជាកម្មសិទ្ធិឯកជនផ្តាច់មុខ។ ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពខ្នាតតូច និងអភិបាលកិច្ចទីតាំងស្តុកទឹកធម្មជាតិឲ្យបានល្អប្រសើរជាងមុន មានសារសំខាន់ដើម្បីរក្សាបាននូវអត្ថប្រយោជន៍ចំពោះគ្រួសារកសិករខ្នាតតូច និងសន្តិសុខស្បៀងក្នុងតំបន់ និងការអភិវឌ្ឍសេដ្ឋកិច្ច។

## *7.3. ការវិនិយោគផ្ទាល់ពីបរទេស និងការវិនិយោគផ្ទាល់ក្នុងស្រុក*

លំហូរដោយសេរីនៃការវិនិយោគពីប្រទេសអាស៊ាន គឺជាសរសរស្តម្ភនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន។ វាត្រូវបានរំពឹងទុកថា កម្ពុជានឹងទទួលបាននូវការវិនិយោគផ្ទាល់ពីបរទេស ដើម្បីជំរុញនូវសេដ្ឋកិច្ចជាតិ និងការបង្កើតការងារសម្រាប់កម្លាំងពលកម្មកម្ពុជា។ រហូតមកដល់ពេលបច្ចុប្បន្ន ផ្ទៃដីជាង១លានហិកតាត្រូវបានផ្តល់ឲ្យក្រុមហ៊ុនឯកជន រួមទាំងក្រុមហ៊ុនបរទេស ដែលរំពឹងថានឹងបង្កើតការងារសម្រាប់យុវជនជនបទតែផ្ទុយទៅវិញ វាបានបង្កនូវទំនាស់ដីធ្លីជាច្រើន ជាមួយប្រជាសហគមន៍ជនបទ។ លើសពីនេះ ក្រុមហ៊ុនជាច្រើនមិនអាចដំណើរការងារបានតាមផែនការរបស់ពួកគេទេ។

នៅខែឧសភា ឆ្នាំ២០១២ នាយករដ្ឋមន្ត្រីបានចេញនូវបទបញ្ជា០១បប ដើម្បីផ្អាកនូវរាល់ការអនុម័តលើរាល់សម្បទានដីសេដ្ឋកិច្ចថ្មី និងបានអំពាវនាវឲ្យមានការត្រួតពិនិត្យមើលឡើងវិញនូវក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចទាំងឡាយដែលមានស្រាប់[2]។

---

[2] អ៊ឹម ឈុនលឹម (២០១២)៖ សុន្ទរកថារបស់ឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ក្នុងកិច្ចប្រជុំលើកទី១៩ របស់គណៈកម្មការសម្របសម្រួលរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ នៅទីក្រុងភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២។

យោងតាមបទបញ្ញា០១បប ដីសម្បទានសេដ្ឋកិច្ចទាំងឡាយណាដែលមិនស្របនឹងច្បាប់ កិច្ចសន្យាទាំងនោះនឹងត្រូវរឹបអូស (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១២)។ នៅខែកក្កដា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចំនួន១៦ ស្ថិតនៅក្រោមការសើរើឡើងវិញ ហើយដីសម្បទានសេដ្ឋកិច្ចដែលមានរយៈពេលជួលច្រើនជាង៧០ឆ្នាំ ត្រូវបានកាត់បន្ថយមកនៅត្រឹម៥០ឆ្នាំ (Taing Vida., 2015)។

ផ្ទុយទៅវិញ កសិករធ្វើស្រែខ្នាតតូច ដែលស្ថិតក្រោមការគាំទ្ររបស់បណ្ដាញកសិករនិងធម្មជាតិ និងមជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) បានកៀងគរនូវធនធានរបស់ខ្លួន ដើម្បីវិនិយោគលើរោងម៉ាស៊ីនកិនស្រូវ ដោយមានស្តង់ដារអន្តរជាតិ សម្រាប់ការនាំចេញទៅបរទេស។ រហូតមកដល់ពេលបច្ចុប្បន្ន រោងម៉ាស៊ីនកិនស្រូវចំនួន០៧ត្រូវបានតម្លើង និងកំពុងតែដំណើរការ។ គួរកត់សម្គាល់ថា សេដាកបានសម្របសម្រួលការប្រជុំជាមួយសមាគមកសិករ និងថ្នាក់ដឹកនាំសហគមន៍កសិកម្មមកពីស្រុកចំនួន៦០ ដែលស្ថិតនៅក្រោមឆ័ត្ររបស់បណ្ដាញកសិករ និងធម្មជាតិ ដើម្បីបង្កើតនូវសហគមន៍រោងម៉ាស៊ីនកិនស្រូវ។ ច្បាប់ដែលបានរៀបចំបានកំណត់ថា ចំនួនរោងម៉ាស៊ីនកិនស្រូវនឹងត្រូវបង្កើតឡើង អាស្រ័យលើមូលនិធិដែលបានកៀងគរចេញពីសមាជិកថ្នាក់ស្រុកនីមួយៗ។ លើសពីនេះ សហគមន៍ថ្នាក់ស្រុកណាដែលអាចកៀងគរថវិកាបានច្រើនជាងគេពីសមាជិករបស់ខ្លួន នឹងត្រូវផ្តល់អាទិភាពទទួលបានថវិកា ដើម្បីសាងសង់រោងម៉ាស៊ីនស្រូវក្នុងស្រុករបស់ពួកគាត់។ ប្រាក់ចំណេញដែលទទួលបានពីអាជីវកម្មរោងម៉ាស៊ីនស្រូវនេះ បានធ្វើការបែងចែកក្នុងចំណោមសមាជិកសហគមន៍ថ្នាក់ស្រុកទាំង៦០ អាស្រ័យតាមចំនួនភាគហ៊ុនរបស់ពួកគេ។ គួរកត់សម្គាល់ថា ការកៀងគរមូលនិធិនឹងត្រូវធ្វើឡើងជាបន្តបន្ទាប់រៀងរាល់ឆ្នាំ ហើយសហគមន៍រោងម៉ាស៊ីនស្រូវបន្ទាប់ផ្សេងទៀត ត្រូវបានរំពឹងទុកថានឹងត្រូវបានបង្កើតឡើងតាមរយៈច្បាប់ដូចគ្នានេះ។

ដូច្នេះវាមានសារសំខាន់ណាស់ ដើម្បីផ្តល់នូវតម្លៃ និងគាំទ្រតួនាទីរបស់គ្រួសារកសិករខ្នាតតូច នៅក្នុងកិច្ចអភិវឌ្ឍកសិកម្ម រួមទាំងការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ និងការចូលរួមចំណែកចំពោះសេដ្ឋកិច្ចជាតិ។ នៅដំណាក់កាលនេះ ទីភ្នាក់ងាររដ្ឋាភិបាលជាពិសេស អគ្គនាយកដ្ឋានកសិកម្ម បានផ្តល់នូវក្របខណ្ឌគតិយុត្ត ដូចជាច្បាប់ស្តីពីសហគមន៍កសិកម្ម និងអនុក្រឹត្យស្តីពីការធ្វើកសិកម្មតាមកិច្ចសន្យាដល់កសិករ ដើម្បីបង្កើតជាសហគមន៍កសិកម្ម និងធ្វើឲ្យប្រសើរឡើងនូវអាជីវកម្មកសិកម្ម។ សហគមន៍

កសិកម្មចំនួន៥៥៦ ត្រូវបានបង្កើតឡើង ហើយបច្ចុប្បន្នកំពុងមានដំណើរការ[3]។ បច្ចុប្បន្ន អគ្គនាយកដ្ឋានកសិកម្ម កំពុងដំណើរការរៀបចំឯកសារបណ្តុះបណ្តាលគោលចំនួន២គឺៈ ១) ការបណ្តុះបណ្តាលគ្រូបង្គោលសហគមន៍កសិកម្ម និង២) ឯកសារបណ្តុះបណ្តាល ដើម្បីកសាងសមត្ថភាពសហគមន៍កសិកម្ម។ អគ្គនាយកដ្ឋានកសិកម្ម មានផែនការក្នុងការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ឃុំ ក្នុងឃុំទាំងអស់នៅកម្ពុជា និងដាក់ឲ្យមានគ្រូបង្គោល/អ្នកសម្របសម្រួលសហគមន៍កសិកម្មចំនួន ០២ នាក់ក្នុង ១ ឃុំ ដើម្បីផ្តល់សេវាកម្មទាក់ទងនឹងសហគមន៍កសិកម្មទូទាំងប្រទេស។

## *7.4. បច្ចេកទេសកសិកម្ម និងទីផ្សារ*

ដូចដែលបានបង្ហាញ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ទំនើបកម្មមានន័យថា មធ្យោបាយមួយដើម្បីលើកកម្ពស់ផលិតភាព តាមរយៈការបង្កើនការប្រើប្រាស់ឧបករណ៍គ្រឿងយន្ត ប្រព័ន្ធស្រោចស្រព ពូជដែលបានកែលម្អ ការប្រើប្រាស់នូវធាតុចូលគីមី និងការអនុវត្តបច្ចេកទេសដែលបានកែលម្អជាដើម។ រហូតមកដល់បច្ចុប្បន្ន កសិករបានទទួលយកនូវឧបករណ៍គ្រឿងយន្ត ដូចជា ត្រាក់ទ័រសម្រាប់ការភ្ជួររាស់ និងដឹកជញ្ជូនផលិតផល និងធាតុចូលកសិកម្ម។ ដូច្នេះ វាអាចធ្វើឲ្យកសិកម្មត្រូវការកម្លាំងពលកម្មមនុស្សតិចជាងមុន។ រដ្ឋាភិបាលបានផ្តល់នូវការគាំទ្រផ្នែកច្បាប់ និងនីតិវិធីក្នុងការនាំចូលនូវធាតុចូលកសិកម្មដូចជា ជី អ័រម៉ូន ថ្នាំសម្លាប់សត្វល្អិត គ្រាប់ពូជ រួមនឹងឧបករណ៍ដូចជា ត្រាក់ទ័រ ម៉ាស៊ីនបាញ់ថ្នាំ។ល។ ក្នុងពេលបច្ចុប្បន្ន ជាមួយនឹងលទ្ធភាពអាចប្រើប្រាស់បានសេវាអ៊ីនធើណែត ឯកសារបច្ចេកទេសជាច្រើន ឬវីដេអូឃ្លីបខ្លីៗស្តីពីកសិកម្ម អាចរកបានតាមប្រព័ន្ធអនឡាញ និងការចែករំលែកផងដែរតាមប្រព័ន្ធហ្វេសប៊ុក។ ទោះយ៉ាងណាក្តី ឧបករណ៍ទាំងនេះអាចទទួលបាន និងផ្តល់អត្ថប្រយោជន៍ភាគច្រើន តែក្នុងចំណោមកសិករដែលបានទទួលការអប់រំ ឬមន្ត្រីជំនាញប៉ុណ្ណោះ។ គ្រួសារកសិករខ្នាតតូចដែលមានវប្បធម៌នៅមានកម្រិត មិនអាចទទួលបាននិងទទួលអត្ថប្រយោជន៍ពីសម្ភារៈទាំងនេះទេ។

អ្នកផ្តល់ព័ត៌មានសំខាន់ៗថ្នាក់ជាតិ បានចែករំលែកនូវគំនិតអំពីប្រព័ន្ធស៊ាំញ៉ាំនៃការគាំទ្រ ចំពោះគ្រួសារកសិករខ្នាតតូចដែលរួមមានទាំងបញ្ហាប្រឈម និងក្តីសង្ឃឹម។

---

[3] សិក្ខាសាលាៈ វិស័យកសិកម្មកម្ពុជាៈ ភាពរួចស្រេចបាច់ សម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ាន ២០១៥ និងតទៅថ្ងៃមុខ នៅសណ្ឋាគារសុខា នាទីក្រុងភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥។

ការគាំទ្របច្ចេកទេសអាចជួយពួកគាត់បង្កើនផលិតភាពកសិកម្ម។ ទោះយ៉ាងណាក្តី វាគ្រាន់តែជាចំណុចចាប់ផ្តើមនៅឡើយ ការតភ្ជាប់ពួកគាត់ទៅកាន់ទីផ្សារ ដើម្បីធ្វើពាណិជ្ជកម្មផលិតផលរបស់ពួកគាត់ គឺជាជំហានមួយផ្សេងទៀត ដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់។ ការតភ្ជាប់កសិករទៅកាន់ទីផ្សារមានន័យថា ជាការកំណត់នូវបែបផែននៃការផ្គត់ផ្គង់ដើម្បីធានាថា កសិករទទួលបានអត្ថប្រយោជន៍ជាបន្តបន្ទាប់ពីផលិតកម្មកសិកម្មរបស់ពួកគាត់។ ការធ្វើផែនការផលិតកម្ម និងការផ្តល់ជំនាញនៃការរៀបចំដល់អ្នកផលិត មានសារសំខាន់បំផុត ដើម្បីជួយបង្កើនលទ្ធភាពទទួលបានទីផ្សារ។

វាត្រូវបានគេជឿថា ដើម្បីបង្កើនផលិតកម្ម និងថែរក្សានូវអត្ថប្រយោជន៍ ការតភ្ជាប់កសិករទៅកាន់ទីផ្សារ គួរត្រូវបានពង្រីកពីទីផ្សារក្នុងតំបន់ ទៅទីផ្សារនៅទីក្រុង និងបន្ទាប់មក ទៅកាន់ទីផ្សារនាំចេញ។ ក្នុងកិច្ចនេះមិនត្រឹមតែចាំបាច់ត្រូវបង្កើនទំហំនៃការលក់ប៉ុណ្ណោះទេ តែគុណភាព និងភាពជាក់លាក់នៃផលិតផលក៏ត្រូវធានាផងដែរ។ អ្នកផលិតត្រូវគោរពនូវច្បាប់អាជីវកម្ម ដូចជាបរិមាណ ពេលវេលាផ្គត់ផ្គង់ គុណភាព និងតម្រូវការជាក់លាក់ជាដើម។

ការផ្សារភ្ជាប់គ្រួសារកសិករខ្នាតតូច បានក្លាយជាប្រធានបទពេញនិយម នៃចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍ បន្ទាប់ពីការចេញនូវរបាយការនៃវឌ្ឍភាពពិភពលោកក្នុងឆ្នាំ២០០៨។ របាយការណ៍បានគូសបញ្ជាក់ថា ដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ វាជាការចាំបាច់ដែលត្រូវផ្សារភ្ជាប់កសិករទៅកាន់ទីផ្សារ។ ចាប់តាំងពីពេលនោះមក គម្រោងអភិវឌ្ឍន៍ជាច្រើនព្យាយាមដាក់បញ្ចូលនូវ "ការតភ្ជាប់កសិករទៅកាន់ទីផ្សារ" នៅក្នុងគម្រោងស្នើសុំរបស់ពួកគេ។ ទោះយ៉ាងណាក្តី ដើម្បីទទួលបានជោគជ័យ នៅក្នុងការភ្ជាប់កសិករទៅកាន់ទីផ្សារ វាទាមទារនូវការរៀបចំជាលក្ខណៈយុទ្ធសាស្រ្ត។ ការជ្រើសរើសប្រភេទមុខដំណាំ ដើម្បីណែនាំទៅកាន់ទីផ្សារគឺជាតថភាពគន្លឹះនៃយុទ្ធសាស្រ្តមួយ ដើម្បីចូលទៅកាន់ទីផ្សារបាន។

យុទ្ធសាស្រ្តទីផ្សារ ២ប្រភេទ ត្រូវបានកត់សម្គាល់: ចង្វាក់សាកល និងចង្វាក់ប្រមូលផ្តុំពីមូលដ្ឋានៈ

**យុទ្ធសាស្រ្តចង្វាក់ប្រមូលផ្តុំពីមូលដ្ឋានៈ**យុទ្ធសាស្រ្តនេះ ត្រូវបានបង្កើតឡើងដោយអ្នកស្រាវជ្រាវនៃវិទ្យាស្ថានស្រាវជ្រាវជាតិ ក្សេត្រសាស្រ្ត (INRA) និងមជ្ឈមណ្ឌល

សហប្រតិបត្តិការអន្តរជាតិ សម្រាប់ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្ម (CIRAD)។ យុទ្ធសាស្ត្រចង្វាក់ប្រមូលផ្តុំពីមូលដ្ឋានមានប្រភពដើម ចេញមកពីការស្រាវជ្រាវផ្នែកបច្ចេកទេសកសិកម្ម។ យុទ្ធសាស្ត្រនេះ ផ្តោតសំខាន់លើប្រព័ន្ធផលិតកម្មក្នុងស្រុក ហើយដែលប្រព័ន្ធនេះ ទទួលរងឥទ្ធិពល ពីស្ថាប័នសាធារណៈ (Raikes et all., 2000)។ ឧទាហរណ៍ នៅពេលរដ្ឋាភិបាល ចុះកិច្ចព្រមព្រៀង នាំចេញនូវផលិតផលកសិកម្មជាក់លាក់ណាមួយក្នុងបរិមាណច្រើន វាចាំបាច់ត្រូវធានានូវការផ្តល់នូវ ផលិតផលទាំងនោះ។ ហេតុដូច្នេះ អ្នកផលិតធំៗភាគច្រើននឹងចុះកុងត្រាបន្ត ឬចូលរួមដើម្បីផលិតនូវផលិតផលនាំចេញទាំងនោះ តាមបរិមាណត្រូវការ ខណៈដែលអ្នកផលិតតូចៗ(កសិករ) កម្រមានឱកាស ផ្គត់ផ្គង់នូវផលិតផលក្នុងចំនួនច្រើនដូច្នេះ។ លើសពីនេះ ការវិភាគពីចង្វាក់ប្រមូលផ្តុំពីមូលដ្ឋាន ដាក់បញ្ចូលទាំងទ្រឹស្តីបណ្តាញសង្គម សម្រាប់យុទ្ធសាស្ត្រទូលំទូលាយ នៃទំនាក់ទំនងសង្គម និងអន្តរការនេះ។ យុទ្ធសាស្ត្រទីផ្សារនេះ ក៏មានគោលបំណងកសាងនូវទំនាក់ទំនងសង្គមរឹងមាំ ក្នុងចំណោមក្រុមអ្នកផលិតដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ និងទំនាក់ទំនងជាមួយអតិថិជន ដើម្បីកសាងនូវទំនុកចិត្តក្នុងរង្វង់អ្នកផលិត ដើម្បីទទួលបានតម្លៃទីផ្សារខ្ពស់ជាងផលិតផលធម្មតា។ នេះតម្រូវឲ្យមានការវិភាគដោយផ្តោតលើប្រភេទមុខទំនិញ ដែលយុទ្ធសាស្ត្រទីផ្សារនេះមានលក្ខណៈសមស្របបំផុត។

រហូតមកដល់ពេលនេះ សេដាក បានធ្វើការលើកកម្ពស់ ផលិតកម្មអង្ករសរីរាង្គដោយជោគជ័យ ដោយសារគេបានកំណត់នូវតម្លៃធានា និងព្រមព្រៀងទិញផលិតផល ក្នុងបរិមាណជាក់លាក់ណាមួយសម្រាប់ការកែច្នៃ និងផ្គត់ផ្គង់ទៅកាន់ទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ។ លើសពីនេះ វិទ្យាស្ថានស្រាវជ្រាវ និងការអភិវឌ្ឍជនបទកម្ពុជា (អង្គការ CIRD) ក៏បានធ្វើការជាមួយកសិករដាំម្រេច និងរៀបចំក្រុមផលិត ដោយអនុវត្តន៍តាមយុទ្ធសាស្ត្រចង្វាក់ទីផ្សារប្រមូលផ្តុំពីមូលដ្ឋាន។ ពួកគេបានរៀបចំកិច្ចការ ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ផលិតផលសម្គាល់ភូមិសាស្ត្រសម្រាប់ម្រេចកំពត។ ម្រេចកំពត មានកេរ្តិ៍ឈ្មោះល្អ ទាំងនៅលើទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ ជាពិសេសទីផ្សារអឺរ៉ុប។ ជាមួយនឹងកេរ្តិ៍ឈ្មោះនេះ អ្នកធ្វើការនាំចេញបានទាក់ទងជាមួយក្រុមផលិតម្រេចកំពត និងរៀបចំកិច្ចសន្យាសម្រាប់ទីផ្សារនាំចេញ។

**យុទ្ធសាស្ត្រចង្វាក់ទីផ្សារសាកល៖** យុទ្ធសាស្ត្រចង្វាក់សាកលត្រូវបានអភិវឌ្ឍន៍ឡើងដោយលោក Gary Gereffi និង មនុស្សមួយចំនួនទៀត ក្នុងសេដ្ឋកិច្ចនយោបាយនៃការរំពឹងការអភិវឌ្ឍ (Gereffi, 1999)។ ការវិភាគពីយុទ្ធសាស្ត្រចង្វាក់សាកល ត្រូវ

បានអភិវឌ្ឍន៍ជាសំខាន់ សម្រាប់ចង្វាក់សេដ្ឋកិច្ចសាកល(Raikes et all., 2000)។ វាផ្តោតទៅលើការលេចឡើង នៃប្រព័ន្ធផលិតកម្មសាកលថ្មីមួយ ដែលការធ្វើសមាហរណកម្មសេដ្ឋកិច្ចហួស ពីពាណិជ្ជកម្មអន្តរជាតិក្នុងវត្ថុធាតុដើម និងផលិតផលសម្រេច (Gereffi, 2000)។ នាពេលបច្ចុប្បន្ន ដំឡូងមីដែលដាំដុះនៅកម្ពុជា ត្រូវបាននាំចេញទៅប្រទេសវៀតណាម។ នេះគឺជាយុទ្ធសាស្ត្រចង្វាក់ទីផ្សារសាកល។ ដើម្បីបំពេញនូវធម្មជាតិនៃតម្រូវការទីផ្សារ នៃឧស្សាហកម្មដំឡូងមី អ្នកផលិតនៅកម្ពុជាបានដាំដុះដំណាំដំឡូងមី ដើម្បីផ្គត់ផ្គង់ទៅទីផ្សារ។ ទោះយ៉ាងណាក្តី ដោយសារកង្វះការសម្របសម្រួល និងការអនុវត្តបទប្បញ្ញត្តិដែលបានកំណត់ក្នុងចំណោមភាគីពាក់ព័ន្ធ អ្នកផលិតជារឿយៗ ខ្វះនូវអំណាចនៃការចរចារ និងបរាជ័យនៅក្នុងអាជីវកម្មរបស់ខ្លួន ដោយសារបរិមាណផ្គត់ផ្គង់លើសលប់ និងតម្លៃលក់ចេញទាប។ នេះដោយសារការពិតថា ដំឡូងមីមិនអាចយកត្រឡប់មកចូលទីផ្សារក្នុងស្រុក សម្រាប់ការប្រើប្រាស់បានទេ ប្រសិនវាមិនត្រូវបាននាំចេញនោះ។

ដើម្បីផ្តល់អត្ថប្រយោជន៍ដល់គ្រួសារកសិករខ្នាតតូច យុទ្ធសាស្ត្រចង្វាក់ប្រមូលផ្តុំពីមូលដ្ឋានគួរត្រូវបានលើកកម្ពស់ នៅដំណាក់កាលដំបូង។ បន្ទាប់មកការច្របាច់បញ្ចូលគ្នានូវយុទ្ធសាស្ត្រទាំងពីរនេះ គប្បីត្រូវបានអនុវត្តន៍។ អង្គការសេដាកបានធ្វើការច្បាច់បញ្ចូលគ្នានូវយុទ្ធសាស្ត្រទាំងពីរប្រភេទនេះ ក្នុងកិច្ចអន្តរាគមន៍របស់ខ្លួនទៅលើប្រភេទអង្ករ ដែលត្រូវបានគេស្គាល់ថាជាទីផ្សារអង្ករសរីរាង្គ។ ក្នុងដំណាក់កាលដំបូង ក្រុមផលិតស្រូវសរីរាង្គត្រូវបានចងក្រងនៅកម្រិតភូមិ និងបន្ទាប់មកចងជាបណ្តាញថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ។ អង្ករសរីរាង្គ មានគោលដៅទីផ្សារជាច្រើនទាំងនៅក្នុងតំបន់នៅតាមទីក្រុង និងទីផ្សារនាំចេញ។ សហគ្រាសសេដាកទិញស្រូវសរីរាង្គពីកសិករ ហើយកិនលក់ទៅឲ្យអតិថិជននៅទីក្រុង។ នេះហៅថាយុទ្ធសាស្ត្រ ប្រមូលផ្តុំពីថ្នាក់មូលដ្ឋាន។ លើសពីនេះ សេដាកក៏ដើរតួនាទីជាឈ្មួញកណ្តាល និងសហការជាមួយក្រុមហ៊ុននាំចេញ ដើម្បីនាំចេញអង្ករសរីរាង្គទៅកាន់ទីផ្សារបរទេស ឧទាហរណ៍ សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិកជាដើម។ ក្នុងករណីនេះអ្នកនាំចេញ អង្ករសរីរាង្គបានធ្វើកិច្ចសន្យាជាមួយសេដាក ក្នុងបរិមាណអង្ករសរីរាង្គណាមួយ។ សេដាកធ្វើការសម្របសម្រួលជាមួយកសិករ ដើម្បីផលិតស្រូវសរីរាង្គ ដើម្បីបំពេញតាមតម្រូវការនាំចេញ។ តម្រូវការកំណត់មួយ ចំពោះអង្ករសរីរាង្គត្រូវបានយល់ព្រម ដោយទីផ្សារនាំចេញ ឬអ្នកបញ្ជាទិញដែលបន្ទាប់មកធ្វើការជាមួយក្រុមហ៊ុនក្នុងស្រុក (សហគ្រាសសេដាក) ហើយនេះត្រូវបានគេស្គាល់ថា ជា

យុទ្ធសាស្ត្រចង្វាក់ទីផ្សារសាកល។ ស្ដាប់ទៅ វាគឺជាយុទ្ធសាស្ត្រដ៏ល្អបំផុត ដើម្បីគាំទ្រដល់គ្រួសារកសិករតូចតាច ដើម្បីទទួលបានអត្ថប្រយោជន៍ពីទីផ្សារក្នុងស្រុក ថ្នាក់តំបន់ និងសាកលលោកផងដែរ។

## VIII. សន្និដ្ឋាន និងការផ្តល់អនុសាសន៍

ឆ្លុះបញ្ចាំងទៅនឹងការវិភាគនៃបញ្ហាអភិវឌ្ឍន៍ និងទំនាក់ទំនងរបស់វាសម្រាប់គ្រួសារកសិករខ្នាតតូច ដើម្បីត្រៀមសម្រាប់សមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន និងដើម្បីអាចប្រកួតប្រជែងបានជាមួយកសិករផ្សេងទៀត ក្នុងបណ្ដាប្រទេសជាសមាជិកអាស៊ាន គ្រួសារកសិករខ្នាតតូចនៅកម្ពុជាគួរមានសុវត្ថិភាព លើសិទ្ធិកាន់កាប់ដីធ្លី ទឹកសម្រាប់ការស្រោចស្រព មូលធនសម្រាប់ការវិនិយោគធាតុចូលបច្ចេកទេស ដើម្បីបង្កើនផលិតភាពកសិកម្ម និងរចនាសម្ព័ន្ធគ្រប់គ្រងទីផ្សារសម្រាប់ការធ្វើពាណិជ្ជកម្មផលិតផលរបស់ពួកគាត់។ ដូច្នេះ ការសិក្សាសូមធ្វើការសន្និដ្ឋាននិងផ្តល់អនុសាសន៍ថា៖

**សន្តិសុខស្តីពីលទ្ធភាពចំពោះសិទ្ធិកាន់កាប់ដីធ្លី៖** សន្តិសុខសិទ្ធិកាន់កាប់ដីធ្លី នៅក្នុងតំបន់ទំនាប ដែលពឹងអាស្រ័យលើរបបទឹកភ្លៀងមានលក្ខណៈល្អប្រសើរ ខណៈសន្តិសុខដីធ្លីនៅតំបន់ភ្នំ និងតំបន់ព្រៃឈើមានភាពប្រសើរឡើងច្រើន ចាប់តាំងពីមានការអនុវត្តបទបញ្ជា០១បប ជាពិសេសនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ដូចជាករណីនៅខេត្តរតនគីរីជាដើម។ ទោះយ៉ាងណាក្តី សន្តិសុខដីធ្លីសម្រាប់ប្រជាសហគមន៍នៅតំបន់ព្រៃឈើពីមុនៗ នៅចោទជាបញ្ហានៅឡើយ។ កសិករមានសិទ្ធិប្រើប្រាស់ដី និងធ្វើការផ្ទេរដីតាមរយៈការទិញ និងការលក់ដី ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្នដីរបស់ពួកគេនៅមិនទាន់បានទទួលស្គាល់ជាផ្លូវការជាទ្រព្យសម្បត្តិឯកជននៅឡើយ។ ជាឧទាហរណ៍ ករណីនៅស្រុកសន្ទុក ខេត្តកំពង់ធំ។ កសិករមានការស្ទាក់ស្ទើរ នៅក្នុងការវិនិយោគលើដីរបស់ពួកគាត់ ជាពិសេសលើដំណាំច្រើនឆ្នាំ ដោយសារវាទាមទារនូវការវិនិយោគធំ ប៉ុន្តែវាក៏ផ្តល់ឲ្យមកវិញនូវប្រាក់ចំណូលច្រើនផងដែរ។

ដូច្នេះ ការសិក្សាសូមផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តបទបញ្ជា០១បប ដើម្បីពង្រីកជំហានបន្តទៀតនូវបេសកកម្មដំណោះស្រាយដីធ្លី នៅតំបន់ផ្សេងទៀតក្នុងប្រទេសកម្ពុជា។ កសិករជាច្រើននៅរង់ចាំការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីពីរដ្ឋាភិបាល។

**សន្តិសុខចំពោះលទ្ធភាពទទួលបានទឹកស្រោចស្រព៖** ចាប់ពីអណត្តិទី២ នៃរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលបានវិនិយោគជាច្រើនទៅលើប្រព័ន្ធស្រោចស្រព ជាពិសេសប្រព័ន្ធស្រោចស្រពខ្នាតមធ្យម និងខ្នាតធំ។ ទោះយ៉ាងណាក្តី ក៏ប្រព័ន្ធស្រោចស្រពទាំងនោះផ្តោតជាសំខាន់ទៅលើផលិតកម្មស្រូវ ឬសម្រាប់ដំណាំមិនមែនស្រូវនៅក្នុងប្រព័ន្ធអេកូដំណាំស្រូវ។ ដោយសារតែបរិបថដែលមានការផ្លាស់ប្តូរ កសិករបានទទួលយកដំណាំមិនមែនស្រូវ និងការចិញ្ចឹមសត្វសម្រាប់តម្លៃបន្ថែមខ្ពស់ និងសម្រាប់លក់។ តម្រូវការសម្រាប់លទ្ធភាពទទួលបានទឹកនៅក្នុងប្រព័ន្ធអេកូនៃការដាំដុះដំណាំមិនមែនស្រូវ ត្រូវបានកត់សម្គាល់នៃការកើនឡើងខ្ពស់។ ជាពិសេស ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធផលិតកម្មស្បៀង ប្រកបដោយនិរន្តរភាពក្នុងកម្រិតគ្រួសារ និងដើម្បីសម្រេចនូវសន្តិសុខស្បៀងក្នុងតំបន់ជនបទ ប្រព័ន្ធស្រោចស្រពខ្នាតតូច មានភាពចាំបាច់បំផុត។

ដូច្នេះ ការសិក្សាសូមផ្តល់ជាអនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជា ពិចារណាលើការវិនិយោគលើប្រព័ន្ធស្រោចស្រពខ្នាតតូច នៅក្នុងតំបន់ដែលងាយទទួលរងនូវគ្រោះរាំងស្ងួត។

**សន្តិសុខចំពោះលទ្ធភាពទទួលបានទុនសម្រាប់វិនិយោគ៖** រយៈពេល៣ អណត្តិចុងក្រោយនៃរាជរដ្ឋាភិបាលកម្ពុជា ប្រព័ន្ធហិរញ្ញវត្ថុមានភាពប្រសើរឡើងច្រើន និងបានទៅដល់គ្រប់តំបន់ទាំងអស់នៅទូទាំងប្រទេស។ គ្រួសារជនបទជាច្រើន បានទទួលស្គាល់ថាមានលទ្ធភាពទទួលបាននូវប្រាក់កម្ចីពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ។ លើសពីនេះ ឧទាហរណ៍មួយពីអង្គការសេដាក និងបណ្តាញកសិករនិងធម្មជាតិ កសិករបានចងក្រងគ្នាជាសមាគមភូមិ និងធ្វើការសន្សំខ្ចីសងក្នុងទំហំតិចតួច។ ជាបន្តបន្ទាប់សមាគមសន្សំនៅថ្នាក់ភូមិ បានចូលរួមជាមួយគ្នាបង្កើតជាសមាគមសន្សំថ្នាក់ឃុំ និងជាសមាគមសន្សំថ្នាក់ស្រុក។ ចេញពីសមាគមសន្សំថ្នាក់ស្រុកចំនួន ៦០ស្រុក កសិករបានវិនិយោគនូវទុនរបស់ខ្លួន សាងសង់រោងម៉ាស៊ីនកិនស្រូវថ្នាក់ស្រុក ដែលមានស្តង់ដារនាំចេញ។ រោងម៉ាស៊ីនកិនស្រូវចំនួន០៧ ត្រូវបានសាងសង់ និងបំពាក់ដោយបរិក្ខាផ្សេងៗក្នុងរោងម៉ាស៊ីន។ ទោះយ៉ាងនេះក្តី ដើម្បីបង្កើតរោងម៉ាស៊ីនកិនស្រូវថ្នាក់ស្រុកចំនួន៦០នោះ ការផ្តោតសំខាន់ឲ្យបានខ្លាំងជាងមុនលើការសន្សំរួមគ្នា គឺជាការចាំបាច់បំផុត។

ដូច្នេះ ការសិក្សាសូមផ្តល់ជាអនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជា ធ្វើការពិចារណាផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុ [កម្ចី] ដល់សមាគមថ្នាក់ស្រុកដែលបានបង្កើតឡើងហើយ ដើម្បីពួកគាត់អាចបង្កើនល្បឿននៃការអភិវឌ្ឍសហគមន៍។

**សន្តិសុខស្តីពីលទ្ធភាពទទួលបានចំណេះដឹងបច្ចេកទេស និងការគាំទ្រការសម្របសម្រួល៖** មានគំនិតច្នៃប្រឌិត ឬចំណេះដឹងថ្មីៗនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ តាមរយៈគម្រោងអភិវឌ្ឍន៍ដែលអនុវត្តន៍ដោយស្ថាប័នរដ្ឋាភិបាល ឬ/និងអង្គការមិនមែនរដ្ឋាភិបាល កសិករបានរៀនសូត្រ ទទួលយកនូវការអនុវត្តបច្ចេកទេសរួមនឹងដំណាំប្រភេទពូជថ្មី។ ក្រៅអំពីសេវាកម្មបច្ចេកទេសដែលផ្តល់ដោយគម្រោង សហគ្រាសឯកជនក៏បានដើរតួនាទីក្នុងការផ្តល់នូវចំណេះដឹងបច្ចេកទេសផងដែរ។ ទោះយ៉ាងណាក្តី នៅមានករណីដែលកសិករជារឿយៗជួបនឹងការបរាជ័យក្នុងការប្រមូលផលផលិតកម្មកសិកម្មរបស់ពួកគាត់ អាស្រ័យដោយកំហុសបច្ចេកទេស ឬការអនុវត្តមិនត្រឹមត្រូវ ឬអាចទទួលបានផលិតភាពទាបបំផុតពីផលិតកម្មកសិកម្មរបស់ពួកគាត់។ វាត្រូវបានកត់សម្គាល់ផងដែរថា នាពេលបច្ចុប្បន្ន កសិករបានដឹងពីសារសំខាន់ដើម្បីទទួលយកបច្ចេកទេស ឬពូជថ្មី ដើម្បីទទួលបានអត្ថប្រយោជន៍ពីតម្រូវការនៃទីផ្សារតែក៏នៅជួបនឹងកង្វះឧបករណ៍ចាំបាច់មួយចំនួន។ ការនេះបង្កឲ្យមាននូវការអូសបន្លាយការសម្របបានចំពោះគំនិតច្នៃប្រឌិតបច្ចេកទេសថ្មី។ អគ្គនាយកដ្ឋានកសិកម្មមានផែនការក្នុងការបង្កើតនូវសហគមន៍កសិកម្ម និងមជ្ឈមណ្ឌលគាំទ្រសេវាបច្ចេកទេស នៅគ្រប់ឃុំទាំងអស់នៅទូទាំងប្រទេស។ មជ្ឈមណ្ឌលនឹងបំពាក់នូវបុគ្គលិកបច្ចេកទេស ០២នាក់ ដើម្បផ្តល់សេវាទៅឲ្យកសិករ។

ហេតុនេះ ការសិក្សាសូមផ្តល់ជាអនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើនល្បឿននៃគំនិតផ្តួចផ្តើមនេះ។ លើសពីនេះ រដ្ឋាភិបាលគួរវិនិយោគបន្ថែមទៀតក្នុងការងារស្រាវជ្រាវបច្ចេកទេសកសិកម្ម។ ការស្រាវជ្រាវ គួរមានទិសដៅសម្រាប់ផលប្រយោជន៍នៃផលិតភាពកសិកម្មរបស់គ្រួសារកសិករខ្នាតតូច។

# បញ្ជីឯកសារយោង

ADB. (2015, 19-21). *Promoting Women's Economic Empowerment in Cambodia, Manila, Philippines.*

ASEAN Economic Community Department and ASEAN Secretariat . (2015, 56). *Vision and Strategic Plan for ASEAN Cooperation in Food, Agriculture and Forestry 2016-2025.*

ASEAN Secretariat. (2015a, 10-12). *A Blueprint for Growth ASEAN Economic Community 2015: Progress and Key Achievements: Jakarta.*

ASEAN Secretariat. (2015b, 20). *ASEAN Economic Community Blueprint 2025, Jakarta.*

Asian Development Bank. (2015b, 8). *Realizing an Asean Economic Community - Opportunity and Challaneges, Cambodia, Manila, Philippines.*

Bank, I. L. (2015, 87). *Cambodia Addressing the Skills Gap: Emploment Dianostic StudyL Geneva: ILO: ADB.*

Caballero-Anthony. (2013, 2). *ASEAN Economic Community (AEC) 2015.*

Castella. (2007). *Transitions Agraire et Dynamiques Environmentales en Asie du Sud-Est: D'une Gestion de Projet a une Gouvermance des Territoires, Memoire pour l'habilitation a diriger les recherhes, Universite d'Avignon et des Pays du Vaucluse.*

Chay Keartha and Chheang Sokmao. (2015). *How Farmers in Rainfed Ecosystmes Make Their Livings under the Irregular Rainfall Conditions.*

Diepart. (2015). *The Cambodian peasantry and the formalisation of land rights: Historical overiew and current issues.*

FAO. (2014, 5). *Food and Agriculture Policy decision analysis, Country fact sheet on Food and agriculture policy trends Cambodia, april2014, Rome, Italy.*

Gereffi. (1999). *A Commodity Chain Framework for Analyzing Global Industries, Duke University.*

Gereffi. (2000). *Beyond the producer-driven/buyers-driven dichotomy: An Expanded Typology of Global Value Chains, with Special Reference to the Internet, Duke University.*

Gironde et al.,. (2014). *Large-Scale Land Acquisitions in Southeast Asia: Rural Transformations between global agendas and people's right to food, working paper, June 2014.*

ILO Regional Office for ASIA & the Pacific, and Asian Development Bank. (2014). *ASEAN Community 2015: Managing Integration for Better Jobs and Shared Prospertiy: Bangkok: ILO.*

Im Chhun Lim. (2012). *Senior Minister and MInister of Land Management, Urban Planning and Construction and Chairman of Council of Land Policy, Speech at the GDCC, 26 September 2012, Phnom Penh.*

International Labour Office, and ASIAN Development Bank. (2015). *Cambodia Addressing the Skills Gap: Employment Diagnostic Study: Geneva: ILO: ADB.*

Invest in ASEAN. (2016). *"Agriculture: Planning the seeds of Progress" Invest in ASEAN Official Investment Promotion Webside of ASEAN.*

LICADHO. (2014). *HUman Rights 2013: The Year in Review, Licadho, Cambodian league for the Promotion and Defense of Human Rights, February 2014.*

Messerli et al.,. (2015). *Marginal land marginal people? Analysis Patterns and Process of Large-Scale Land Acquisitions in Southeast Asia., International Development Policy Review, Special Edition on Scale Land Acquisitions.*

NIS. (2015). *STATISTICAL YEARBOOK OF CAMBODIA 2013.*

NIS. (2015). *STATISTICAL YEARBOOK OF CAMBODIA 2013.*

Raikes et all. (2000). *Global Commodity Chain Analysis and The French Filiere Approach: Comparision and Critique, Economy and Society, Volume 29, Number 3.*

Raikes et all. (2000). *Global Commodity Chain Analysis and The French Filiere Approach: Comparision and Critique, Economy and Society, Volume 29, Number 3.*

RGC. (2008). *Law on Seed Management and Plant Breeders' Rights.*

RGC. (2011). *Sub-Decree on Contract-Based Agriculture Production (Contract-Farming).*

RGC MAFF. (2013). *Law on Agriculture Cooperatives.*

RGC MAFF. (2015). *Agricultural Sector Strategic Development Plan (ASSDP) 2014-2018.*

RGC MoP. (2014). *National Strategic Development Plan (NSDP) 2014-2018.*

Sperfeldt et al.,. (2012). *An Examination of Policies Promoting Large-Scale Investments in Farmland in Cambodia, Cambodian Human Rights Action Committee (CHRAC).*

Taing Vida. (2015). *"Lifespan of ELCs slashed by gov't". The Phnom Penh Post, July 29.*

Thapa and Gaiha. (2011). *Smallholder Farming in Asia and the Pacific: Challenges and Opportunities. in IFAD Conference on New Directions for Smallholder Agriculture Session 3. Rome.*

The Economist Intelligence Unit. (2015, 26). *Global food security index 2015-an annual measure of the state of global food security, London United Kingdom.*

Thuon et al. (2007). *Managing Water in Rainfed Agriculture in the Greater Mekong Subregion.*

USAID. (2011). *USAID Country Profile: Property Rights and Resource Governance, Cambodia.*

Wokker et al. (2011). *Irrigation Water Productivity in Cambodian Rice Systems.*

Worldbank. (2015). *Cambodia Data December 13.*

## ឧបសម្ព័ន្ធទី១៖ បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ

| ល.រ | ឈ្មោះអ្នកផ្តល់ព័ត៌មាន | តួនាទី/មុខងារ |
|---|---|---|
| ១ | លោក ថៃ ឈុនហាក់ | អនុប្រធានអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងការអភិវឌ្ឍសេដ្ឋកិច្ច |
| ២ | ឯ.ឧ. ថោង ចិន្តា | សាការីសាធារណៈនិងដៃគូផ្នែកគ្រប់គ្រង |
| ៣ | លោកបណ្ឌិត សុខ ស៊ីឡូ | អនុរដ្ឋលេខាធិការ ក្រុមប្រឹក្សា សម្រាប់ការអភិវឌ្ឍកសិកម្ម និងជនបទ |
| ៤ | លោកបណ្ឌិត យ៉ង សាំងកុមារ | អតីតប្រធានអង្គការសេដាក |
| ៥ | លោកបណ្ឌិត សាម អ៊ីន | អតីតនាយកប្រតិបត្តិអង្គការជីវិតថ្លៃថ្នូរ |
| ៦ | លោក កាន់សាឡុន | អនុប្រធានមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ៧ | លោក ងិន ឆាយ | ប្រធាននាយកដ្ឋានដំណាំស្រូវនៃអគ្គនាយកដ្ឋានកសិកម្ម |
| ៨ | លោក ជូ ជ័យធីរិទ្ធ | អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ-កម្មវិធីអាយភីអឹមកម្ពុជា |
| ៩ | លោក សរ សានភារម្យ | អ្នកប្រឹក្សាយោបល់ |
| ១០ | លោក សូ សុខា | អតីតប្រធានកម្មវិធីអង្គការស្រែខ្មែរ បច្ចុប្បន្នជាអ្នកប្រឹក្សាយោបល់ |
| ១១ | លោក អ៊ឹង សេង | អតីតមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃអង្គការសេដាក បច្ចុប្បន្នជាអ្នកប្រឹក្សាយោបល់ |
| ១២ | លោក អាន គឹមហេង | អ្នកស្រាវជ្រាវផ្នែកកសិពាណិជ្ជកម្មនៃមជ្ឈមណ្ឌលសិក្សាគោលនយោបាយ |
| ១៣ | លោក ហេង ឈុនហ៊ី | អនុប្រធាននាយកដ្ឋានការពារដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម |
| ១៤ | លោក គាម មករាឌី | នាយកកម្មវិធីបរិស្ថាន និងសុខភាពអង្គការសេដាក |

| | | |
|---|---|---|
| ១៥ | លោក ចាន់ សុផល | នាយកប្រតិបត្តិមជ្ឈមណ្ឌលសិក្សាគោលនយោបាយ |
| ១៦ | លោក ជីន គ្រីស្តុប ឌីប៉ាត | ទីប្រឹក្សាស្រាវជ្រាវ នៃកម្មវិធីអភិបាលកិច្ចដីតំបន់មេគង្គ |
| ១៧ | លោក អ៊ុង តាភារ័ត្នមុន្នី | អតីតទីប្រឹក្សាអង្គការយូអិនឌីភី/អាយហ្វាត កម្ពុជា បច្ចុប្បន្នជាអ្នកប្រឹក្សាយោបល់ |
| ១៨ | លោក ធុន វឌ្ឍនា | នាយកសាលាកសិកម្មព្រែកលៀប |
| ១៩ | លោក ងិន ចាន់រិទ្ធិ | សាស្ត្រាចារ្យនៃដេប៉ាតឺម៉ង់ ការសិក្សាពីការអភិវឌ្ឍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២០ | លោក អម សុខា | ទីប្រឹក្សាស៊ើបអង្កេតទំនាស់ អង្គការអាដហុក |
| ២១ | លោក សយ សុណា | ប្រធានមន្ទីរកសិកម្មខេត្តរតនគីរី |
| ២២ | កញ្ញា បេង ប៊ុនណេត | ព្រឹទ្ធបុរសរងផ្នែករដ្ឋបាលដីធ្លី នៃសាកលវិទ្យាល័យភូមិន្ទកសិកម្មចម្ការដូង |

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា**
អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ-៣ កម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែលៈ **ngoforum@ngoforum.org.kh**
គេហទំព័រៈ **www.ngoforum.org.kh**